

# ការបង្ការ និងទប់ស្កាត់ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

## ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល

រក្សាសិទ្ធិដោយ៖

APLE

## ការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

### សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល

**រក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ២០២១**

សៀវភៅនេះត្រូវបានរៀបចំ និងផលិតឡើងដោយអង្គការសកម្មភាពដើម្បីកុមារ (APLE)
ក្រោមការរៀបរៀង និងនិពន្ធដោយ លោកស្រី **Avigal Orha** និងត្រូវបានរៀបចំចងក្រងជាភាសាខ្មែរដោយ
ក្រុមការងារអង្គការសកម្មភាពដើម្បីកុមារ

**ឯកសារនេះត្រូវបានរចនាឡើងដោយមានការគាំទ្រថវិកាពី៖**

អង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំប្រទេសកម្ពុជា Terre des Hommes Netherlands in Cambodia

**និងត្រូវបានបោះពុម្ពផ្សព្វផ្សាយដោយមានការគាំទ្រថវិកាពី៖**

អង្គការភ្លែនអន្តរជាតិកម្ពុជា Plan International Cambodia
តាមរយៈគម្រោងកិច្ចការពារជំនាន់ថ្មី Protection Plus

អង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំប្រទេសកម្ពុជា Terre des Hommes Netherlands in Cambodia
តាមរយៈគម្រោង Sweetie 24/7 Cambodia

អង្គការមូលនិធិវើលឆាលហូដ World Childhood Foundation
តាមរយៈគម្រោង World Childhood Hotline

រាល់ខ្លឹមសារនានាដែលបានបង្ហាញនៅក្នុងសៀវភៅនេះ មិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា Plan International Cambodia អង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំប្រទេសកម្ពុជា Terre des Hommes Netherlands in Cambodia និងអង្គការមូលនិធិវើលឆាលហូដ World Childhood Foundation នោះទេ។

**រាល់ខ្លឹមសារដកស្រង់ចេញពីសៀវភៅនេះត្រូវដាក់ប្រភពដូចខាងក្រោម៖**

អង្គការសកម្មភាពដើម្បីកុមារ (APLE) *សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល៖ "ការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ"*
រាជធានីភ្នំពេញ ឆ្នាំ២០២១

**រូបថត៖** រូបថតទាំងអស់ ត្រូវបានរក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ។ គ្រប់រូបភាពកុមារទាំងអស់ក្នុងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលនេះ គឺត្រូវបានប្រើប្រាស់ក្នុងគោលបំណងដើម្បីបង្ហាញ និងប្រើប្រាស់តែក្នុងន័យផ្សព្វផ្សាយអប់រំប៉ុណ្ណោះ ហើយមិនមែនជារូបភាពរបស់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទនោះឡើយ។

**អង្គការសកម្មភាពដើម្បីកុមារ (APLE)**

ការិយាល័យកណ្តាល រាជធានីភ្នំពេញ
ទូរស័ព្ទទំនាក់ទំនង៖ ០២៣ ៩៩៦ ៣៥១
អ៊ីម៉ែល៖ info@aplecambodia.org
គេហទំព័រ៖ www.aplecambodia.org

# មាតិកា


**សេចក្តីផ្តើម** ៥

**ផ្នែកទី១៖ សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល** ៧

ចំណុចគួរពិចារណា ដើម្បីឱ្យវគ្គបណ្តុះបណ្តាលដំណើរការប្រកបដោយប្រសិទ្ធភាព ៨

ក. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ មុនវគ្គបណ្តុះបណ្តាលមកដល់? ៨

ខ. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ ក្នុងអំឡុងវគ្គបណ្តុះបណ្តាល? ១១

គ. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ ក្រោយវគ្គបណ្តុះបណ្តាល? ១៩

**ផ្នែកទី២៖ ខ្លឹមសារលម្អិតនៃវគ្គបណ្តុះបណ្តាល** ២១

ជំពូក១៖ ការស្វែងយល់ពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២២

មេរៀនទី១៖ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២៥

មេរៀនទី២៖ ការស្វែងយល់ថានរណាជាជនល្មើសផ្លូវភេទលើកុមារ និងអ្វីជាវិធីដែលពួកគេប្រើប្រាស់? ៣៧

ជំពូក២៖ ការស្វែងយល់ពីអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ៤៦

មេរៀនទី១៖ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ៤៩

មេរៀនទី២៖ ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ៧៩

ជំពូក៣៖ ការឆ្លើយតបចំពោះអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ៨៧

មេរៀនទី១៖ ការស្គាល់ពីសញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការផ្តល់ជំនួយ និងការរាយការណ៍ ៨៩

មេរៀនទី២៖ សារៈសំខាន់នៃការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារ ១០៣

**ឧបសម្ព័ន្ធ** ១១១



# សេចក្តីផ្តើម

អង្គការសកម្មភាពដើម្បីកុមារ (APLE) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឈានមុខគេ ដែលធ្វើការយ៉ាងយកចិត្តទុកដាក់ ក្នុងកិច្ចការប្រយុទ្ធប្រឆាំងការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។

កម្មវិធីសំខាន់មួយក្នុងចំណោមកម្មវិធីទាំង៤របស់អង្គការសកម្មភាពដើម្បីកុមារ ផ្តោតលើការចូលរួមរបស់សហគមន៍ វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងសិទ្ធិអំណាចដល់ភាគីពាក់ព័ន្ធតាមរយៈចំណេះដឹង ជំនាញ និងវិធីសាស្ត្របង្ការពីហានិភ័យនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទក្នុងសហគមន៍របស់ពួកគេ។ កម្មវិធីនេះ ក៏ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីលើកកម្ពស់ការយល់ដឹង និងផ្តល់ការអប់រំដល់សមាជិកសហគមន៍នូវវិធីសាស្ត្រក្នុងការរក្សាកុមារឱ្យមានសុវត្ថិភាពពីហានិភ័យនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទជាពិសេសគឺផ្តោតលើការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ដើម្បីធានាបានថាចំណេះដឹងត្រូវបានបញ្ជ្រាបយ៉ាងទូលំទូលាយ អង្គការសកម្មភាពដើម្បីកុមារបាន និងកំពុងបណ្តុះបណ្តាលសមាជិកសហគមន៍សំខាន់ៗដទៃទៀតសំដៅឆ្ពោះទៅរកការក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរ និងផ្តល់ឱ្យពួកគេនូវជំនាញក្នុងការផ្តល់ចំណេះដឹងបន្ត ក៏ដូចជាកសាងបណ្តាញផ្តល់ព័ត៌មានប្រកបដោយការប្តេជ្ញាចិត្តខ្ពស់។

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះ គឺជាសៀវភៅដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមគោលដៅជាក់លាក់ជាពិសេសគឺភាគីពាក់ព័ន្ធដែលធ្វើការផ្ទាល់ជាមួយកុមារ។ សៀវភៅនេះ ផ្តោតសំខាន់លើការបណ្តុះបណ្តាលដល់អ្នកមានជំនាញវិជ្ជាជីវៈដែលមានមុខតំណែងតម្រូវឱ្យមានការទាក់ទងផ្ទាល់ជាមួយកុមារដូចជាគ្រូបង្រៀន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសអ្នកជំនាញដែលធ្វើការជាមួយកុមារមកពីសហគមន៍ងាយរងគ្រោះ។

# គោលបំណងសំខាន់នៃសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះគឺផ្តោតទៅលើ៖

១. លើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការផ្ទាល់ជាមួយកុមារអំពីបញ្ហានៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ក៏ដូចជាផ្តល់ឱ្យពួកគេនូវចំណេះដឹងដែលអាចជួយរក្សាសុវត្ថិភាពកុមារពីហានិភ័យទាំងនោះ។

២. ផ្តល់ឱ្យអ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការផ្ទាល់ជាមួយកុមារទាំងនោះនូវជំនាញ ដែលអាចឱ្យពួកគេប្រើប្រាស់ក្នុងការចែកចាយបន្តនូវចំណេះដឹងដែលពួកគេទទួលបានទៅឱ្យក្រុមគោលដៅសំខាន់ៗដទៃទៀត ជាពិសេសគឺអាចជម្រុញឱ្យមានការកើនឡើងនូវចំនួនមនុស្សដែលបានដឹងពីរបៀបការពារកុមារឱ្យចៀសផុតពីហានិភ័យនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។

# រចនាសម្ព័ន្ធនៃសៀវភៅ៖

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលនេះ ត្រូវបានបែងចែកជាពីរផ្នែកសំខាន់ៗ៖

### ផ្នែកទី១៖ សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល

មុននឹងឈានដល់ការស្វែងយល់អំពីមេរៀនសំខាន់ៗ សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល ក៏ត្រូវបានផ្តល់ជូនក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូបណ្តុះបណ្តាលបង្គោល និងផ្តល់ឱ្យពួកគេនូវឧបករណ៍ដែលចាំបាច់សម្រាប់ការផ្តល់វគ្គបណ្តុះបណ្តាលបន្តប្រកបដោយប្រសិទ្ធភាព។ ផ្នែកនេះ នឹងអាចជួយពង្រឹងនូវជំនាញក្នុងការសម្របសម្រួល/បណ្តុះបណ្តាល ជាពិសេសគឺវិធីសាស្ត្របញ្ជ្រាបចំណេះដឹងពីសៀវភៅណែនាំនេះ ដល់អ្នកចូលរួម។

### ផ្នែកទី២៖ ខ្លឹមសារលម្អិតនៃវគ្គបណ្តុះបណ្តាល

ផ្នែកនេះ នឹងផ្តោតសំខាន់លើមេរៀនគោល ហើយមេរៀនទាំងនោះនឹងត្រូវបែងចែកជា៣ផ្សេងគ្នា។ មេរៀននីមួយៗផ្តោតលើចំណុចសំខាន់ផ្សេងៗគ្នាជុំវិញការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ ជាងនេះទៅទៀត វគ្គនីមួយៗក៏បានរួមបញ្ចូលនូវសកម្មភាពបែបចូលរួម សម្រាប់អនុវត្តក្នុងវគ្គរៀនសូត្រនីមួយៗ ក៏ដូចជាមានបញ្ចូលនូវព័ត៌មានមូលដ្ឋានសំខាន់ៗដើម្បីធានាថាអ្នកសម្របសម្រួលវគ្គទាំងអស់មានព័ត៌មានត្រឹមត្រូវក្នុងការយកទៅបង្រៀនបន្ត។

# ផ្នែកទី១៖

# សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល



# ចំណុចគួរពិចារណា ដើម្បីឱ្យវគ្គបណ្តុះបណ្តាលដំណើរការប្រកបដោយប្រសិទ្ធភាព

## ក. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ មុនវគ្គបណ្តុះបណ្តាលមកដល់?

ដើម្បីប្រាកដថាវគ្គបណ្តុះបណ្តាល នឹងរៀបចំទៅប្រកបដោយប្រសិទ្ធិភាព ជាពិសេសអ្នកចូលរួមនឹងទទួលបានចំណេះដឹងពេញលេញលើប្រធានបទដែលផ្តល់ឱ្យ អ្នកសម្របសម្រួលអាចអនុវត្តនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

### ១. អ្នកសម្របសម្រួលគួររៀបចំវគ្គបណ្តុះបណ្តាលដោយប្រើប្រាស់លទ្ធផល ឬព័ត៌មានពីការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (Training Need Assessment)



ព័ត៌មានពីការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (TNA) ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃចំណេះដឹងដែលមានស្រាប់ក្នុងពេលបច្ចុប្បន្នរបស់ក្រុមគោលដៅ ក៏ដូចជាប្រើប្រាស់ដើម្បីស្វែងយល់ពីចន្លោះខ្វះខាតនៃចំណេះដឹងរបស់អ្នកចូលរួមដែលត្រូវបំពេញនៅវគ្គបណ្តុះបណ្តាល។ ព័ត៌មានពីការវិភាគតម្រូវការនៃវគ្គបណ្តុះបណ្តាលពិតជាមានសារៈសំខាន់ នៅពេលដែលវគ្គបណ្តុះបណ្តាលរបស់អ្នកមានពេលវេលាកំណត់ ហើយអ្នកត្រូវប្រាកដថាអ្នកអាចជ្រើសរើសព័ត៌មាន/មេរៀនដែលត្រូវជាមួយក្រុមគោលដៅរបស់អ្នកបានល្អ។

### ២. អ្នកសម្របសម្រួលត្រូវកំណត់រយៈពេលនៃវគ្គបណ្តុះបណ្តាលឱ្យបានសមស្រប៖



តាមរយៈការប្រើប្រាស់លទ្ធផលពីការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (TNA) អ្នកសម្របសម្រួលវគ្គនឹងអាចជ្រើសរើសប្រធានបទដែលសមស្របនឹងតម្រូវការរបស់ក្រុមគោលដៅ និងកម្រិតអាទិភាពរបស់ប្រធានបទ ជាពិសេសអាចកំណត់នូវរយៈពេលដ៏សមស្របមួយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលចំពោះមេរៀននៅក្នុងសៀវភៅនេះ អាចត្រូវបានរៀបចំឡើងក្នុងរយៈពេលពីរថ្ងៃពេញ។ ទោះបីជាយ៉ាងនេះក៏ដោយអ្នកសម្របសម្រួលក៏អាចរៀបចំវគ្គបណ្តុះបណ្តាលនេះក្នុងរយៈពេលតែមួយថ្ងៃពេញក៏បានដោយគ្រាន់តែបញ្ចូលនូវមេរៀនត្រឹមតែ ៣ ទៅ ៤ ប៉ុណ្ណោះ ដើម្បីធានាថាក្រុមគោលដៅអាចរៀនសូត្រប្រកបដោយប្រសិទ្ធភាព។

អ្នកសម្របសម្រួលក៏អាចបត់បែនដោយបែងចែកនិងជ្រើសរើសមេរៀនតិចជាងនេះ ឬច្រើនជាងនេះឱ្យសមស្របតាមពេលវេលា ក៏ដូចជាតម្រូវការរបស់អ្នកចូលរួមក៏បាន។ ជាងនេះទៅទៀតអ្នកសម្របសម្រួលក៏អាចរៀបចំជាប្រភេទវគ្គលើកកម្ពស់ការយល់ដឹងរយៈពេលខ្លី/វគ្គបណ្តុះបណ្តាលរយៈពេលកន្លះថ្ងៃតាមតម្រូវការរបស់ក្រុមគោលដៅក៏ដូចជារយៈពេលដែលខ្លួនមាន។

## ៣. អ្នកសម្របសម្រួលគួររៀបចំទុកជាមុនឱ្យបានល្អប្រសើរ មុនវគ្គបណ្តុះបណ្តាល៖



អ្នកសម្របសម្រួលត្រូវប្រាកដថា ខ្លួនបានរៀបចំមេរៀន និងព័ត៌មានដែលត្រូវយកទៅបង្រៀនរួចជាស្រេចមុនវគ្គបណ្តុះបណ្តាល ជាពិសេសគឺត្រូវមានចំណេះដឹងច្បាស់លាស់ទៅលើប្រធានបទទាំងនោះ។ លើសពីនេះទៅទៀត អ្នកក៏ត្រូវធានាថាមេរៀនទាំងនោះបានធ្វើបច្ចុប្បន្នភាព និងស្របតាមនិន្នាការថ្មីៗ។

## ៤. អ្នកសម្របសម្រួលគួរតែកត់ត្រាទុកនូវព័ត៌មានដែលមិនអាចដាក់បញ្ចូលក្នុងវគ្គបណ្តុះបណ្តាល៖



វាពិតជាមានសារៈសំខាន់ណាស់ ដែលអ្នកសម្របសម្រួលយល់ច្បាស់ពីអ្វីដែលខ្លួននឹងនិយាយកំឡុងវគ្គបណ្តុះបណ្តាល ហើយវាក៏សំខាន់ផងដែរនៅពេលអ្នកសម្របសម្រួលមានព័ត៌មានគ្រប់គ្រាន់ពីអ្វីដែលមិនបានដាក់បញ្ចូលក្នុងប្រធានបទ។ ដោយសារកត្តាពេលវេលា អ្នកសម្របសម្រួលប្រហែលជាមិនអាចផ្តល់នូវគ្រប់មេរៀនទាំងអស់ក្នុងវគ្គបណ្តុះបណ្តាលបានទេ ដូចនេះការដែលបានដឹងថាប្រធានបទអ្វីដែលមិនអាចដាក់បញ្ចូលបានក្នុងវគ្គបណ្តុះបណ្តាល នឹងអាចឱ្យអ្នកសម្របសម្រួលប្រាប់ដល់អ្នកចូលរួមក្នុងការស្វែងរកចំណេះដឹង/ព័ត៌មានបន្ថែមលើប្រធានបទដែលមិនអាចពិភាក្សាបាននោះ។

## ៥. អ្នកសម្របសម្រួលត្រូវប្រាកដថាបានដឹងពីប្រធានបទដែលអ្នកសម្របសម្រួលដទៃទៀតនឹងធ្វើបទបង្ហាញ៖



ចំណុចនេះ គួរតែត្រូវយកចិត្តទុកដាក់ប្រសិនបើអ្នកនឹងសម្របសម្រួលវគ្គបណ្តុះបណ្តាលជាមួយអ្នកសម្របសម្រួលដទៃទៀត។ អ្នកមិនត្រឹមតែត្រូវដឹងពីខ្លឹមសារនៃប្រធានបទរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវដឹងថាតើអ្នកផ្សេងទៀតនឹងនិយាយអំពីអ្វីផងដែរ។ ការដឹងថាមានព័ត៌មានអ្វីខ្លះដែលនឹងត្រូវធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលទាំងមូល នឹងអាចជួយអ្នកឱ្យកំណត់បានពីលំហូរព័ត៌មានដែលត្រូវបង្ហាញ ជាពិសេសនឹងអាចកំណត់ថាព័ត៌មានណាដែលអ្នកមិនគួរលំអិត ប្រសិនបើព័ត៌មាននោះនឹងត្រូវបង្ហាញ ឬបង្រៀនដោយអ្នកសម្របសម្រួលដទៃទៀត។

## ៦. អ្នកសម្របសម្រួលត្រូវប្រាកដថាបានជ្រើសរើសទីកន្លែងដែលសមស្របសម្រាប់វគ្គបណ្តុះបណ្តាល ហើយរៀបចំរបៀបអង្គុយបានល្អបំផុត៖



អ្នកសម្របសម្រួលត្រូវដឹងថា ទាំងទីកន្លែងនិងរបៀបអង្គុយ សុទ្ធតែអាចជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការសិក្សារបស់អ្នកចូលរួម។ ទីកន្លែងសម្រាប់វគ្គរៀនសូត្រគួរតែមានទំហំធំល្មម មានគម្លាតសុវត្ថិភាព និងអាចផ្ទុកអ្នកចូលរួមបានគ្រប់គ្រាន់ ប៉ុន្តែមិនគួរធំពេកទេ ព្រោះដើម្បីធានាថាការពិភាក្សា និងការចូលរួមនានាអាចធ្វើទៅបាន។ មិនត្រឹមតែប៉ុណ្ណោះ ទីកន្លែងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល គួរតែបំពាក់នូវឧបករណ៍ផ្សេងៗឱ្យបានពេញលេញនិងអាចឱ្យអ្នកចូលរួមដែលមានពិការភាពអាចប្រើប្រាស់បានយ៉ាងងាយស្រួល។

របៀបនៃការអង្គុយរបស់អ្នកចូលរួម គួរតែរៀបចំអាស្រ័យលើប្រភេទនៃវគ្គបណ្តុះបណ្តាលនិងសកម្មភាពនៃវគ្គនីមួយៗ។ ជាឧទាហរណ៍ សកម្មភាពបែបពិភាក្សា គួរត្រូវរៀបចំរបៀបនៃការអង្គុយជារង្វង់ ឬជាអក្សរ U។ ការអង្គុយនៅតាមតុរៀងខ្លួន ឬការអង្គុយជាលក្ខណៈថ្នាក់រៀន គួរតែត្រូវជៀសវាងសម្រាប់ប្រភេទវគ្គបណ្តុះបណ្តាលទាំងអស់នៅក្នុងសៀវភៅណែនាំនេះ ព្រោះការអង្គុយប្រភេទនេះមិនអាចឱ្យអ្នកចូលរួមចល័ត ឬមានទំនាក់ទំនងជាមួយអ្នកចូលរួមផ្សេងទៀតបានងាយស្រួលឡើយ។

## ៧. អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលត្រូវតែមានភាពងាយស្រួលក្នុងការពិភាក្សាពីប្រធានបទ៖



ការពិភាក្សាអំពីបញ្ហាទាក់ទងនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ អាចជាការពិបាកសម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ព្រោះវាជាការនិយាយអំពីបញ្ហាងាយរសើប។ ទោះជាយ៉ាងនេះក្តី អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលចាំបាច់ត្រូវតែមានភាពងាយស្រួលក្នុងការពិភាក្សាពីប្រធានបទទាំងនេះដោយបើកចំហ។ ផ្នែកមួយនៃការងារប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺការបំបាត់អារម្មណ៍ខ្មាស់អៀន និងហ៊ាននិយាយពីបញ្ហា ដូចនេះតាមរយៈមេរៀននៅក្នុងសៀវភៅនេះ អ្នកនឹងធ្វើជាគំរូដល់អ្នកដទៃទៀតក្នុងការនិយាយពីបញ្ហានៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដោយបើកចំហ និងគ្មានភាពខ្មាស់អៀន។

### ៨. អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ត្រូវជម្រុញឱ្យមានការចូលរួមច្រើនពីសិក្ខាកាម ក្នុងវគ្គបណ្តុះបណ្តាល ឬប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម៖



វិធីសាស្ត្របង្រៀន និងរៀនសូត្របែបអន្តរកម្ម ឬបែបចូលរួម ត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅណែនាំនេះដែលអាចឱ្យអ្នកអាន ប្រើប្រាស់ដើម្បីបំផុសគំនិត និងជាឧបករណ៍ក្នុងការចែករំលែកចំណេះដឹងបន្តទៅអ្នកដទៃទៀតប្រកបដោយប្រសិទ្ធភាព។ ការរៀនសូត្របែបសកម្ម អាចជម្រុញឱ្យអ្នកចូលរួមបង្កើនការគិតគូរ និងបង្កើនសមត្ថភាពដោះស្រាយបញ្ហា ក៏ដូចជាជម្រុញអ្នកចូលរួមឱ្យមានទំនាក់ទំនងជាមួយគ្នា ជាពិសេសគឺផ្តល់នូវមូលដ្ឋានដ៏មានប្រសិទ្ធភាពសម្រាប់ការបណ្តុះបណ្តាលនិងការកសាងជំនាញ។ ការជម្រុញឱ្យមានការចូលរួមពីសិក្ខាកាមអាចធ្វើឡើងតាមរយៈការប្រើប្រាស់ហ្គេមកំសាន្ត សកម្មភាពជាក្រុម ការសម្តែងតួ ការពិភាក្សា និងតាមរយៈសកម្មភាពជាច្រើនផ្សេងទៀត។

## ខ. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ ក្នុងអំឡុងវគ្គបណ្តុះបណ្តាល?

### ១. ការធ្វើតេស្តសាកល្បងចំណេះដឹងមុនវគ្គ និងក្រោយវគ្គ



ការបង្កើតឱ្យមាននូវតេស្តសាកល្បងចំណេះដឹងមុនវគ្គ និងក្រោយវគ្គបណ្តុះបណ្តាល គឺជាវិធីដ៏ល្អមួយសម្រាប់វាស់វែងនូវចំណេះដឹងដែលពួកគេទទួលបាន ក៏ដូចជាជួយបង្កើនដំណើរការសិក្សារៀនសូត្ររបស់ពួកគេទៀតផង។ ក្នុងដំណើរការរៀនសូត្រ អ្នកចូលរួមអាចគិតអំពីសំណួរដែលពួកគេត្រូវបានសួរកាលពីពេលធ្វើតេស្តមុនវគ្គ។ អ្នកសម្របសម្រួលគួរចងចាំដែរថា សំណួរក្នុងតេស្តសាកល្បងទាំងមុនវគ្គ និងក្រោយវគ្គត្រូវតែដូចគ្នា និងផ្តោតលើប្រធានបទដែលនឹងត្រូវយកមកបង្រៀនក្នុងវគ្គបណ្តុះបណ្តាល។ ម៉្យាងវិញទៀតអ្នកសម្របសម្រួល ក៏ត្រូវជៀសវាងការប្រើតេស្តដដែលៗជាមួយក្រុមគោលដៅផ្សេងគ្នា។ តេស្តសាកល្បងមុនវគ្គ និងក្រោយវគ្គ គួរតែជាប្រភេទសំនួរបែបជ្រើសរើស និងគួរតែចំណាយពេលក្នុងការធ្វើមិនឱ្យលើសពី ១០នាទីឡើយ។

## ២. របៀបនៃការចាប់ផ្តើមវគ្គ និងការស្វាគមន៍



វគ្គបណ្តុះបណ្តាល គួរតែចាប់ផ្តើមដោយការណែនាំអំពីប្រធានបទនិងការស្វាគមន៍ដល់អ្នកចូលរួម។ បន្ទាប់ពីបានណែនាំនូវប្រធានបទដែលអ្នកនឹងត្រូវធ្វើបទបង្ហាញពេញមួយថ្ងៃ អ្នកសម្របសម្រួលគួរផ្តល់ពេលវេលាសមរម្យមួយដល់អ្នកចូលរួមដើម្បីឱ្យពួកគេអាចណែនាំខ្លួនឯង។ សកម្មភាពនេះ ត្រូវបានចាត់ទុកជាវិធីមួយដែលអាចឱ្យអ្នកចូលរួមស្គាល់គ្នាទៅវិញទៅមក និងអាចឱ្យអ្នកសម្របសម្រួលដឹងពីសាវតារបស់ពួកគេ តែសកម្មភាពនេះ មិនគួរធ្វើឡើងក្នុងរយៈពេលយូរពេកទេ។

ការអង្គុយរាងជារង្វង់ ជារបៀបអង្គុយដែលល្អបំផុតសម្រាប់ការណែនាំខ្លួន។ អ្នកចូលរួមទាំងអស់ អាចអង្គុយទល់មុខគ្នាក្នុងគម្លាតសមស្របណាមួយ ហើយអាចចាប់ផ្តើមណែនាំខ្លួនដោយប្រាប់ពីឈ្មោះ ទីកន្លែងរស់នៅ សាលារៀន/អង្គការ របស់ពួកគេ និងមូលហេតុអ្វីដែលនាំពួកគេឱ្យមកចូលរួមវគ្គបណ្តុះបណ្តាលនេះ។ អ្នកសម្របសម្រួល ក៏អាចបញ្ចូលនូវល្បែងកំសាន្តណាមួយបន្ថែមដើម្បីទទួលបានលទ្ធផលល្អប្រសើរ។



ក្នុងអំឡុងពេលចាប់ផ្តើម អ្នកសម្របសម្រួលក៏គួរតែបញ្ចូលនូវចំនុចសំខាន់ៗមួយចំនួនរួមមាន៖

### ក. ការពិភាក្សាអំពីភាពរសើបនៃប្រធានបទមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល៖

អ្នកសម្របសម្រួលត្រូវប្រាកដថា បានប្រាប់ដល់អ្នកចូលរួមអំពីលក្ខណៈរសើបនៃប្រធានបទ ហើយវាអាចពិបាកសម្រាប់អ្នកចូលរួមមួយចំនួនក្នុងការស្តាប់ ឬក៏បង្កឱ្យមានការប៉ះពាល់ផ្លូវអារម្មណ៍ជាដើម។ ប្រសិនបើអ្នកចូលរួម មានអារម្មណ៍មិនស្រួល ឬមានអារម្មណ៍ថាពួកគេមានអ្វីផ្ទាល់ខ្លួនដើម្បីចែករំលែក សូមឱ្យពួកគេដឹងថាពួកគេអាចមកនិយាយជាមួយអ្នកបន្ទាប់ពីវគ្គបណ្តុះបណ្តាល ដើម្បីធានាថាពួកគេអាចទទួលបានការណែនាំបន្ថែម។

### ខ. ការកំណត់វិន័យជារួម (Ground Rule) មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល៖

វិន័យរួមក្នុងវគ្គបណ្តុះបណ្តាល បង្កើតឡើងក្នុងគោលបំណងកំណត់នូវឥរិយាបថដែលរំពឹងទុករបស់អ្នកចូលរួមទាំងអស់ក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល និងធ្វើឱ្យប្រាកដថាវគ្គបណ្តុះបណ្តាលនឹងក្លាយជាបរិយាកាសដែលមិនមានការវិនិច្ឆ័យ ហើយសិក្ខាកាមដែលចូលរួម អាចបញ្ចេញយោបល់ដោយគ្មានភាពភ័យខ្លាច ឬបារម្ភថាគំនិតរបស់ពួកគេមិនអាចទទួលយកបាន។ ចំណុចដែលអ្នកសម្របសម្រួល គួរលើកឡើងដើម្បីកំណត់ជាវិន័យរួម រួមមាន ការគោរពអ្នកដទៃនៅពេលពួកគេនិយាយ ការមិនសើចចំអកចំពោះចម្លើយរបស់អ្នកណាម្នាក់ ការមិនបង្ខំនរណាម្នាក់ឱ្យនិយាយ ប្រសិនបើពួកគេមិនចង់ ការមិនវិនិច្ឆ័យអ្នកដទៃ ជាពិសេសការរក្សាភាពឯកជនរបស់គ្នាទៅវិញទៅមក។

### គ. កម្រិតនៃការរំពឹងទុករបស់អ្នកចូលរួម៖

ក្នុងអំឡុងពេលចាប់ផ្តើមនេះ អ្នកសម្របសម្រួលក៏ត្រូវប្រាកដថាការរំពឹងទុករបស់អ្នកចូលរួម បានផ្តោតលើអ្វីដែលនឹងត្រូវពិភាក្សា។ សំណួរដែលអ្នកសម្របសម្រួលអាចសួរបានរួមមាន៖ តើអ្នករំពឹងថានឹងទទួលបានអ្វីខ្លះពីវគ្គបណ្តុះបណ្តាលនេះ? តើអ្នកសង្ឃឹមថានឹងចែករំលែកអ្វីខ្លះជាមួយអ្នកដទៃបន្ទាប់ពីអ្នកបានចូលរួមវគ្គបណ្តុះបណ្តាលនេះ? ជាចុងក្រោយ អ្នកសម្របសម្រួលត្រូវលើកយកប្រធានបទដែលនឹងត្រូវពិភាក្សាពេញមួយថ្ងៃ មកពន្យល់ពីគោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលដែលនឹងត្រូវផ្តល់ជូន។

# ៣. សកម្មភាពសម្របសម្រួលសំខាន់ៗ

## សកម្មភាពជាក្រុម

សកម្មភាពជាក្រុមអាចអនុវត្តបាននៅក្នុងវគ្គនីមួយៗនៃសៀវភៅណែនាំនេះ ។វាជាផ្នែកសំខាន់ក្នុងដំណើរការសិក្សារបស់សិក្ខាកាម និងជាវិធីរៀនសូត្រដែលសិក្ខាកាមអាចសហការគ្នា បំផុសគំនិតច្នៃប្រឌិត និងអនុវត្តវិធីផ្សេងៗដែលពួកគេបានទទួលតាមរយៈវគ្គបណ្តុះបណ្តាល ។

ក្នុងកំឡុងពេលធ្វើសកម្មភាពជាក្រុម អ្នកចូលរួមជាទូទៅត្រូវបានបែងចែកជាក្រុមតូចៗ ដើម្បីឱ្យពួកគេអាចទំនាក់ទំនងគ្នាប្រកបដោយប្រសិទ្ធភាព និងសហការជាមួយគ្នាបានយ៉ាងល្អ ជាពិសេសគឺអាចជម្រុញឱ្យអ្នកចូលរួមដែលមានភាពអៀនខ្មាសច្រើនអាចសម្របខ្លួនបាន ។

សកម្មភាពក្រុមខ្លះ ត្រូវការការពិភាក្សា និងសរសេរនូវគំនិតដោយប្រើប្រាស់ក្រដាសផ្ទាំងធំ ( Flip Chart ) ដែលតម្រូវឱ្យសមាជិកក្រុមគិតអំពីព័ត៌មានចាំបាច់បំផុតដែលត្រូវសរសេរ និងបង្ហាញ ហើយត្រូវបង្ហាញយ៉ាងច្បាស់លាស់បំផុតដើម្បីឱ្យអ្នកដទៃទៀតអាចយល់បាន ។ វិធិសាស្ត្រនេះពិតជាមានប្រសិទ្ធភាពជាពិសេសក្នុងពេលបណ្តុះបណ្តាលដល់គ្រូបង្គោល ព្រោះសិក្ខាកាមអាចបង្កើនបច្ចេកទេស និងជំនាញធ្វើបទបង្ហាញរបស់ពួកគេតាមរយៈសកម្មភាពក្រុមប្រភេទនេះ ។

អ្នកសម្របសម្រួល ក៏ត្រូវប្រាកដថាក្រុមនីមួយៗបានយល់ពីអ្វីដែលអ្នកសម្របសម្រួលរំពឹងទុកពីពួកគេ ហើយសមាជិកក្រុមនីមួយៗសហការជាមួយគ្នាបានល្អ ធ្វើយ៉ាងណាចៀសវាងកុំឱ្យមានតែមនុស្សពីរបីនាក់ចូលរួមដឹកនាំការសន្ទនា តាមរយៈការលើកទឹកចិត្តឱ្យអ្នកដែលនៅសេសសល់ចែករំលែកគំនិតរបស់ពួកគេជាមួយអ្នកដទៃទៀត ។





### ការពិភាក្សាក្រុម៖

ការពិភាក្សាក្រុម ជាវិធីសាស្ត្រមួយដែលត្រូវបានប្រើសម្រាប់ជម្រុញឱ្យអ្នកចូលរួមអាចចែករំលែកនូវគំនិតរបស់ពួកគេ បង្កើនសមត្ថភាពក្នុងការគិតពិចារណា និងជួយពួកគេឱ្យយល់ពីប្រធានបទបានស៊ីជម្រៅ។ វិធីសាស្ត្រនេះ ក៏អាចជួយដល់អ្នកសម្របសម្រួលវគ្គក្នុងនាមជាគ្រូបណ្តុះបណ្តាល អាចមើលឃើញថាតើសិក្ខាកាមបានរៀនសូត្រ និងបានយល់ដឹងពីវគ្គបណ្តុះបណ្តាលបានកម្រិតណា ហើយព័ត៌មានណាដែលត្រូវពន្យល់បន្ថែម។

នៅពេលធ្វើការពិភាក្សាជាក្រុម អ្នកសម្របសម្រួលគួរតែរក្សាភាពអព្យាក្រឹត ហើយតួនាទីរបស់អ្នកសម្របសម្រួលគឺធ្វើយ៉ាងណាជម្រុញឱ្យសិក្ខាកាមបញ្ចេញមតិយោបល់របស់ពួកគេឱ្យបានច្រើន និងលើកទឹកចិត្តឱ្យមានការចូលរួម ចៀសវាងការផ្តល់គំនិតផ្ទាល់ខ្លួនរបស់អ្នកសម្របសម្រួល។

អ្នកសម្របសម្រួលក៏អាចបង្កើតជាលក្ខខណ្ឌដែលអាចឱ្យក្រុមនីមួយៗធ្វើការគិតពិភាក្សា និងសម្រេចចិត្តរួមគ្នា។ ក្រៅពីនោះ អ្នកសម្របសម្រួល ក៏អាចសួរជាសំណួរបើក ដើម្បីជួយបំផុសគំនិតឱ្យសិក្ខាកាមបញ្ចេញទស្សនៈរបស់ពួកគេ។ ជាងនេះទៅទៀត អ្នកសម្របសម្រួលគួរគប្បីស្តាប់ឱ្យបានម៉ត់ចត់នូវអ្វីដែលសិក្ខាកាមបាននិយាយដើម្បីដឹងថាតើពេលណាដែលគួរកាត់ ប្រសិនបើសិក្ខាកាមនិយាយចាកឆ្ងាយពីប្រធានបទ។ ចុងក្រោយ អ្នកសម្របសម្រួលអាចបិទបញ្ចប់ការពិភាក្សា ដោយសង្ខេបនូវចំណុចសំខាន់ៗដែលត្រូវបានលើកឡើងដោយសិក្ខាកាម។



### ការសំដែងតួ៖

ការសំដែងតួជាវិធីត្រាប់តាមស្ថានភាពជីវិតពិត ហើយវិធីសាស្ត្របង្រៀនដោយប្រើប្រាស់ការសម្តែងតួ អាចជួយដល់ដំណើរការសិក្សារៀនសូត្ររបស់សិក្ខាកាមជាពិសេសអាចឱ្យពួកគេទទួលបាននូវឧទាហរណ៍ជាក់ស្តែងដែលស្រដៀងទៅនឹងស្ថានភាពក្នុងជីវិតប្រចាំថ្ងៃ។ លើសពីនេះទៅទៀត វិធីសាស្ត្រប្រភេទនេះអាចឱ្យសិក្ខាកាមអនុវត្តនូវចំណេះដឹងដែលពួកគេបានទទួលក្នុងបរិយាកាសមានសុវត្ថិភាព និងទំនុកចិត្តប្រសិនបើពួកគេជួបនូវស្ថានភាពដែលកើតឡើងណាមួយ។

ក្នុងអំឡុងពេលដែលសិក្ខាកាមចូលរួមសម្តែងតួ អ្នកសម្របសម្រួលមិនគួរកាត់ពួកគេឡើយ និងត្រូវរង់ចាំរហូតដល់ពេលដែលឈុតសម្តែងនីមួយៗត្រូវបានបញ្ចប់ ទើបផ្តល់មតិកែលម្អភ្លាមៗយោងតាមចំណុចជាក់លាក់នៃវគ្គនីមួយៗ។ អ្នកសម្របសម្រួលក៏គួរតែអនុញ្ញាតឱ្យមានការពិភាក្សាពីរបីនាទីជាមួយក្រុមដែលនៅសេសសល់អំពីអ្វីដែលក្រុមដទៃទៀតបានសម្តែងក្នុងឈុតឆាកនីមួយៗ។ សំនួរដែលអាចសួរដើម្បីបំផុសនូវការពិភាក្សារួមមាន៖ តើចំណុចណាខ្លះ ដែលអ្នកគិតថាសិក្ខាកាម ក និង



សិក្ខាកាម ៥ សម្តែងជាមួយគ្នាបានល្អ? តើចំណុចអ្វីដែលអ្នកគិតថាពួកគេអាចធ្វើបានផ្សេងពីនេះទៀត?

នៅក្នុងសៀវភៅណែនាំនេះ សេណារីយ៉ូមួយចំនួនត្រូវបានផ្តល់ជូនសម្រាប់ប្រើប្រាស់ក្នុងការសម្តែងតួ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកសម្របសម្រួលក៏អាចកែច្នៃ និងផ្លាស់ប្តូរសេណារីយ៉ូទៅតាមភាពចាំបាច់ជាក់ស្តែង។

បន្ថែមពីលើសកម្មភាពខាងលើ អ្នកក៏អាចស្វែងយល់បន្ថែមអំពីសកម្មភាព Icebreaker ល្បែងថាមពល និងសកម្មភាពបែបឆ្លុះបញ្ចាំងដែលជាជំនួយក្នុងការធ្វើឱ្យសិក្ខាកាមនៅតែចូលរួម និងមិនធុញទ្រាន់។ សកម្មភាពទាំងនេះ អាចបញ្ចូលគ្នា ឬកែច្នៃទៅតាមតម្រូវការនិងការសម្របសម្រួលរបស់គ្រូបណ្តុះបណ្តាល។

## សកម្មភាព Icebreaker

សកម្មភាព Ice breaker ត្រូវបានអនុវត្តច្រើននៅពេលអ្នកចូលរួមណែនាំខ្លួន ព្រោះវិធីនេះអាចជួយអ្នកចូលរួមឱ្យស្គាល់គ្នា និងមានអារម្មណ៍ងាយស្រួលក្នុងការទាក់ទងគ្នាទៅវិញទៅមក។ ជាពិសេសសកម្មភាព Ice breaker រឹតតែមានសារៈសំខាន់ហើយគួរតែត្រូវប្រើមុនពេលពិភាក្សាលើប្រធានបទដែលអ្នកចូលរួមអាចមានអារម្មណ៍ថាខ្មាស់អៀនក្នុងការនិយាយ។





## ក. ល្បែងបោះបាល់

**របៀបលេង៖** សម្ភារៈដែលត្រូវការមានបាល់មួយ។ អ្នកចូលរួមត្រូវឈរជារង្វង់ ហើយអ្នកសម្របសម្រួលត្រូវឱ្យបាល់មួយដល់អ្នកចូលរួមម្នាក់ ដោយឱ្យអ្នកចូលរួមនោះបោះបាល់ទៅមនុស្សម្នាក់ផ្សេងទៀតដោយចៃដន្យ។ អ្នកដែលទទួលបានបាល់ត្រូវស្រែកប្រាប់ឈ្មោះខ្លួនឯង បន្ទាប់មកត្រូវបោះបាល់នោះទៅអ្នកចូលរួមម្នាក់ទៀតដែលមិនទាន់បានទទួលបាល់ ហើយស្រែកប្រាប់ឈ្មោះអ្នកមុនដដែល។ ក្រោយពេលដែលបាល់ត្រូវបានបោះគ្រប់គ្នាហើយ ជុំបន្ទាប់សិក្ខាកាមត្រូវលេងល្បែងនេះតាមលំដាប់ដូចជុំទី១ដែរ តែលើកនេះអ្នកបោះបាល់ត្រូវចងចាំឈ្មោះសិក្ខាកាមបន្ទាប់ដែលបានទទួលបាល់ ហើយហៅឈ្មោះអ្នកបន្ទាប់នោះ។ នៅពេលបញ្ចប់ជុំទី ២ អ្នកលេងនីមួយៗ ត្រូវបង្កើនល្បឿនលេងដោយការហៅឈ្មោះគ្នា ស្របពេលដែលអ្នកសម្របសម្រួលក៏ត្រូវកំណត់ពេលវេលាផងដែរ។ សកម្មភាពប្រភេទនេះ មិនត្រឹមតែអាចឱ្យអ្នកចូលរួមស្គាល់គ្នាទៅវិញទៅមកនោះទេ តែថែមទាំងអាចឱ្យពួកគេទទួលបាននូវភាពសប្បាយរីករាយទៀតផង។



## ខ. ល្បែងឈ្មោះ និងគុណនាម

**របៀបលេង៖** អ្នកចូលរួមលេងហ្គេមគ្រប់គ្នា ត្រូវប្រាប់ពីឈ្មោះរបស់ខ្លួន រួចត្រូវបន្ថែមគុណនាមមួយពាក្យភ្ជាប់ជាមួយឈ្មោះរបស់ខ្លួន។ ឧទាហរណ៍៖ ធីតាដ៏ស្រស់ស្អាត ស្រីមុំដ៏រីករាយ បូរ៉ាដ៏សង្ហាជាដើម។

## គ. ល្បែងពាក្យចុងក្រោយ

**របៀបលេង៖** អ្នកចូលរួមលេងដំបូងគេ ត្រូវដើរទៅរកអ្នកចូលរួមមួយផ្សេងទៀត ហើយនិយាយនូវប្រយោគមួយ " ឧទាហរណ៍៖ "អាកាសធាតុក្តៅខ្លាំងណាស់នៅថ្ងៃនេះ។" អ្នកបន្ទាប់ត្រូវជ្រើសរើសមនុស្សម្នាក់បន្តទៀតនៅក្នុងក្រុម ដើម្បីនិយាយប្រយោគថ្មីដោយប្រើពាក្យចុងក្រោយនៃប្រយោគមុន ជាឧទាហរណ៍គឺ "ថ្ងៃនេះខ្ញុំនឹងទៅញ៉ាំភីហ្សា"។ សកម្មភាពប្រភេទនេះ លើកចិត្តឱ្យអ្នកចូលរួមមានទំនាក់ទំនង និងស្តាប់គ្នាទៅវិញទៅមកតាមវិធីបែបសប្បាយរីករាយ និងច្នៃប្រឌិត។

# ល្បែងថាមពល

ល្បែងថាមពល អាចប្រើប្រាស់នៅពេលដែលអ្នកចូលរួមមានភាពនឿយហត់ ឬបាត់បង់ការផ្ដោតអារម្មណ៍ ព្រោះល្បែងប្រភេទនេះធ្វើឱ្យអ្នកចូលរួមមានភាពរីករាយ និងសកម្មជាងមុន។



## ក. ល្បែងថាមពលទី១៖ សកម្មភាពតាមលេខរៀង

ដំបូងអ្នកសម្របសម្រួលត្រូវរៀបចំអ្នកចូលរួមឱ្យឈរជាពីរជួរ និងឈរទល់មុខគ្នា។ អ្នកសម្របសម្រួលត្រូវស្រែកលេខណាមួយដែលតំណាងឱ្យសកម្មភាពដែលបានកំណត់។ ឧទាហរណ៍៖

**# 1** តំណាងឱ្យសកម្មភាពទះដៃ ឬ High-Five ជាមួយអ្នកចូលរួមដែលឈរនៅទល់មុខពួកគេ

**# 2** តំណាងឱ្យសកម្មភាពបង្វិលខ្លួនមួយជុំ

**# 3** តំណាងឱ្យសកម្មភាពលោត

**# 4** តំណាងឱ្យសកម្មភាពប៉ះដី

អ្នកសម្របសម្រួល ត្រូវណែនាំទុកជាមុនពីលេខ និងសកម្មភាពមុនចាប់ផ្ដើមលេងល្បែងថាមពលនេះដើម្បីឱ្យអ្នកចូលរួមលេងដឹងថាលេខមួយណាតំណាងឱ្យសកម្មភាពមួយណា។ អ្នកសម្របសម្រួលក៏អាចស្រែកលេខខុសៗគ្នា ត្រលប់ទៅត្រលប់មក ដើម្បីធ្វើឲ្យអ្នកចូលរួមងាយច្រលំ និងបង្កភាពរីករាយកាន់តែខ្លាំង។



## ខ. ល្បែងថាមពលទី២៖ ល្បែងផ្គររន្ទះ

អ្នកសម្របសម្រួលល្បែងថាមពល ត្រូវប្រាប់អ្នកចូលរួមឱ្យធ្វើសកម្មភាពដូចខ្លួន។ ប្រសិនបើស្រែកថា "ភ្លៀង" នោះត្រូវយកដៃគោះលើតុស្រាលៗដូចភ្លៀងរលឹម ហើយបន្ទាប់មកគោះតុកាន់តែខ្លាំងឡើងៗ ឱ្យដូចភ្លៀងធ្លាក់ខ្លាំង។ បើស្រែកថា "ផ្គរបន្ទោរ" ត្រូវទះដៃដើម្បីបង្កើតជាសំលេងផ្គរលាន់។ អ្នកចូលរួមត្រូវធ្វើបែបនេះពីរ បីដង រហូតដល់ស្ទាត់ក្នុងការធ្វើសកម្មភាពក្នុងពេលដំណាលគ្នា។ ល្បែងបែបនេះគួរប្រើនៅពេលអ្នកចូលរួមអង្គុយនៅតាមតុ ព្រោះងាយស្រួលក្នុងការគោះ ប៉ុន្តែបើអ្នកចូលរួមមិននៅជិតតុទេ ពួកគេក៏អាចគោះភ្លៅខ្លួនឯងជំនួសក៏បាន។

# គ. តើចំណុចអ្វីខ្លះដែលអ្នកសម្របសម្រួលគួររៀបចំ ក្រោយវគ្គបណ្តុះបណ្តាល ?

## សកម្មភាពឆ្លុះបញ្ចាំង

សកម្មភាពឆ្លុះបញ្ចាំង ត្រូវបានយកទៅប្រើនៅចុងនៃវគ្គបណ្តុះបណ្តាល។ សកម្មភាពប្រភេទនេះជួយអ្នកចូលរួមក្នុងការប្រមូលព័ត៌មានចាំបាច់បំផុតដែលពួកគេបានទទួលពីប្រធានបទ/វគ្គបណ្តុះបណ្តាលពេញមួយថ្ងៃ។

### ក. សកម្មភាពឆ្លុះបញ្ចាំងទី១៖ Web of Reflection

**សំភារៈដែលត្រូវការ៖** ហុងអំបោះវែងរុំលើបាល់

**របៀបលេង៖** នៅចុងបញ្ចប់នៃវគ្គ អ្នកចូលរួមត្រូវឈរជារង្វង់ ហើយអ្នកសម្របសម្រួលនឹងសួរអំពីអ្វីដែលពួកគេបានរៀនពេញមួយថ្ងៃ និងគិតថាមានប្រយោជន៍សម្រាប់ពួកគេ ឬពួកគេគិតថានឹងយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ដោយប្រើប្រាស់ហុងអំបោះរុំលើបាល់ អ្នកទីមួយដែលមានបាល់ត្រូវប្រាប់ពីគំនិតរបស់ខ្លួនទៅកាន់ក្រុម ហើយបន្ទាប់មក ត្រូវបោះបាល់នោះទៅអ្នកចូលរួមម្នាក់ទៀតដែលមិនទាន់បាននិយាយនៅឡើយ (ត្រូវកាន់សរសៃអំបោះហើយបោះតែបាល់នោះទេ)ដោយត្រូវប្រាកដថាអ្វីដែលអ្នកមុនបានលើកឡើង នឹងមិនត្រូវនិយាយម្តងទៀតទេ។ វិធីនេះ អាចឱ្យអ្នកចូលរួមផ្តល់នូវគំនិតផ្សេងៗគ្នា ក៏ដូចជាជម្រុញពួកគេឱ្យស្តាប់អ្នកចូលរួមដទៃទៀត។ បន្ទាប់ពីមនុស្សគ្រប់គ្នាបាននិយាយរួចរាល់ហើយ អ្នកទាំងអស់គ្នានឹងមើលឃើញពីសំណាញ់សរសៃអំបោះខ្វាត់ខ្វែងដែលគ្រប់គ្នាកំពុងកាន់។សកម្មភាពបែបនេះបង្ហាញឱ្យឃើញថាសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាល មានទំនាក់ទំនងគ្នាតាមរយៈអ្វីដែលពួកគេបានរៀនសូត្រ។

### ខ. សកម្មភាពឆ្លុះបញ្ចាំងទី២៖ ប្រអប់នៃការឆ្លុះបញ្ចាំង ឬ Cube of Reflection

**សម្ភារៈដែលត្រូវការ៖** គូបមួយ (អ្នកអាចប្រើគ្រាប់ឡុកឡាក់ ឬធ្វើគូបក្រដាសដែលអ្នកអាចសរសេរលេខនៅសងខាង)។

**របៀបលេង៖** អ្នកចូលរួមលេងត្រូវក្រឡុកគ្រាប់ឡុកឡាក់ម្តងម្នាក់។ លេខរៀងនីមួយៗនៃគ្រាប់ឡុកឡាក់ នឹងតំណាងឱ្យចំណុចដូចខាងក្រោម។ ប្រសិនបើក្រឡុកចំលេខណាមួយ អ្នកចូលរួមត្រូវឆ្លើយនូវសំនួរដូចខាងក្រោម៖

១ = ចំណុចអ្វីដែលអ្នកចងចាំជាងគេ
២ = ចំណុចអ្វីដែលអ្នកយល់ថាអ្នកមិនធ្លាប់ធ្វើពីមុន
៣ = ចំណុចអ្វីដែលអ្នកនឹងអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក
៤ = ចំណុចអ្វីដែលធ្វើឱ្យអ្នកយកមកគិត
៥ = ចំណុចអ្វីដែលអ្នកនឹងយកទៅចែករំលែកជាមួយអ្នកដទៃ
៦ = ចំណុចអ្វីដែលអ្នកគិតថាមានសារៈសំខាន់

## ការប្រើប្រាស់ទម្រង់វាយតម្លៃ

អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ត្រូវតែធ្វើការវាយតម្លៃការបណ្តុះបណ្តាលរបស់ពួកគេដើម្បីប្រាកដថាវគ្គនោះមានប្រសិទ្ធភាព និងសម្រេចដូចលទ្ធផលរំពឹងទុក។ នៅក្នុង**ឧបសម្ព័ន្ធ១** អ្នកនឹងឃើញគំរូនៃទម្រង់វាយតម្លៃដែលត្រូវប្រើប្រាស់នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ ទម្រង់វាយតម្លៃ គួរតែរួមបញ្ចូលនូវការវាយតម្លៃចំពោះអ្នកសម្របសម្រួល ការវាយតម្លៃចំពោះសម្ភារៈដែលបានផ្តល់ជូន និងវាយតម្លៃថាតើវគ្គរៀនសូត្រនេះបានឆ្លើយតបតាមការរំពឹងទុករបស់អ្នកចូលរួមដែរឬទេ។ អ្នកសម្របសម្រួលវគ្គត្រូវប្រាកដថាបានវិភាគលទ្ធផលនៃទម្រង់វាយតម្លៃ ហើយធ្វើការផ្លាស់ប្តូរនិងកែសម្រួលសម្រាប់វគ្គបណ្តុះបណ្តាលក្រោយៗទៀត។

## ការផ្តល់ជូនវិញ្ញាបនបត្រ

វិញ្ញាបនបត្របញ្ចប់វគ្គ គួរតែត្រូវផ្តល់ជូនអ្នកចូលរួមនៅពេលពួកគេបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ។ វិញ្ញាបនបត្របញ្ជាក់ពីសមិទ្ធិផលរបស់អ្នកចូលរួម ក៏ដូចជាពង្រឹងឆន្ទៈរបស់ពួកគេក្នុងការចែករំលែក នូវអ្វីដែលពួកគេបានរៀនជាមួយអ្នកដទៃ។ នៅក្នុង**ឧបសម្ព័ន្ធ២** អ្នកនឹងឃើញគំរូវិញ្ញាបនបត្រដែលប្រើប្រាស់ដោយអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលរបស់អង្គការសកម្មភាពដើម្បីកុមារ។ ប្រសិនបើអ្នកមានគម្រោងរៀបចំវគ្គបណ្តុះបណ្តាលណាមួយ បើទោះបីជាមិនមែនវគ្គបណ្តុះបណ្តាលបន្តនៃសកម្មភាពគម្រោងរបស់អង្គការសកម្មភាពដើម្បីកុមារក៏ដោយ អ្នកក៏អាចប្រើប្រាស់គំរូវិញ្ញាបនបត្រនេះជាឯកសារយោងនិងធ្វើការផ្លាស់ប្តូរទៅតាមភាពចាំបាច់របស់អ្នកក៏បាន។



# ផ្នែកទី២៖
# ខ្លឹមសារលម្អិតនៃវគ្គបណ្តុះបណ្តាល



# ជំពូក១៖

## ការស្វែងយល់ពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ



នៅក្នុងជំពូក១នេះ អ្នកនឹងបានរៀនសូត្រនូវមេរៀនសំខាន់ៗចំនួនពីរផ្សេងគ្នាដែលក្នុងនោះរួមមាន មេរៀនទី១៖ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងមេរៀនទី២៖ ការស្វែងយល់ថានរណាជា ជនល្មើសផ្លូវភេទលើកុមារ និងអ្វីជាវិធីដែលពួកគេប្រើប្រាស់។ នៅក្នុងមេរៀននីមួយៗ អ្នកនឹងបានយល់ពីសារគន្លឹះសំខាន់ដូចខាងក្រោម៖

# គំនិតសំខាន់នៃមេរៀនទី១

១. ការអប់រំបន្ថែមអំពីការព្រមព្រៀងផ្នែកផ្លូវភេទ (Sexual Consent) ពិតជាមានសារសំខាន់ណាស់ចំពោះក្មេងជំទង់ និងមនុស្សពេញវ័យ។ ការព្រមព្រៀងខាងផ្នែកផ្លូវភេទ កើតឡើងនៅពេលដែលដៃគូ បានផ្តល់ការយល់ព្រមពេញលេញ ក្នុងការចូលរួមសកម្មភាពផ្លូវភេទ។ តាមបញ្ញត្តិច្បាប់នៅកម្ពុជា នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ មានន័យថា ច្បាប់បានផ្តល់សិទ្ធិ និងសេរីភាពដល់អនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើង អាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរួមភេទបាន។ ផ្ទុយទៅវិញ ប្រសិនបើជនណាមួយធ្វើការរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ នោះនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ជាងនេះទៅទៀត បើយោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទត្រង់មាត្រាទី៣៤ ក៏បានបញ្ជាក់ដែរថា ជនណារួមភេទ ឬធ្វើអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទជាមួយអនីតិជន (ជនដែលមានអាយុក្រោម ១៨ឆ្នាំ) ដោយផ្តល់ ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬទៅឱ្យអន្តរការី ឪពុកម្តាយ អាណាព្យាបាល ឬជនដទៃទៀត ត្រូវផ្តន្ទាទោសទៅតាមផ្លូវច្បាប់ បើទោះបីជាមានការព្រមព្រៀងខាងផ្នែកផ្លូវភេទក៏ដោយ។

២. អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (Child Sexual Abuse and Exploitation-CSAE) រាប់បញ្ចូលទាំងការប៉ះពាល់ផ្ទាល់ និងការមិនប៉ះពាល់ផ្ទាល់រវាងជនល្មើសទៅលើកុមារ ដូចជាការថតរូប/វីដេអូអាសអាភាសរបស់កុមារ ឬការថតរូប/វីដេអូកុមារក្នុងស្ថានភាពផ្លូវភេទ ឬផ្តោតលើកេរភេទ ការផ្សាយផ្ទាល់ពីសកម្មភាពផ្លូវភេទ ការបង្ហាញឱ្យកុមារមើលឃើញនូវរូបភាពបែបអាសអាភាស ការប៉ះពាល់ស្ទាបអង្អែលកុមារក្នុងចេតនាផ្លូវភេទ ការបៀតបៀនផ្លូវភេទកុមារ ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមរយៈពេស្យាចារកុមារ ក៏ដូចជាការរួមភេទជាដើម។

៣. ទាំងកុមារា និងកុមារី សុទ្ធតែអាចក្លាយជាជនរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ដូចនេះ វាពិតជាចាំបាច់ណាស់ ដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀតដល់កុមារាដែលរងគ្រោះពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដោយហេតុថាការរងគ្រោះរបស់ពួកគេភាគច្រើនមិនត្រូវបានដឹង ឬទទួលបានការគាំទ្រ។

## គំនិតសំខាន់នៃមេរៀនទី២

១. យើងមិនអាចកំណត់ថា នរណាម្នាក់ជាជនល្មើសផ្លូវភេទលើកុមារ តាមរយៈភេទ អាយុ សញ្ជាតិ ឬសាវតារបស់គេបានឡើយ។ ជនល្មើសផ្លូវភេទលើកុមារ អាចជានរណាម្នាក់ មិនថាពួកគេជាមនុស្សចាស់ ឬក្មេង ជាប្រុសឬស្រី ជាជនដែលកុមារស្គាល់ ឬមិនស្គាល់ ជាជនបរទេស ឬជាមនុស្សដែលរស់នៅក្នុងស្រុក។

២. ជារឿយៗ ជនល្មើសផ្លូវភេទលើកុមារ ប្រើប្រាស់វិធីល្បួងលោម និងមធ្យោបាយផ្សេងៗដើម្បីទទួលបានការទុកចិត្តពីកុមារ គ្រួសារ ឬសហគមន៍ទាំងមូល មុននឹងឈានដល់ការរំលោភបំពានផ្លូវភេទ។ ជនល្មើសទាំងនោះ ក៏អាចស្វែងរកកុមារ នៅក្នុងគ្រួសារ/សហគមន៍ នៅតាមដងផ្លូវ ឬទីសាធារណៈ នៅតាមកន្លែងកំសាន្តនានា នៅតាមស្ថាប័ន ជាពិសេសនៅតាមប្រព័ន្ធអនឡាញ។

៣. ការល្បួងលោម គឺជាដំណើរការនៃការកសាងទំនុកចិត្តជាមួយកុមារ គ្រួសារ ឬសហគមន៍ទាំងមូល មុននឹងឈានដល់ការរំលោភបំពានផ្លូវភេទលើកុមារ។ ការល្បួងលោមអាចធ្វើឡើងក្នុងដំណាក់កាលផ្សេងៗគ្នាដូចជា ការដាក់គោលដៅលើកុមារ ការទទួលបាននូវទំនុកចិត្ត ការបំពេញនូវតម្រូវការ ការបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ និងការរក្សាការគ្រប់គ្រងលើកុមារជាដើម។

# មេរៀនទី ១ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

## មាតិកាមេរៀនទី១


១.១ ប្រធានបទសំខាន់ៗ

១.២ នរណាជាក្រុមគោលដៅ

១.៣ រយៈពេលនៃមេរៀន

១.៤ សេចក្តីផ្តើម

១.៥ ប្លង់មេរៀន

១.៦ ខ្លឹមសារមេរៀនលម្អិត

ក. តើកុមារ ជានរណា?

ខ. ការព្រមព្រៀងផ្នែកផ្លូវភេទ និងនីតិភាពនៃការរួមភេទ

គ. ការស្វែងយល់ពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ឃ. ជនរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

# មេរៀនទី ១ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

## ១.១ ប្រធានបទសំខាន់ៗ

- ការព្រមព្រៀងផ្នែកផ្លូវភេទ និងនីតិភាពនៃការរួមភេទ
- អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ជនរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

## ១.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះអំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ១.៣ រយៈពេលនៃមេរៀន

១ ម៉ោង ទៅ ១ម៉ោង១៥នាទី

## ១.៤ សេចក្ដីផ្ដើម



ការយល់ច្រឡំថាការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ សំដៅតែទៅដល់ការរំលោភសេពសន្ថវៈតែមួយមុខ បានបង្កជាឧបសគ្គចម្បងក្នុងការប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា។ នៅក្នុងមេរៀននេះ អ្នកនឹងអាចស្វែងយល់កាន់តែស៊ីជម្រៅពីនិយមន័យនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការយល់ដឹងថាការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទអាចកើតឡើងដោយការប៉ះពាល់ផ្ទាល់ និងការមិនប៉ះពាល់ផ្ទាល់រវាងជនល្មើសនឹងកុមារ ជាពិសេសគឺការយល់ដឹងថាទាំងកុមារា និងកុមារី សុទ្ធតែអាចជាគោលដៅរបស់ជនល្មើស។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាច៖

- កំណត់និយមន័យនៃពាក្យគន្លឹះទាក់ទងនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសការយល់ដឹងពីភាពខុសគ្នារវាងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ
- កំណត់ថាអ្នកណាអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ
- ស្វែងយល់ពីអ្វីជាការព្រមព្រៀងផ្នែកផ្លូវភេទ និងនីតិភាពនៃការរួមភេទ ជាពិសេសការអប់រំបានត្រឹមត្រូវពីការព្រមព្រៀងផ្នែកផ្លូវភេទមានឥទ្ធិពលយ៉ាងដូចម្ដេចខ្លះចំពោះការបង្ការការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

## ១.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្ដើមវគ្គ | ៥នាទី | មុនពេលចាប់ផ្ដើមវគ្គសិក្សា សូមចងចាំថា ពាក្យគន្លឹះខ្លះប្រហែលជាសិក្ខាកាមមួយចំនួនធ្លាប់បានស្គាល់រួចហើយ ដូចនេះអ្នកសម្របសម្រួលអាចចាប់ផ្ដើមមេរៀនទី១ដោយការសួរនូវសំណួរមួយចំនួន ដើម្បីបានយល់ពីកម្រិតចំណេះដឹងដែលមានស្រាប់របស់អ្នកចូលរួម ជាពិសេសដើម្បីដឹងថាផ្នែកណាដែលត្រូវពន្យល់បន្ថែមឱ្យបានច្បាស់លាស់ និងផ្នែកណាដែលគួរពន្យល់ដោយសង្ខេប។ |
| ផ្នែកទី១ | ១០នាទី | **សេចក្តីផ្តើម**<br>ដើម្បីបានយល់ច្បាស់អំពីអ្វីជាការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ អ្នកសម្របសម្រួលត្រូវចាប់ផ្តើមដោយការពន្យល់សង្ខេបថានរណាត្រូវបានចាត់ទុកជាកុមារ បើយោងតាមច្បាប់នៃប្រទេសកម្ពុជា ជាងនេះទៅទៀតគឺការពន្យល់បន្ថែមពីនីតិភាពនៃការរួមភេទ ព្រោះពាក្យគន្លឹះទាំងពីរនេះសុទ្ធតែពាក់ព័ន្ធនឹងការអនុវត្តច្បាប់នៃប្រទេសនីមួយៗ។<br><br>**សំនួរបំផុស៖** តើអ្វីខ្លះ ជាសារៈសំខាន់នៅពេលដែលប្រទេសមួយមានការកំណត់ជាក់លាក់ពីនីតិភាពនៃការរួមភេទ តើការកំណត់បែបនេះ អាចជាយន្តការការពារកុមារបានយ៉ាងដូចម្តេច? |
| ផ្នែកទី២ | ១០នាទី | **សកម្មភាពបំផុស៖** សួរអ្នកចូលរួមថាតើពួកគេអាចពន្យល់ពីភាពខុសគ្នារវាងអ្វីជាការរំលោភបំពានផ្លូវភេទ? និងអ្វីជាការកេងប្រវ័ញ្ចផ្លូវភេទ?<br><br>បន្ទាប់ពីទទួលបានចម្លើយ អ្នកសម្របសម្រួលបង្ហាញនិយមន័យដោយប្រើប្រាស់ស្លាយ ឬក្រដាសផ្ទាំងធំ។<br><br>**សកម្មភាពបំផុស៖** ឱ្យអ្នកចូលរួមកំណត់ពីទម្រង់នៃការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទតាមរយៈការផ្តល់ជាឧទាហរណ៍មួយចំនួន ជាពិសេសអាចកំណត់ពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដែលអាចកើតឡើងដោយការប៉ះពាល់ផ្ទាល់ និងការមិនប៉ះពាល់ផ្ទាល់រវាងជនល្មើសនឹងកុមារ។ |

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី៣ | ១០នាទី | **សកម្មភាពបំផុស៖** សាកសួរអ្នកចូលរួមថាតើនរណា ដែលអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ? តើពួកគេអាចជាកុមារ ឬកុមារី? តើពួកគេអាចមកពីគ្រួសារដែលមានប្រាក់ចំណូលទាប ឬខ្ពស់? តើពួកគេអាចជាកុមារដែលបានទទួលការអប់រំ ឬមិនបាន?<br><br>អ្នកសម្របសម្រួល ផ្តល់ចម្លើយដល់អ្នកចូលរួម៖ បើទោះបីជាមានកត្តាមួយចំនួនដែលអាចបង្កើនភាពងាយរងគ្រោះរបស់កុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ តែកុមារគ្រប់រូបសុទ្ធតែអាចក្លាយជាជនរងគ្រោះ។ អ្នកសម្របសម្រួល អាចផ្តល់ទិន្នន័យស្តីពីចំនួនជនរងគ្រោះជាកុមារា និងកុមារី ជាពិសេសគឺការយល់ច្បាស់ថាកុមារា ក៏អាចក្លាយជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទដូចកុមារីដែរ។ |
| ផ្នែកទី៤ | ២៥ ទៅ ៤០នាទី | **សកម្មភាព ៖ ការសម្របសម្រួលកិច្ចពិភាក្សាក្រុម**<br><br>អ្នកសម្របសម្រួល ត្រូវចែកសិក្ខាកាមជាបីក្រុម ហើយចាត់សិក្ខាកាមម្នាក់ពីក្រុមនីមួយៗ ដើម្បីធ្វើជាអ្នកសម្របសម្រួលក្រុមរបស់ពួកគេ។ អ្នកសម្របសម្រួលដែលត្រូវបានជ្រើសរើសនឹងត្រូវសម្របសម្រួលការពិភាក្សា ក៏ដូចជាកត់ត្រាការពិភាក្សានោះ រួចធ្វើបទបង្ហាញដល់អ្នកចូលរួមដទៃទៀត។<br><br>អ្នកសម្របសម្រួល ត្រូវផ្តល់នូវប្រធានបទសម្រាប់ពិភាក្សា និងសំណួរដល់ក្រុមនីមួយៗ ជាពិសេសជម្រុញសិក្ខាកាមឱ្យចូលរួមបញ្ចេញមតិយោបល់របស់ពួកគេ។<br><br>**ក្រុមទី១៖ ប្រធានបទនៃកិច្ចពិភាក្សាគឺផ្តោតលើការព្រមព្រៀងផ្នែកផ្លូវភេទ**<br><br>**សំណួរសម្រាប់ក្រុម៖** តើការពិភាក្សាអំពីការព្រមព្រៀងផ្នែកផ្លូវភេទតាំងពីវ័យក្មេងអាចរួមចំណែកជួយទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដោយរបៀបណា? តើអ្នកគិតថាអ្វីជាកត្តាសំខាន់បំផុតដែលត្រូវដោះស្រាយទាក់ទងនឹងការព្រមព្រៀងផ្នែកផ្លូវភេទ (ឧទាហរណ៍ កង្វះការយល់ដឹងអំពីបញ្ហាផ្នត់គំនិតវប្បធម៌ចំពោះកុមារា និងកុមារី)? តើអ្នកគិតថាកុមារ និងមនុស្សវ័យក្មេងអាចទទួលបានការអប់រំកាន់តែប្រសើរទាក់ទងនឹងការព្រមព្រៀងផ្នែកផ្លូវភេទដោយរបៀបណា? តើអ្នកអាចចែករំលែកបទពិសោធន៍របស់អ្នកបានទេ ចំពោះការយល់ខុសអំពីអ្វីជាការព្រមព្រៀងផ្នែកផ្លូវភេទ? |

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| | | **ក្រុមទី២៖ ប្រធានបទនៃកិច្ចពិភាក្សាគឺផ្តោតលើភាពខុសគ្នារវាងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ**<br><br>**សំណួរសម្រាប់ក្រុម៖** តើអ្នកបានដឹងកម្រិតណាពីភាពខុសគ្នានៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ? តើការមិនបានយល់ពីភាពខុសគ្នានៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ មានឥទ្ធិពលយ៉ាងដូចម្តេចក្នុងការការពារកុមារ? តើអ្នកគិតថាអ្វីជាវិធីក្នុងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហានេះក្នុងសហគមន៍របស់អ្នក?<br><br>**ក្រុមទី៣៖ ប្រធានបទនៃកិច្ចពិភាក្សាគឺផ្តោតលើនរណាអាចជាជនរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ**<br><br>នៅប្រទេសកម្ពុជា ជំនឿខុសឆ្គងដែលគិតថាក្មេងប្រុសមានភាពរឹងមាំ និងមិនអាចរងគ្រោះពីការរំលោភបំពាន នៅតែជាបញ្ហាចោទ ដែលជាហេតុនាំឱ្យមានករណីជាច្រើននៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារាមិនត្រូវបានរាយការណ៍ ហើយកុមារារងគ្រោះ នៅតែមិនបានទទួលជំនួយដែលពួកគេត្រូវការ។<br><br>**សំណួរសម្រាប់ក្រុម៖** តើការមិនបានដឹងថាកុមារាអាចជាជនរងគ្រោះនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ បានផ្តល់ផលប៉ះពាល់ដល់សុខុមាលភាពរបស់ពួកគេយ៉ាងដូចម្តេច? តើអ្វីជាវិធីល្អបំផុតក្នុងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហានេះ? |

## ១.៦ ខ្លឹមសារមេរៀនលម្អិត



### ក. តើកុមារ ជានរណា?

យោងតាមមាត្រា១នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) បានកំណត់ថា កុមារគឺជា **"បុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ"** លើកលែងតែច្បាប់របស់ប្រទេស ចែងពីអាយុពេញវ័យដែលគេសន្មតហ័សជាង។ បន្ថែមពីនេះ កថាខណ្ឌទី១៧ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានគូសបញ្ជាក់អំពីនិយមន័យនៃពាក្យអនីតិជនថាជា "**បុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ**"។

## ខ. ការព្រមព្រៀងផ្នែកផ្លូវភេទ និងនីតិភាពនៃការរួមភេទ

ការព្រមព្រៀងផ្នែកផ្លូវភេទ កើតឡើងនៅពេលដែលដៃគូ បានផ្តល់ការយល់ព្រមពេញលេញ ក្នុងការចូលរួមសកម្មភាពផ្លូវភេទ។

នៅក្នុងកាលៈទេសៈមួយចំនួន ការព្រមព្រៀងផ្នែកផ្លូវភេទមិនអាចកើតឡើងបានឡើយ ប្រសិនបើបុគ្គលណាម្នាក់មិនមានសមត្ថភាពយល់ព្រមពេញលេញ និងមិនមានសមត្ថភាពព្រមព្រៀងដោយផ្អែកតាមព័ត៌មានគ្រប់គ្រាន់ដូចជា ករណីដែលនរណាម្នាក់អសមត្ថភាពផ្នែកប្រាជ្ញាស្មារតីដោយសារពិការភាព ជនណាម្នាក់ដែលស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ឬគ្រឿងស្រវឹង ឬក្នុងករណីកុមារមិនទាន់ដល់នីតិភាពនៃការរួមភេទ។ ប្រសិនបើជនរងគ្រោះត្រូវបានចាត់ទុកថាបាត់បង់សមត្ថភាពណាមួយដូចរៀបរាប់ខាងលើ បុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពាន មិនអាចរួចខ្លួនដោយសំអាងថាជនរងគ្រោះបានព្រមព្រៀងនោះឡើយ។ ប្រទេសភាគច្រើនក្នុងពិភពលោកបានកំណត់ពីអាយុជាក់លាក់ ជានីតិភាពនៃការរួមភេទ។

ជាក់ស្តែងនៅប្រទេសកម្ពុជា បើយោងតាមមាត្រា២៣៩នៃក្រមព្រហ្មទណ្ឌ បានចែងថានីតិភាពនៃការរួមភេទ ត្រូវបានកំណត់ចាប់ពីអាយុ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ មានន័យថា ច្បាប់បានផ្តល់សិទ្ធិ និងសេរីភាពដល់អនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើង អាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរួមភេទបាន។ ផ្ទុយទៅវិញ ប្រសិនបើជនណាមួយធ្វើការរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ នោះនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជាងនេះទៅទៀត បើយោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទត្រង់មាត្រា៣៤ ក៏បានបញ្ជាក់ដែរថា ជនណារួមភេទ ឬធ្វើអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទជាមួយអនីតិជន (ជនដែលមានអាយុក្រោម ១៨ឆ្នាំ) ដោយផ្តល់ ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬទៅឱ្យអន្តរការី ឪពុកម្តាយ អាណាព្យាបាល ឬជនដទៃទៀត ត្រូវផ្តន្ទាទោសទៅតាមផ្លូវច្បាប់ បើទោះបីជាមានការព្រមព្រៀងខាងផ្នែកផ្លូវភេទក៏ដោយ។

នីតិភាពនៃការរួមភេទគឺសម្រាប់ការពារកុមារពីការរំលោភបំពានផ្លូវភេទ និងការរំលោភសេពសន្ថវៈ។ ជាឧទាហរណ៍ ក្នុងករណីដែលនរណាម្នាក់ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈលើកុមារ ជននោះមិនអាចរួចខ្លួនដោយសំអាងថា កុមាររងគ្រោះបានព្រមព្រៀងនោះឡើយ។ ដូច្នេះសរុបជារួមមក ទិដ្ឋភាពជាមូលដ្ឋាននៃការយល់ដឹងអំពីការរំលោភបំពានផ្លូវភេទលើកុមារ គឺការទទួលបានចំណេះដឹងពីចំណុចដែលមានចែងក្នុងច្បាប់ទាក់ទងនឹងនីតិភាពនៃការរួមភេទ [៧]។

---

[៧] របាយការណ៍សង្ខេបរបស់អង្គការ World Vision ឆ្នាំ២០១៤ ស្តីពី " ផ្លូវភេទ ការរំលោភបំពាន និងកុមារភាព - ការសិក្សាស្រាវជ្រាវអំពីចំណេះដឹង ឥរិយាបទ និងទង្វើផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរនៅប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម " ទាញយកពីគេហទំព័រ៖ https://www.wvi.org/sites/default/files/Sex-Abuse-Childhood-Report.pdf ត្រង់ជំពូក២ ការយល់ដឹងពីការរំលោភបំពានកុមារ ទំព័រទី៤១



## គ. ការស្វែងយល់ពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (Child Sexual Abuse and Exploitation)

ការយល់ដឹងជាមូលដ្ឋាន ចំពោះបញ្ហានៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា ហាក់នៅមានកម្រិតនៅឡើយ ដោយហេតុថានៅមានការយល់ខុសអំពីអ្វីដែលត្រូវបានចាត់ទុកជាការរំលោភបំពានផ្លូវភេទលើកុមារ និងមិនទាន់មានការយល់ច្បាស់លាស់ថានរណា អាចជាជនរងគ្រោះពីការរំលោភបំពានផ្លូវភេទ [២]។ ជាងនេះទៅទៀត នៅតែមានជំនឿជាច្រើន តែងគិតថាមានតែកុមារីប៉ុណ្ណោះ ដែលអាចក្លាយជាជនរងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសជំនឿខុសឆ្គងដែលតែងគិតថាការរំលោភបំពានផ្លូវភេទលើកុមារសំដៅតែលើការរំលោភសេពសន្ថវៈ ដោយមិនបានគិតថាមានទម្រង់ផ្សេងៗជាច្រើនទៀតដែលអាចពាក់ព័ន្ធ [៣]។

ខាងក្រោមនេះ ជានិយមន័យដែលត្រូវបានដកស្រង់ចេញពី**គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទរបស់ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឆ្នាំ២០១៦** [៤]៖

| ពាក្យគន្លឹះ | និយមន័យ | ឧទាហរណ៍ |
|---|---|---|
| ការរំលោភបំពានផ្លូវភេទលើកុមារ | ការរំលោភបំពានផ្លូវភេទលើកុមារ គឺជាទម្រង់នៃអំពើហិង្សាផ្លូវភេទទៅលើកុមារ ដើម្បីបំពេញចំណង់ផ្លូវភេទរបស់បុគ្គលដែលប្រព្រឹត្តអំពើនោះ។ ការរំលោភបំពានផ្លូវភេទ អាចពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងការបង្ខិតបង្ខំ ឬតាមរូបភាពផ្សេងៗទៀត ដូចជាការប្រើប្រាស់អំណាច ឬឧបាយកល។ ការរំលោភបំពានអាចជាការប៉ះពាល់ដោយផ្ទាល់ ឬដោយមិនប៉ះពាល់ផ្ទាល់រវាងជនល្មើសទៅលើកុមារ [៥]។ | • ការរួមភេទ<br>• ការរំលោភសេពសន្ថវៈ<br>• ការបៀតបៀនផ្លូវភេទកុមារ<br>• ការប៉ះពាល់កុមារក្នុងចេតនាផ្លូវភេទ<br>• ការរំលោភបំពានផ្លូវភេទកុមារដែលពុំមានការប៉ះពាល់ (ការថតរូបភាព/វីដេអូកុមារក្នុងស្ថានភាពផ្លូវភេទ ការបង្ខំឱ្យកុមារមើលរូបភាព សម្ពារអាសអាភាស)<br>• ការប្រើភាសា ឬកាយវិការភេទមិនសមរម្យចំពោះកុមារ |

[២] របាយការណ៍របស់អង្គការ ECPAT ឆ្នាំ២០១៨ ស្តីពី"ទិដ្ឋភាពទូទៅតាមប្រទេស៖ របាយការណ៍ស្តីពីមាត្រដ្ឋាន វិសាលភាព និងបរិបទនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ"

[៣] របាយការណ៍សង្ខេបរបស់អង្គការ World Vision ឆ្នាំ២០១៤ ស្តីពី "ផ្លូវភេទ ការរំលោភបំពាន និងកុមារភាព - ការសិក្សាស្រាវជ្រាវអំពីចំណេះដឹង ឥរិយាបទ និងទង្វើផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរនៅប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម" ទាញយកពីគេហទំព័រ៖ https://www.wvi.org/sites/default/files/Sex-Abuse-Childhood-Report.pdf

[៤] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ "គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ" ទាញយកពី៖ http://luxembourgguidelines.org/english-version/

[៥] ibid ទំព័រទី18-22

| ពាក្យគន្លឹះ | និយមន័យ | ឧទាហរណ៍ |
|---|---|---|
| ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ | ចំណុចដែលខុសគ្នារវាងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទលើកុមារ គឺជាការដោះដូរអ្វីមួយក្នុងគោលបំណងកេងប្រវ័ញ្ច។ នេះមានន័យថាប្រសិនបើកុមារណាម្នាក់ ឬបុគ្គលណាមួយ ជាប់ពាក់ព័ន្ធនឹងការទទួលរបស់អ្វីមួយដែលជាថ្នូរនឹងការធ្វើសកម្មភាពផ្លូវភេទ។<br><br>* * * បើទោះបីជាមានការបែងចែកពីភាពខុសគ្នារវាងការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ តែពេលខ្លះវាប្រហែលជាអាចមិនមានភាពច្បាស់លាស់ទាំងស្រុងនោះទេ [៦]។ | • អំពើជួញដូរផ្លូវភេទកុមារ<br>• អំពើពេស្យាចារកុមារ |
| ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ | សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទដែលអាចកើតឡើងចំពោះកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ។ សកម្មភាពទាំងនោះ រួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬបណ្តាលឱ្យកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ចែកចាយ ឬបញ្ជូននូវរូបភាព ឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ [៦]។ | • ការផលិត និងចែកចាយតាមប្រព័ន្ធអនឡាញនូវសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ និងសម្ភារៈកេងប្រវ័ញ្ចផ្លូវភេទលើកុមារ<br>• ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ<br>• ការគម្រាមកុមារដោយប្រើប្រាស់រូបភាពអាក្រាត ឬរូបភាពបែបផ្លូវភេទ<br>• ការផ្ញើ ឬបញ្ជូនឱ្យកុមារនូវសម្ភារៈបែបផ្លូវភេទ<br>• ការលួងលោមកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ឬក្រៅប្រព័ន្ធអនឡាញ |

[៦] Ibid ទំព័រទី 22-25

### ឃ. ជនរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

បើយោងតាមការសិក្សាស្រាវជ្រាវស្ដីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា (Cambodia's Violence Against Children Survey–CVACS) ឆ្នាំ២០១៣ ដែលដឹកនាំដោយក្រសួងកិច្ចការនារី និងអង្គការយូនីសេហ្វ បានផ្ដល់នូវការប៉ាន់ប្រមាណលំដាប់ថ្នាក់ជាតិជាលើកដំបូង ដែលពិព័ណ៌នាអំពីវិសាលភាព និងសភាពនៃអំពើហិង្សាផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត កាលពីកុមារភាពបានឱ្យដឹងថា[៧]៖



ប្រមាណ៥%នៃកុមារា និងកុមារី ស្ត្រី និងបុរស ដែលមានអាយុចន្លោះពី១៣ ដល់ ២៤ឆ្នាំ បានរាយការណ៍ឱ្យដឹងអំពីទម្រង់មួយចំនួននៃអំពើរំលោភបំពានផ្លូវភេទ មុនពេលដែលពួកគេមានអាយុ១៨ឆ្នាំ។



កុមារា និងកុមារីអាយុចន្លោះពី១៣ ទៅ ១៧ឆ្នាំ លើសពី១នាក់ក្នុងចំណោម២០នាក់ (៥.៥%) បានរាយការណ៍ឱ្យដឹងអំពីអំពើរំលោភបំពានផ្លូវភេទ យ៉ាងហោចណាស់ចំនួន១ប្រភេទ។



កុមារា និងកុមារីអាយុចន្លោះពី ១៣-១៧ឆ្នាំ ស្ទើរតែ១នាក់ក្នុងចំណោម១០នាក់ បានទទួលរងអំពើហិង្សាផ្លូវភេទដោយគ្មានការប៉ះពាល់។

ការសិក្សានោះ ពិតជាបានបង្ហាញថា អត្រានៃការរំលោភបំពានផ្លូវភេទលើកុមារនៅកម្ពុជា មានចំនួនគួរឱ្យកត់សម្គាល់។

* * * សូមបញ្ជាក់ថា ការអង្កេតនេះ ត្រូវបានធ្វើឡើងជាមួយកុមារា និងកុមារីមានអាយុចន្លោះពី ១៣ ទៅ ២៤ឆ្នាំសរុបប្រមាណ ២៥៦០នាក់ ដែលក្នុងនោះមានកុមារី ១១២១នាក់ និងកុមារា ១២៥៥នាក់ បានបំពេញកម្រងសំនួរ។

[៧] Steering Committee on Violence Against Children, Finding from Cambodia's Violence Against Children Survey (CVACS), 2013.

ខាងក្រោមនេះ ជាបំណែងចែកទិន្នន័យនៃជនរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទទាំងពីរភេទ ដែលជាករណីអង្គការសកម្មភាពដើម្បីកុមារបានធ្វើការជាមួយចាប់តាំងពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០២០ [៨]៖

### ទិន្នន័យជនរងគ្រោះដែលជាករណីរបស់អង្គការសកម្មភាពដើម្បីកុមារ ពីឆ្នាំ២០០៣ ដល់ឆ្នាំ ២០២០




ការមិនទាន់មានចំណេះដឹងច្បាស់លាស់ ឬនៅមានការយល់ខុសដោយគិតថាកុមារាមិនងាយនឹងរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដូចកុមារី អាចធ្វើឱ្យកុមារាកាន់តែមានភាពងាយរងគ្រោះ។

តាមរយៈទិន្នន័យរបស់អង្គការសកម្មភាពដើម្បីកុមារ បានបង្ហាញថាក្នុងករណីខ្លះចំនួនកុមារារងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទមានច្រើនជាងកុមារី ដែលហាក់ផ្ទុយពីអ្វីដែលបានយល់។ កត្តានេះ អាចដោយសារតែអង្គការសកម្មភាពដើម្បីកុមារ ភាគច្រើនបានដោះស្រាយករណីដែលទាក់ទងនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមផ្លូវឬតាមទីសាធារណៈ បង្កដោយជនល្មើសផ្លូវភេទលើកុមារជាទេសចរ និងអ្នកធ្វើដំណើរ។ ជនល្មើសផ្លូវភេទលើកុមារទាំងនោះ ជាប្រភេទជនល្មើសដែលមានចំណូលចិត្តខ្ពស់ចំពោះកុមារាជាងកុមារី។ ទោះបីជាយ៉ាងនេះក៏ដោយ ចំនួនកុមារារងគ្រោះជារៀងរាល់ឆ្នាំមានការកើនឡើងគួរឱ្យកត់សម្គាល់ ហើយនៅក្នុងពេលបច្ចុប្បន្ននេះ នៅមិនទាន់មានការយល់ដឹងគ្រប់គ្រាន់អំពីទំហំនៃបញ្ហានោះឡើយ។

សរុបមក វាពិតជាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថាកុមារា ពិតជាអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទដូចកុមារីដែរ ព្រោះការយល់ដឹងនេះ អាចធានាបានថាកុមារានឹងទទួលបានការថែទាំយ៉ាងត្រឹមត្រូវ ជាពិសេសកុមារានឹងទទួលបានការព្យាបាល ការគាំទ្រយ៉ាងត្រឹមត្រូវប្រសិនបើពួកគេរងគ្រោះ ហើយរាល់ករណីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដែលកើតឡើងចំពោះពួកគេ នឹងត្រូវបានយកចិត្តទុកដាក់ដូចករណីដែលកើតឡើងចំពោះកុមារីដែរ។

[៨] ទិន្នន័យអង្គការសកម្មភាពដើម្បីកុមារ

# មេរៀនទី ២ ការស្វែងយល់ថានរណាជាជនល្មើសផ្លូវភេទលើកុមារ និងអ្វីជាវិធីដែលពួកគេប្រើប្រាស់ ?

## មាតិកាមេរៀនទី២


២.១ ប្រធានបទសំខាន់ៗ

២.២ នរណាជាក្រុមគោលដៅ

២.៣ រយៈពេលនៃមេរៀន

២.៤ សេចក្តីផ្តើម

២.៥ ប្លង់មេរៀន

២.៦ ខ្លឹមសារមេរៀនលម្អិត

ក. តើនរណា ជាជនល្មើសផ្លូវភេទលើកុមារ ?

ខ. ការចាប់ផ្តើមទំនាក់ទំនងរវាងជនសង្ស័យ និងកុមារ

គ. ការលួងលោម

# មេរៀនទី ២ ការស្វែងយល់ថានរណាជាជនល្មើសផ្លូវភេទលើកុមារ និងអ្វីជាវិធីដែលពួកគេប្រើប្រាស់ ?

## ២.១ ប្រធានបទសំខាន់ៗ

- ជនល្មើសផ្លូវភេទលើកុមារ-លក្ខណៈទូទៅ និងនិន្នាការថ្មីៗ
- ការលួងលោមកុមារ

## ២.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះអំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ២.៣ រយៈពេលនៃមេរៀន

៤៥ នាទី ទៅ ១ម៉ោង

## ២.៤ សេចក្តីផ្តើម



ជាការពិតណាស់ នៅមានការយល់ច្រឡំ និងមានភាពមិនច្បាស់លាស់ជាច្រើនអំពីការកំណត់ថានរណាជាជនល្មើសផ្លូវភេទលើកុមារ។ ភាពមិនច្បាស់លាស់នេះ ក៏អាចបង្កឱ្យមានការលំបាកជាច្រើនក្នុងការការពារកុមារពីការរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ការសិក្សាស្វែងយល់ថានរណាជាជនល្មើសផ្លូវភេទលើកុមារ និងវិធីសាស្ត្រអ្វីដែលពួកគេប្រើក្នុងការស្វែងរកកុមារ គឺជាមេរៀនមូលដ្ឋានដ៏សំខាន់ក្នុងការការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាច៖

- កំណត់ពីសញ្ញាណនៃអាកប្បកិរិយាដែលគួរឱ្យសង្ស័យ
- កំណត់ពីការចាប់ផ្តើមទំនាក់ទំនងរវាងជនសង្ស័យនិងកុមារ
- កំណត់អំពីគោលបំណង កលល្បិច និងដំណាក់កាលនៃការល្បួងលោម

## ២.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្តើមវគ្គ | ៥នាទី | មុនពេលចាប់ផ្តើមផ្នែកនេះ អ្នកសម្របសម្រួលអាចសាកសួរសំនួរបំផុសទៅអ្នកចូលរួមថាតើគេអាចកំណត់លក្ខណៈរបស់ជនល្មើសផ្លូវភេទលើកុមារដោយរបៀបណា? <br><br> បន្ទាប់ពីទទួលបានចម្លើយ អ្នកសម្របសម្រួលអាចប្រើប្រាស់ចម្លើយទាំងនោះខ្លះៗ និងពន្យល់បន្ថែមដោយលម្អិតថា ជនល្មើសផ្លូវភេទលើកុមារអាចជាមនុស្សណាម្នាក់ បើទោះបីជាពួកគេមានភេទអ្វីក៏ដោយ អាយុប៉ុន្មានក៏ដោយ ហើយមកពីប្រទេសណាមួយក៏ដោយ។ នៅក្នុងវគ្គនេះ សិក្ខាកាមនឹងបានដឹងកាន់តែច្បាស់អំពីលក្ខណៈជាទូទៅ និងដំណើរការក្នុងការកំណត់សញ្ញាណគួរឱ្យសង្ស័យ។ |
| ផ្នែកទី១ | ៥នាទី | នៅក្នុងផ្នែកនេះ អ្នកសម្របសម្រួល អាចបង្ហាញអំពីទិន្នន័យនៃចំនួនជនល្មើសជាបុរស និងស្ត្រី ក៏ដូចជាចំនួនជនល្មើសផ្លូវភេទទាំងពីរប្រភេទរួមមានជនល្មើសផ្លូវភេទបែបឱកាសនិយម និងជនល្មើសផ្លូវភេទដែលមានទំនោរផ្លូវភេទជាមួយកុមារពីកំណើត។ |
| ផ្នែកទី២ | ១៥នាទី | តាមរយៈការប្រើប្រាស់ស្លាយ ឬ ការប្រើប្រាស់ក្រដាសផ្ទាំងធំ អ្នកសម្របសម្រួលអាចបង្ហាញអំពីការចាប់ផ្តើមទំនាក់ទំនងរវាងជនសង្ស័យ និងកុមារ ក្នុងនោះរួមមានការស្វែងរកកុមារនៅក្នុងក្រុមគ្រួសារ/ក្នុងសហគមន៍ ការស្វែងរកកុមារនៅតាមដងផ្លូវ ឬទីសាធារណៈ ការស្វែងរកកុមារតាមកន្លែងកំសាន្តនានា ការស្វែងរកកុមារនៅតាមស្ថាប័ន ការស្វែងរកកុមារតាមប្រព័ន្ធអនឡាញជាដើម ដែលជានិន្នាការថ្មីគួរឱ្យកត់សម្គាល់។ |
| ផ្នែកទី៣ | ២០នាទី | **សកម្មភាព៖ ការកំណត់អំពីការលួងលោម** <br><br> អ្នកសម្របសម្រួល អាចប្រើប្រាស់**ឧបសម្ព័ន្ធ៣**។ អ្នកសម្របសម្រួល ត្រូវចែកសិក្ខាកាមជាពីរក្រុមផ្សេងគ្នា ហើយក្រុមនីមួយៗនឹងទទួលបានករណីសិក្សាមួយពីអង្គការសកម្មភាពដើម្បីកុមារ។ អ្នកសម្របសម្រួល ក៏ត្រូវបញ្ជាក់បន្ថែមដល់សិក្ខាកាមឱ្យបានដឹងថាករណីសិក្សានីមួយៗ សុទ្ធតែជាករណីពិត ហើយជនដែលប្រព្រឹត្តក៏ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់រួចហើយដែរ។ សិក្ខាកាមទាំងពីរក្រុមអាចសរសេរចម្លើយរបស់ខ្លួននៅលើក្រដាសផ្ទាំងធំ រួចធ្វើបទបង្ហាញដោយអ្នកតំណាងរបស់ពួកគេ។ |

## ២.៦ ខ្លឹមសារមេរៀនលម្អិត



### ក. តើនរណា ជាជនល្មើសផ្លូវភេទលើកុមារ?

ជនល្មើសផ្លូវភេទលើកុមារ អាចជានរណាម្នាក់ មិនថាពួកគេជាមនុស្សចាស់ឬក្មេង ជាប្រុសឬស្រី ជាជនចម្លែកឬជាមនុស្សដែលកុមារស្គាល់ ជាជនបរទេសឬជាមនុស្សដែលរស់នៅក្នុងស្រុក។

តាមរយៈទិន្នន័យរបស់អង្គការសកម្មភាពដើម្បីកុមារ [៩] យើងឃើញថាចំនួនជនល្មើសផ្លូវភេទលើកុមារភាគច្រើន គឺជាបុរស។ បើទោះបីជាយ៉ាងនេះក៏ដោយ ស្ត្រីក៏ជាចំណែកបង្កឱ្យមានការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទចំពោះកុមារដែរ។ ក្នុងនោះមានករណីជាច្រើន ដែលបង្ហាញថាស្ត្រីជាអ្នកសមគំនិតក្នុងការសម្របសម្រួលឱ្យមានការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកើតឡើង។

### ទិន្នន័យជាភាគរយនៃចំនួនជនល្មើសជាបុរស និងស្ត្រី




ជនល្មើសផ្លូវភេទលើកុមារ ជាទូទៅត្រូវបានបែងចែកជាពីរប្រភេទផ្សេងគ្នា ក្នុងនោះមានជនល្មើសផ្លូវភេទលើកុមារបែបឱកាសនិយម និងជនល្មើសផ្លូវភេទលើកុមារដែលមានទំនោរផ្លូវភេទជាមួយកុមារពីកំណើត។

[៩] អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) របាយការណ៍ស្តីពី “An Analysis of the Trends and Challenges in the Field of Child Sexual Abuse and Exploitation in Cambodia-February 2014”

ដូចដែលបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទរបស់ក្រុមការងារអន្តរទីភ្នាក់ងារ [១០] ៖

**ជនល្មើសផ្លូវភេទលើកុមារដែលមានទំនោរផ្លូវភេទជាមួយកុមារពីកំណើត៖** សំដៅដល់បុគ្គលដែលមានចំណង់ផ្លូវភេទតែជាមួយកុមារ ឬកុមារក្នុងក្រុមអាយុជាក់លាក់ និងស្វែងរកកុមារក្នុងគោលបំណងទទួលបាននូវទំនាក់ទំនងផ្លូវភេទ។ ជនទាំងនោះ មានចរិតលក្ខណៈដែលអាចកំណត់សញ្ញាណបាន។

**ជនល្មើសផ្លូវភេទលើកុមារបែបឱកាសនិយម៖** សំដៅដល់ជនទាំងឡាយណា ដែលមិនបានបង្ហាញពីចំណង់ចំណូលចិត្តផ្លូវភេទណាមួយចំពោះកុមារ ឬមនុស្សវ័យក្មេងណាមួយឡើយ ប៉ុន្តែពួកគេនឹងប្រព្រឹត្តសកម្មភាពរំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬមនុស្សវ័យក្មេងទាំងនោះ នៅពេលដែលពួកគេស្ថិតក្នុងស្ថានភាពអំណោយផលណាមួយ [១១]។

ខាងក្រោមនេះជាលក្ខណៈទូទៅរបស់**ជនល្មើសផ្លូវភេទលើកុមារដែលមានទំនោរផ្លូវភេទជាមួយកុមារពីកំណើត**ដោយផ្អែកលើបទពិសោធន៍ការងារពីមុនៗរបស់អង្គការសកម្មភាពដើម្បីកុមារ [១២] ៖

| ចរិតលក្ខណៈ | ព័ត៌មានលម្អិត | ភាពញឹកញាប់ |
|---|---|---|
| សាវតា | ធ្លាប់ជាជនរងគ្រោះនៃអំពើរំលោភបំពានផ្លូវភេទកាលពីអតីតកាល | មធ្យម |
| | មានទំនាក់ទំនងសង្គមតិចតួច ឬគ្មានសោះជាមួយមិត្តភក្តិក្នុងអំឡុងវ័យជំទង់ | មធ្យម |
| | ផ្លាស់កន្លែងស្នាក់នៅជាច្រើនដងពីកន្លែងមួយទៅកន្លែងមួយ | មធ្យម |
| | ធ្លាប់ត្រូវបានស៊ើបអង្កេត ឬផ្តន្ទាទោសពីមុនចំពោះអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ | ខ្ពស់ |

[១០] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ"

[១១] Ibid p.87

[១២] អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) សៀវភៅមេរៀន៖ ការឆ្លើយតបបែបកុមារមេត្រីក្នុងនីតិវិធីស៊ើបអង្កេតបទល្មើសផ្លូវភេទលើកុមារ រាជធានីភ្នំពេញ ២០១៩

| ចរិតលក្ខណៈ | ព័ត៌មានលម្អិត | ភាពញឹកញាប់ |
|---|---|---|
| លក្ខណៈ ទំនាក់ទំនង និងអាកប្បកិរិយា | មិនទាន់រៀបការ ប៉ុន្តែហាក់ដូចជាមិនចាប់អារម្មណ៍លើទំនាក់ទំនងជាមួយមនុស្សពេញវ័យ | ទាប |
| | ប្រសិនបើមានចំណាប់អារម្មណ៍ទៅលើទំនាក់ទំនងមនុស្សពេញវ័យ គឺទៅលើស្ត្រីដែលមានកូនរួចហើយ | ទាប |
| | ចូលចិត្តដើរលេងជាមួយកុមារ | មធ្យម |
| | ចូលចិត្តចូលរួមសកម្មភាពនានាជាមួយកុមារ | មធ្យម |
| | មិត្តភក្តិភាគច្រើន ជាកុមារ | មធ្យម |
| | មានចំណង់ចំណូលចិត្តជាក់លាក់ចំពោះក្មេងប្រុស ឬក្មេងស្រី | មធ្យម |
| | មានចំណង់ចំណូលចិត្តជាក់លាក់ចំពោះកុមារក្នុងអាយុជាក់លាក់ណាមួយ | មធ្យម |
| | មានមិត្តភក្តិជាមនុស្សពេញវ័យតិច | មធ្យម |



### ខ. ការចាប់ផ្តើមទំនាក់ទំនងរវាងជនសង្ស័យ និងកុមារ

ជាទូទៅ គេអាចកត់សម្គាល់ឃើញថាជនសង្ស័យ ចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយកុមារ តាមវិធីដូចជា៖



**នៅក្នុងក្រុមគ្រួសារ៖** ជនល្មើសផ្លូវភេទលើកុមារ អាចជាសមាជិកគ្រួសារ អ្នកជិតខាង ឬជាមនុស្សដែលកុមារស្គាល់ក៏ថាបាន ហើយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទអាចកើតឡើងនៅក្នុងក្រុមគ្រួសារដែលកុមាររស់នៅ។



**តាមដងផ្លូវ ឬទីសាធារណៈ៖** ជនល្មើសអាចស្វែងរកកុមារផ្ទាល់នៅតាមទីសាធារណៈ ឬតាមរយៈអន្តរការី។ កុមារដែលងាយរងគ្រោះជាងគេ គឺជាកុមារដែលរស់នៅតាមដងផ្លូវ កុមារដែលធ្វើការលក់ដូរ តាមតំបន់ឆ្នេរសមុទ្រ រមណីយដ្ឋាន ឬកន្លែងសាធារណៈផ្សេងទៀត។ ជនល្មើសផ្លូវភេទលើកុមារទាំងនោះភាគច្រើនជាទេសចរ និងអ្នកធ្វើដំណើរ ឬ ជាជនបរទេស ហើយជនរងគ្រោះភាគច្រើនគឺជាកុមារា។ ដំណើរការល្បួងលោម ដើម្បីកសាងទំនុកចិត្តជាមួយកុមារ  ក៏ត្រូវសម្គាល់ឃើញថាបានប្រើប្រាស់ច្រើនដោយជនល្មើសផងដែរ។

**តាមទីកន្លែងកំសាន្តនានា៖** ជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់ទីកន្លែងកំសាន្តមួយចំនួនដូចជា ខារ៉ាអូខេ បៀរហ្គាដិន ហាងម៉ាស្សាជាដើម ដើម្បីទាក់ទងជាមួយកុមារក្នុងគោលបំណងផ្លូវភេទ ហើយកុមារក៏ត្រូវបានគេកេងប្រវ័ញ្ចតាមរយៈពេស្យាចារ។ ជនល្មើសផ្លូវភេទលើកុមារ ភាគច្រើនជាជនជាតិខ្មែរ ឬជាជាតិសាសន៍អាស៊ីដទៃទៀត ហើយជនទាំងនោះអាចស្វែងរកកុមារដោយមានជំនួយពីអន្តរការី ដែលជនរងគ្រោះភាគច្រើនត្រូវបានកត់សម្គាល់ឃើញថា គឺជាកុមារី។

**នៅតាមស្ថាប័ន៖** ជនល្មើស អាចស្វែងរកតួនាទីណាមួយ ឬធ្វើជាអ្នកស្ម័គ្រចិត្តនៅក្នុងស្ថាប័នណាមួយដែលជាស្ថាប័នមានគោលបំណងជួយដល់កុមារ។ ស្ថាប័នទាំងនោះ អាចជាសាលារៀន អង្គការ មណ្ឌលកុមារកំព្រា ឬមណ្ឌលដែលជនល្មើសអាចធ្វើការ ឬប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយកុមារ។ ជនល្មើសក្នុងលក្ខខណ្ឌនេះ ភាគច្រើនជាជនបរទេស។

**តាមប្រព័ន្ធអនឡាញ៖** មធ្យោបាយនេះ ត្រូវបានចាត់ទុកថាជាទម្រង់ថ្មីនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ជនល្មើស អាចទាក់ទងកុមារតាមរយៈប្រព័ន្ធអ៊ីនធឺណិត ហើយជនទាំងនោះក៏អាចកេងប្រវ័ញ្ចផ្លូវភេទលើកុមារផងដែរ។ ជាឧទាហរណ៍ដូចជា ការទាមទាររូបថតបែបផ្លូវភេទពីកុមារជាដើម។ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ជនល្មើសក៏អាចរៀបចំដើម្បីជួបជាមួយកុមារផ្ទាល់ក្នុងគោលបំណងរំលោភបំពានផ្លូវភេទផងដែរ។ មធ្យោបាយនេះ ក៏រួមបញ្ចូលនូវការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាពសម្ភារៈបែបផ្លូវភេទ ឬរូបភាព-សម្ភារៈផ្តោតលើកេរភេទកុមារ។



## គ. ការល្បួងលោម

ជនល្មើសផ្លូវភេទលើកុមារ ប្រើកលល្បិចល្បួងលោម ដើម្បីកសាងទំនុកចិត្តជាមួយកុមារ គ្រួសារ ឬសហគមន៍ទាំងមូល មុននឹងឈានដល់ការរំលោភបំពានផ្លូវភេទ។ វិធីសាស្ត្រល្បួងលោម តែងកត់សម្គាល់ឃើញថាត្រូវបានប្រើប្រាស់ដោយជនល្មើសដើម្បីទាក់ទងកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទដោយការចាប់ផ្តើមនូវទំនាក់ទំនងតាមដងផ្លូវ ឬទីសាធារណៈ នៅតាមស្ថាប័ន និងនៅតាមប្រព័ន្ធអ៊ីនធឺណិត។ ការល្បួងលោមអាចកើតឡើងដោយផ្ទាល់ ឬតាមប្រព័ន្ធអ៊ីនធឺណិត ហើយអាចធ្វើឡើងក្នុងដំណាក់កាលផ្សេងៗគ្នា។

ការល្បួងលោម គឺជាដំណើរការដែលអាចកើតឡើងក្នុងរយៈពេលយូរ ឬឆាប់ អាស្រ័យលើវិធីសាស្ត្រដែលជនល្មើសបង្កើតទំនាក់ទំនងជាមួយកុមារ និងមនុស្សជុំវិញ ជាពិសេសគឺអាស្រ័យថាតើការល្បួងលោមនោះ កើតឡើងផ្ទាល់ឬតាមប្រព័ន្ធអនឡាញ។ ការល្បួងលោមដែលកើតឡើងផ្ទាល់ ពេលខ្លះជនល្មើសអាចចំណាយពេលរហូតដល់ពីរ ឬបីឆ្នាំ មុននឹងឈានដល់ការរំលោភបំពានលើកុមារក៏មាន។

ខាងក្រោម គឺជាដំណាក់កាលសំខាន់ៗនៃការលួងលោម [១៣ ១៤ ១៥]។ គួរឱ្យកត់សម្គាល់ដែរថា ដំណាក់កាលនៃការលួងលោម មិនមែនកើតឡើងគ្រប់ដំណាក់កាលទាំងអស់នោះទេ ពេលខ្លះដំណាក់កាលមួយចំនួនអាចកើតឡើងម្តងហើយ ម្តងទៀត ហើយពេលខ្លះមិនអាចញែកចេញពីគ្នាបានទាំងស្រុងនោះឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ជាទូទៅជនល្មើសផ្លូវភេទកុមារភាគច្រើន តែងតែឆ្លងកាត់ដំណាក់កាលទាំងអស់នេះ ដើម្បីទាក់ទងជាមួយកុមារ។ ដំណាក់កាលទាំងនោះរួមមាន៖

## ការកំណត់ភាពងាយរងគ្រោះ និងការដាក់គោលដៅចំពោះកុមារ៖

ជនល្មើសផ្លូវភេទលើកុមារ វាយតម្លៃលើស្ថានភាពងាយរងគ្រោះរបស់កុមារ ឪពុកម្តាយ សហគមន៍ និងស្ថាប័នណាមួយ ដើម្បីកំណត់គោលដៅរបស់ខ្លួន។ ជាឧទាហរណ៍៖ កុមារដែលខ្វះការជឿជាក់ ទុកចិត្តលើខ្លួនឯង កុមារស្ថិតក្នុងជីវភាពក្រីក្រ កុមារដែលមានបញ្ហាសុខភាពផ្លូវកាយ/ផ្លូវចិត្តជាដើម។ ចំណែកស្ថានភាពគ្រួសារវិញ ជនល្មើសផ្លូវភេទលើកុមារអាចវាយតម្លៃគ្រួសារដែលមានស្ថានភាពជីវភាពក្រីក្រ គ្រួសារដែលមានតែម្តាយ ឬឪពុក គ្រួសារដែលសមាជិកប្រើប្រាស់គ្រឿងញៀនជាដើម។ ក្រៅពីកុមារ និងគ្រួសារ ជនល្មើសក៏អាចវាយតម្លៃចំពោះស្ថាប័នណាដែលមានភាពដាច់ស្រយាល កង្វះការត្រួតពិនិត្យត្រឹមត្រូវ កង្វះគោលនយោបាយការពារកុមារជាដើម។ ដំណាក់កាលទីមួយនេះ គឺជាដំណាក់កាលដែលជនល្មើសធ្វើការគ្រោងទុកយ៉ាងល្អបំផុត។

## ការទទួលបាននូវទំនុកចិត្ត

ជនល្មើសផ្លូវភេទ នឹងបន្តកសាងទំនាក់ទំនងល្អ បង្កើនភាពស្និទ្ធស្នាល ផ្តល់ទំនុកចិត្ត និងសិក្សាពីតម្រូវការរបស់កុមារ មនុស្សជុំវិញកុមារ និងស្ថាប័ននោះជាដើម។ ចំពោះកុមារ ដំណាក់កាលនេះ ជនល្មើសអាចបង្ហាញនូវការយកចិត្តទុកដាក់ជាពិសេស ការស្តាប់ និងការកោតសរសើរ។ ចំណែកចំពោះគ្រួសារដំណាក់កាលនេះ អាចជាការរៀបអាពាហ៍ពិពាហ៍ជាដើម។ ចំពោះស្ថាប័នវិញ ការស្វែងរកតួនាទីណាមួយដែលអាចស្ថិតនៅកៀកជាមួយកុមារ និងបង្កើតទំនាក់ទំនងការងារល្អជាមួយបុគ្គលិកដទៃទៀត គឺជាវិធីសាស្ត្រដែលជនល្មើសប្រើ។

## ការបំពេញនូវតម្រូវការ

ជនល្មើសផ្លូវភេទ អាចផ្តល់ជាប្រាក់កាស អំណោយ អាហារ ទីជម្រក សំលៀកបំពាក់ ការអប់រំ និង/ឬជាការគាំទ្រ ផ្គត់ផ្គង់ចំពោះកុមារ។ ពួកគេ ក៏អាចបំពេញតម្រូវការដល់គ្រួសារកុមារតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុ សាងសង់ផ្ទះសំបែង ការគាំទ្រ ឬការផ្គត់ផ្គង់នានាជាដើម។ ចំពោះស្ថាប័ន ជនល្មើសអាចមានតួនាទីជាបុគ្គលិកសំខាន់ ឬ ជាអ្នកផ្តល់ជំនួយឧបត្ថម្ភ។

---

[១៣] APLE (2013) "Grooming Techniques- Techniques Used by Perpetrators in Cambodia"

[១៤] G. M. Winters & E. L. Jeglic (2017) Stages of Sexual Grooming: Recognizing Potentially Predatory Behaviors of Child Molesters, Deviant Behavior, 38:6, 724-733, DOI: 10.1080/01639625.2016.1197656

[១៥] O'Leary, P, Koh, E, & Dare, A (2017), Grooming and child sexual abuse in institutional contexts, Royal Commission into Institutional Responses to Child Sexual Abuse, Sydney

## ការបំបែកកុមារចេញពីក្រុមគ្រួសារ ឬសហគមន៍

ចាប់ផ្តើមចេញពីដំណាក់កាលនេះទៅ មានតែកុមារប៉ុណ្ណោះដែលត្រូវរងផលប៉ះពាល់ ដោយជនល្មើសប្រើវិធីសាស្ត្រនាំកុមារចេញឆ្ងាយពីមនុស្សជុំវិញខ្លួន ដោយចំណាយពេលនៅតែជាមួយកុមារ ដោយមិនមានវត្តមានមនុស្សពេញវ័យ។ ជនទាំងនោះអាចនាំកុមារចេញទៅដើរលេងនៅខាងក្រៅ លេងល្បែងកំសាន្តជាមួយកុមារ ឬប្រហែលជាអាចផ្តល់ការមើលថែទាំកុមារនៅពេលឪពុកម្តាយពួកគេមិននៅផ្ទះ ឬក៏ប្រហែលជាអាចឱ្យកុមារប្រើប្រាស់ គ្រឿងញៀន ឬគ្រឿងស្រវឹងជាដើម។

## ការបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ

ជនល្មើស អាចប្រព្រឹត្តនូវសកម្មភាពទាក់ទងនឹងផ្លូវភេទបែបបន្លំ និងបន្សាំកុមារទៅនឹងសកម្មភាពផ្លូវភេទផ្សេងៗ។ ជាឧទាហរណ៍ដូចជា ការនាំកុមារចូលរួមក្នុងសកម្មភាពដែលមានចេតនាប៉ះពាល់ដូចជាការហែលទឹក ការលេងបោកចំបាប់ ការលេងចាក់ក្រឡេក ការម៉ាស្សាជាដើម និង/ឬអាចភ្ជាប់ការសន្ទនារបស់គេជាមួយកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ ឬការបង្ហាញរូបភាពបែបអាសអាភាសជាដើម។

## ការប្រព្រឹត្តសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ និងការរក្សាការគ្រប់គ្រងលើកុមារ

បន្ទាប់ពីការរំលោភបំពានផ្លូវភេទលើកុមារ ជនល្មើសនឹងប្រើវិធីសាស្ត្រផ្លូវចិត្តផ្សេងៗ ដើម្បីរក្សាការគ្រប់គ្រងបន្តការរំលោភបំពាន និងមិនឱ្យកុមារលាតត្រដាងអំពីការរំលោភបំពាន។ ជនល្មើសផ្លូវភេទលើកុមារអាចប្រើប្រាស់ការសំងាត់ ការដាក់កំហុសលើកុមារ ការប្រើប្រាស់ឧបាយកល ភាពអាម៉ាស់ និងការគំរាមកំហែងដើម្បីបន្តសកម្មភាពរំលោភបំពាន និងទប់ស្កាត់មិនឱ្យមានការរាយការណ៍។

- **ការសម្ងាត់** - ធ្វើយ៉ាងណាឱ្យកុមារសន្យាថាមិនប្រាប់រឿងរ៉ាវទៅអ្នកដទៃ ហើយរក្សារឿងនោះជាអាថ៌កំបាំង
- **ការដាក់កំហុសលើកុមារ** - ធ្វើឱ្យកុមារមានអារម្មណ៍ថាខ្លួនបានធ្វើអ្វីមួយខុសឆ្គង
- **ភាពអាម៉ាស់** - ធ្វើឱ្យកុមារមានអារម្មណ៍ថាអាម៉ាស់នឹងអ្វីដែលបានកើតឡើង
- **ការគំរាមកំហែង** - គំរាមកំហែងថានឹងបញ្ចប់ទំនាក់ទំនង ឬគំរាមថានឹងប្រាប់រឿងរ៉ាវទៅអ្នកដទៃ ឬគំរាមកំហែងធ្វើបាបកុមារ ឬក្រុមគ្រួសារកុមារ

ការពន្យល់បង្ហាញអំពីដំណាក់កាលនីមួយៗនៃការលួងលោម អាចជួយឱ្យបានដឹងថាការរំលោភបំពានអាចកើតឡើងចំពោះមនុស្សគ្រប់គ្នា ហើយវាជាសកម្មភាពរៀបចំទុករបស់ជនល្មើស។ ការពន្យល់បង្ហាញត្រង់ចំណុចនេះ ក៏អាចជួយលុបបំបាត់អារម្មណ៍ស្តីបន្ទោសខ្លួនឯងរបស់ជនរងគ្រោះ ភាពអាម៉ាស់ និងអារម្មណ៍ដែលគិតថាខ្លួនឯងមានកំហុសជាដើម ជាពិសេសគឺជួយលុបបំបាត់អារម្មណ៍ដែលគិតថាខ្លួនឯងបានរួមចំណែកក្នុងរឿងរ៉ាវដែលកើតឡើងនោះ។

# ជំពូក២៖

# ការស្វែងយល់ពីអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ




នៅក្នុងជំពូក២នេះ អ្នកនឹងបានរៀនសូត្រនូវមេរៀនសំខាន់ៗចំនួនពីរផ្សេងគ្នាដែលក្នុងនោះរួមមាន មេរៀនទី១៖ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងមេរៀនទី២៖ ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។ នៅក្នុងមេរៀននីមួយៗ អ្នកក៏នឹងបានយល់ពីគន្លឹះសំខាន់ដូចខាងក្រោម៖

# គំនិតសំខាន់នៃមេរៀនទី១

១. ស្ថិតិនៃការប្រើប្រាស់អ៊ីនធឺណិតនៅប្រទេសកម្ពុជា មានការកើនឡើងយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ជាពិសេសចំនួនកុមារកាន់តែច្រើនដែលបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាមានការយល់ដឹងតិចតួចអំពីវត្តមាន និងទំហំនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ហើយការយល់ដឹងរបស់សហគមន៍ក៏នៅមានកម្រិតដែរ។ ការយល់ដឹងអំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារតាមប្រព័ន្ធអនឡាញ មិនទាន់មានភាពទូលំទូលាយ និងច្បាស់លាស់នៅឡើយទេ។

២. ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (Online Child Sexual Exploitation -OCSE) ជាទម្រង់មួយនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារដែលកំពុងកើតមានឡើងនៅប្រទេសកម្ពុជា និងទាមទារឱ្យមានការយល់ដឹងទូលំទូលាយអំពីហានិភ័យដែលអាចកើតឡើងតាមប្រព័ន្ធអនឡាញចំពោះកុមារតាមរយៈវេទិកាអនឡាញមួយចំនួនដែលកុមារនិយមប្រើប្រាស់។

៣. ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ មានភាពខុសប្លែកគ្នាខ្លាំងពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារក្រៅប្រព័ន្ធអនឡាញ ទម្រង់ទាំងនោះរួមមាន៖ ការលួងលោមតាមប្រព័ន្ធអនឡាញ ការផលិត និងការចែកចាយសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ការផ្ញើសារបែបផ្លូវភេទ ការគម្រាមបែបផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមរយៈការផ្សាយផ្ទាល់។

៤. ភាពជឿនលឿននៃបច្ចេកវិទ្យា និងភាពអនាមិកនៃការប្រើប្រាស់អ៊ីនធឺណិត ធ្វើឱ្យជនល្មើសផ្លូវភេទលើកុមារកាន់តែមានភាពងាយស្រួល ក្នុងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជាពិសេសភ្នាក់ងារអនុវត្តច្បាប់ មានការលំបាកក្នុងការកំណត់អត្តសញ្ញាណជនសង្ស័យ និងសកម្មភាពប្រព្រឹត្តបទល្មើស បានបង្កឱ្យការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅតែបន្តកើតមាន។

# គំនិតសំខាន់នៃមេរៀនទី២

១. អ្វីទាំងអស់ដែលបានបង្ហោះនៅលើអ៊ីនធឺណិត គឺស្ទើរតែមិនអាចដកចេញបាននោះទេ។ មុននឹងបង្ហោះអ្វីមួយនៅលើប្រព័ន្ធអ៊ីនធឺណិត គួរមានការគិតគូរឱ្យបានច្បាស់លាស់បំផុត ដើម្បីរក្សាកុមារឱ្យរួចផុតពីហានិភ័យដែលអាចកើតមាន។

២. ការណែនាំកុមារឱ្យចេះអនុវត្តនូវវិធីសាស្ត្រងាយៗមួយចំនួន ជាពិសេសការយល់ដឹងពីអាកប្បកិរិយាតាមអនឡាញដែលប្រកបដោយភាពឆ្លាតវៃ ឬហៅថា SMART rules អាចឱ្យពួកគេរក្សាព័ត៌មានផ្ទាល់ខ្លួនប្រកបដោយសុវត្ថិភាព ជាពិសេសអាចការពារពួកគេពីហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញផងដែរ។

៣. ការកំណត់ឯកជនភាពរបស់អ្នកប្រើប្រាស់នៅលើគណនី និងបណ្ដាញទំនាក់ទំនងសង្គម គួរតែត្រូវធ្វើមុនពេលចាប់ផ្ដើមប្រើប្រាស់គណនីទាំងនោះ ដើម្បីប្រាកដថាមានតែមិត្តភក្តិដែលអ្នកទុកចិត្តប៉ុណ្ណោះដែលអាចមើលឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។

មេរៀនទី ១

# ការស្វែងយល់អំពីមូលដ្ឋាននៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## មាតិកាមេរៀនទី១


១.១ ប្រធានបទសំខាន់ៗ

១.២ នរណាជាក្រុមគោលដៅ

១.៣ រយៈពេលនៃមេរៀន

១.៤ សេចក្ដីផ្ដើម

១.៥ ប្លង់មេរៀន

១.៦ ខ្លឹមសារមេរៀនលម្អិត

ក. ស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

ខ. បរិបទនៅប្រទេសកម្ពុជា

គ. ការស្វែងយល់លម្អិតពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

- > តើអ្វីខ្លះជាហានិភ័យដែលអាចកើតឡើងនៅពេលកុមារប្រើប្រាស់អ៊ីនធឺណិត?
- > វេទិកាអនឡាញមួយចំនួនដែលកុមារនិយមប្រើប្រាស់
- > តើអ្វីជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (Online Child Sexual Exploitation_OCSE)?
- > តើជនល្មើស កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញជានរណា?
- > ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ
- > បច្ចេកស័ព្ទមួយចំនួនទាក់ទងនឹងអ៊ីនធឺណិត និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ឃ. ការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

# មេរៀនទី ១ ការស្វែងយល់អំពីមូលដ្ឋាននៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## ១.១ ប្រធានបទសំខាន់ៗ

- បរិបទនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា
- ហានិភ័យដែលអាចកើតឡើងតាមប្រព័ន្ធអនឡាញ
- វេទិកាអនឡាញដែលកុមារនិយមប្រើប្រាស់
- ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## ១.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះអំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ១.៣ រយៈពេលនៃមេរៀន

១ម៉ោង ៣០នាទី ទៅ ២ម៉ោង

## ១.៤ សេចក្តីផ្តើម



ទាំងកុមារ និងមនុស្សពេញវ័យ មិនទាន់មានចំណេះដឹងគ្រប់គ្រាន់នៅឡើយអំពីគ្រោះថ្នាក់ដែលអាចបង្កឡើងតាមរយៈសកម្មភាពតាមអនឡាញរបស់ពួកគេ។ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កើតឡើងក្នុងទម្រង់ជាច្រើន ហើយកុមារត្រូវបានទាក់ទងដោយជនល្មើសផ្លូវភេទតាមប្រព័ន្ធអនឡាញ ដោយប្រើវិធីផ្សេងៗគ្នា។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាច៖

- ដឹងពីបរិបទនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅប្រទេសកម្ពុជា
- ដឹងពីហានិភ័យដែលអាចកើតឡើងនៅពេលកុមារប្រើប្រាស់អ៊ីនធឺណិត
- កំណត់បានពីវេទិកា/កម្មវិធីតាមអនឡាញមួយចំនួន ដែលអាចធ្វើឱ្យកុមារប្រឈមនឹងហានិភ័យ
- ដឹងពីលក្ខណៈរបស់ជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងវិធីសាស្ត្រនៃការលួងលោមរបស់ពួកគេតាមអនឡាញ
- កំណត់បាន និងស្គាល់ពីទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ
- ដឹងពីទំនាក់ទំនងនៃការប្រើប្រាស់អ៊ីនធឺណិត ទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ
- បច្ចេកសព្ទមួយចំនួនទាក់ទងនឹងអ៊ីនធឺណិត និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ដឹងពីបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## ១.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី១ | ១៥នាទី | នៅក្នុងផ្នែកទី១នេះ អ្នកសម្របសម្រួល អាចចាប់ផ្ដើមដោយការបង្ហាញពីស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញជាសកលជាពិសេសគឺបរិបទនៅប្រទេសកម្ពុជា។ |
| ផ្នែកទី២ | ១៥នាទី | អ្នកសម្របសម្រួលត្រូវផ្ដោតសំខាន់ពីការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដោយចាប់ផ្ដើមចេញពីការបង្ហាញថាអ្វីទៅជាហានិភ័យតាមប្រព័ន្ធអនឡាញ? |
| ផ្នែកទី៣ | ២០នាទី | **សកម្មភាពបំផុស៖** ផ្នែកនេះ អ្នកសម្របសម្រួលនឹងសួរទៅអ្នកចូលរួម៖<br><br>តើគេហទំព័រ និងកម្មវិធីតាមប្រព័ន្ធឌីជីថលអ្វីខ្លះដែលអ្នកបានដឹង? តើអ្នកគិតថាកុមារប្រើប្រាស់ប្រភេទកម្មវិធីអ្វីខ្លះ? តើអ្នកដឹងទេថា ពួកគេប្រើប្រាស់កម្មវិធីទាំងនោះដើម្បីអ្វី?<br><br>តាមរយៈស្លាយមេរៀន ឬការសរសេរលើក្រដាសផ្ទាំងធំ អ្នកសម្របសម្រួលបង្ហាញពីកម្មវិធីសំខាន់ៗមួយចំនួនដែលត្រូវបានប្រើប្រាស់ដោយកុមារក្នុងប្រទេសកម្ពុជា។ បន្ទាប់មក ពន្យល់ពីអ្វីដែលកុមារធ្វើ នៅពេលពួកគេប្រើប្រាស់កម្មវិធីទាំងនោះ ហើយប្រៀបធៀបចំណុចទាំងនោះជាមួយនឹងចម្លើយដែលសិក្ខាកាមបានផ្ដល់ឱ្យ។ អ្នកសម្របសម្រួលត្រូវសង្កត់ធ្ងន់លើប្រភេទកម្មវិធីដែលកុមារអាចប្រើប្រាស់ក្នុងការទាក់ទងជាមួយអ្នកដទៃទៀតតាមអនឡាញ។ ចំណាំ៖ ត្រង់ចំណុចនេះ អ្នកសម្របសម្រួលត្រូវដឹងថា កម្មវិធីដែលកុមារប្រើប្រាស់តែងមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស និងមានកម្មវិធីថ្មីៗជាច្រើន ដូចនេះ មុនពេលបង្ហាញនូវចំណុចនេះ អ្នកសម្របសម្រួលគួរតែស្រាវជ្រាវបន្ថែម ដើម្បីប្រាកដថាព័ត៌មានដែលបង្ហាញបានធ្វើបច្ចុប្បន្នភាព។ |
| ផ្នែកទី៤ | ៣០នាទី | អ្នកសម្របសម្រួលត្រូវបន្តផ្ដោតសំខាន់លើការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដោយផ្ដល់និយមន័យ នរណាជាជនល្មើសតាមប្រព័ន្ធអនឡាញ បន្ទាប់មកពន្យល់លម្អិតពីទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក៏ដូចជាបន្ថែមករណីជាឧទាហរណ៍មួយចំនួនរបស់អង្គការសកម្មភាពដើម្បីកុមារ។ |

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី៥ | ១០នាទី | អ្នកសម្របសម្រួល ត្រូវបង្ហាញបន្ថែមអំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា |
| ផ្នែកទី៦ | ៣០នាទី | **សកម្មភាពបំផុស៖ យុទ្ធនាការលើកកម្ពស់ការយល់ដឹង**<br>បែងចែកសិក្ខាកាម ជា៣ក្រុមផ្សេងគ្នា ដោយផ្តល់ឱ្យក្រុមនីមួយៗនូវកិច្ចការដូចខាងក្រោម៖ ឧបមាថា សិក្ខាកាមគឺជាសមាជិកនៃគណៈកម្មាធិការ ដែលធ្វើការលើការងារប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅក្នុងសហគមន៍របស់អ្នក។ អ្នកចង់បង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹងមួយ ដោយផ្តោតលើកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ដូចនេះសិក្ខាកាមត្រូវគិតគូររួមគ្នាពីវិធីផ្សព្វផ្សាយសារសំខាន់ៗក្នុងចំណោមអ្នកចូលរួម។ ចំណុចដែលត្រូវគិតគូរពិចារណារួមមាន៖<br>១. តើយុទ្ធនាការរបស់អ្នក នឹងផ្តោតលើទម្រង់តែមួយ ឬគ្រប់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ?<br>២. តើសារសំខាន់អ្វីខ្លះ ដែលអ្នកចង់ផ្សព្វផ្សាយ?<br>៣. តើអ្នកនឹងកំណត់ក្រុមគោលដៅប្រភេទណា?<br>៤. តើអ្នកមានគម្រោងផ្សព្វផ្សាយសារទាំងនេះដោយរបៀបណា?<br>៥. តើវេទិកាប្រភេទណាដែលអ្នកនឹងប្រើសម្រាប់យុទ្ធនាការនេះ? (បណ្តាញទំនាក់ទំនងសង្គម ព្រឹត្តិការណ៍សាធារណៈ ព័ត៌មាន ការជួបជុំសហគមន៍ជាដើម)<br>អ្នកសម្របសម្រួល គួរលើកទឹកចិត្តសិក្ខាកាមឱ្យមានគំនិតច្នៃប្រឌិតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ក្រុមនីមួយៗ នឹងត្រូវធ្វើបទបង្ហាញពីគំនិតរបស់ពួកគេទៅដល់អ្នកចូលរួមផ្សេងទៀត។ បន្ទាប់ពីក្រុមនីមួយៗ បានធ្វើបទបង្ហាញរួច អ្នកសម្របសម្រួលត្រូវផ្តល់គំនិតល្អៗបន្ថែម និងចូលរួមកែលម្អគំនិតផ្សេងទៀត។ |

## ១.៦ ខ្លឹមសារមេរៀនលម្អិត

### ក. ស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ



ការប្រើប្រាស់អ៊ីនធឺណិត និងគណនីបណ្តាញទំនាក់ទំនងសង្គម បានក្លាយជាទម្លាប់ប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា និងមនុស្សជាច្រើនទៀតនៅជុំវិញពិភពលោក។ អ៊ីនធឺណិត បានផ្តល់ឱ្យមនុស្សគ្រប់គ្នា នូវការកម្សាន្ត ការស្វែងរកឱកាសការងារ ការរក្សាទំនាក់ទំនងជាមួយគ្រួសារនិងមិត្តភក្តិ ការទទួលបានព័ត៌មានផ្សេងៗ ការលេងហ្គេមកំសាន្តជាដើម។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ការជឿនលឿនផ្នែកបច្ចេកវិទ្យា និងការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធឺណិតនៅទូទាំងពិភពលោក ក៏បានបង្កើននិន្នាការថ្មីគួរឱ្យព្រួយបារម្ភ ដែលអាចនាំឱ្យកុមារប្រឈមនឹងហានិភ័យ។



ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់ថ្មីមួយដែលកើតឡើងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឬប្រព័ន្ធអ៊ីនធឺណិតជាមធ្យោបាយទាក់ទងកុមារមុននឹងឈានដល់ការរំលោភបំពាន។ ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញរួមមាន ការផលិតសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) អំពើលួងលោមតាមប្រព័ន្ធអនឡាញ (Online Grooming) អំពើផ្ញើសារបែបរំលោភបំពានផ្លូវភេទ (Sexting) អំពើគំរាមខាងផ្លូវភេទ (Sextortion) និងអំពើផ្សាយផ្ទាល់ពីការរំលោភបំពានផ្លូវភេទកុមារ (Live Online Child Sexual Abuse)[១៦]។



ជាសកល ការទទួលបានសេវាអ៊ីនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាតតម្លៃសមរម្យ កំពុងកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ក្រីក្រ និងងាយរងគ្រោះ។ ក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រជាជន៧៥% មានទូរស័ព្ទដៃវៃឆ្លាត និងមានលើសពី២ភាគ៣នៃអ្នកប្រើប្រាស់អ៊ីនធឺណិត កំពុងប្រើប្រាស់គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីសូហ្វវែរ តាមរយៈឧបករណ៍ចល័ត[១៧]។ យ៉ាងហោចណាស់ មានអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមចំនួន ៧៥០លាននាក់នៅទូទាំងតំបន់។

[១៦] WePROTECT. (2016).

[១៧] We are Social. (2017).

## ខ. បរិបទនៅប្រទេសកម្ពុជា



ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតចល័ត បណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យា បានពង្រីកខ្លួនយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយនិន្នាការនេះ ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើង។ នាពេលបច្ចុប្បន្ននេះ នៅកម្ពុជាមានអ្នកប្រើប្រាស់លេខទូរស័ព្ទចល័តចំនួន ២០.៩៩៣.៨៥៧ លេខ និងទូរស័ព្ទអចល័តចំនួន ៤២.១៩៥ លេខ អ្នកប្រើប្រាស់អ៊ីនធឺណិតចល័តប្រមាណ ១៧.៤៩៨.៨៣៧ ភ្ជាប់ប្រព័ន្ធ និងអ៊ីនធឺណិតអចល័តចំនួន ៣០៩.២៤២ ភ្ជាប់ប្រព័ន្ធ [១៨]។

**ក្រាហ្វិកទី១៖ ចំនួនអ្នកប្រើប្រាស់លេខទូរស័ព្ទចល័ត និងអចល័តពីឆ្នាំ២០១៧ ដល់ ខែកក្កដាឆ្នាំ២០២១**

( ទិន្នន័យនិយ័តករទូរគមនាគមន៍កម្ពុជា-Telecommunication Regulator of Cambodia_TRC )




**ក្រាហ្វិកទី២៖ ចំនួនអ្នកប្រើប្រាសអ៊ីនធឺណិតចល័តនិងអចល័តពីឆ្នាំ២០១៧ ដល់ ខែកក្កដាឆ្នាំ២០២១**

( ទិន្នន័យនិយ័តករទូរគមនាគមន៍កម្ពុជា-Telecommunication Regulator of Cambodia_TRC )




[១៨] និយ័តករទូរគមនាគមន៍កម្ពុជា–Telecommunication Regulator of Cambodia

ជាងនេះទៅទៀត បើយើងពិនិត្យមើលចំនួនអ្នកប្រើប្រាស់ Facebook ត្រឹមរយៈពេលដដែល (ខែកក្កដា ឆ្នាំ២០២១) មានចំនួនប្រមាណ ១២.៧៨៤.០០០ Messenger មានចំនួន ១១.៣៨៣.០០០ Instagram មានចំនួន ១.៩៧៩.៤០០ និង Linkedin ចំនួន ៤៣៧.២០០។ ក្នុងចំណោមអ្នកប្រើប្រាស់ Facebook ចំនួន ១២.៧៨៤.០០០ មានប្រុសចំនួន ៥៦.៧% ស្រីចំនួន ៤៣.៣% ក្នុងនោះមានអ្នកប្រើប្រាស់បណ្ដាញសង្គមដែលមិនទាន់គ្រប់អាយុមានចំនួនប្រមាណ 11.3% [១៩]។

**ក្រាហ្វិកទី៣៖ ចំនួនអ្នកប្រើប្រាស់ Facebook ត្រឹមខែកក្កដាឆ្នាំ២០២១**

**(ទិន្នន័យដកស្រង់ចេញពីគេហទំព័រ NapoleonCat.com)**




**ក្រាហ្វិកទី៤៖ ចំនួនអ្នកប្រើប្រាស់ Messenger ត្រឹមខែកក្កដាឆ្នាំ២០២១**

**(ទិន្នន័យដកស្រង់ចេញពីគេហទំព័រ NapoleonCat.com)**




[១៩] NapoleonCat.com

**ក្រាហ្វិកទី៥៖ ចំនួនអ្នកប្រើប្រាស់ Instagram ត្រឹមខែកក្កដាឆ្នាំ២០២១**

**( ទិន្នន័យដកស្រង់ចេញពីគេហទំព័រ NapoleonCat.com )**




**ក្រាហ្វិកទី៥៖ ចំនួនអ្នកប្រើប្រាស់ Linkedin ត្រឹមខែកក្កដាឆ្នាំ២០២១**

**( ទិន្នន័យដកស្រង់ចេញពីគេហទំព័រ NapoleonCat.com )**




កំណើននៃការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាត នៅតាមសហគមន៍មានចំណូលទាប មានអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន។ ទោះបីជាយ៉ាងណា វាបានបង្កនូវហានិភ័យគួរឱ្យកត់សម្គាល់ផងដែរចំពោះកុមារ និងមនុស្សវ័យក្មេង។

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាមានការយល់ដឹងតិចតួចអំពីវត្តមាន និងទំហំនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ [២០] ហើយការយល់ដឹងរបស់សហគមន៍ក៏នៅមានកម្រិតដែរ [២១]។

[២០] អង្គការសេកម្មភាពដើម្បីកុមារ (ឆ្នាំ២០១៦)

[២១] ក្រសួងកិច្ចការនារី (ឆ្នាំ២០១៤)

ដោយមើលឃើញនូវបញ្ហាប្រឈម និងផលប៉ះពាល់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល WePROTECT នៅទីក្រុងអាប៊ុយដាប៊ី ក្នុងឆ្នាំ២០១៥ ដែលមានក្រសួងមហាផ្ទៃជាអ្នកសម្របសម្រួល។ សេចក្តីថ្លែងការណ៍នេះ បានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) ដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

ការវិវត្តជាវិជ្ជមាននេះស្របគ្នាទៅនឹងផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

ព្រះរាជាណាចក្រកម្ពុជា ក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ (Path Finding Country) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។

បន្ថែមពីនេះទៀត ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រមុខដឹកនាំរដ្ឋជាសមាជិកនៃប្រទេសអាស៊ានទាំងអស់ បានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទក្នុងអាស៊ាន នៅកិច្ចប្រជុំកំពូលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ជាងនេះទៅទៀត ក្នុងពេលថ្មីៗនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការដៃគូ ធ្វើការវិភាគស្ថានភាពជំបូង ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ក្នុងគោលបំណងកំណត់នូវអនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាងដើម្បីឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅក្នុងបរិបទកម្ពុជា ផ្អែកលើក្របខណ្ឌឆ្លើយតបថ្នាក់ជាតិគំរូ (WePROTECT-MNR) ដោយបានចេញផ្សាយនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

ជាលទ្ធផល ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញឆ្នាំ២០២១-២០២៥ បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ក្រោមការសម្របសម្រួលដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ក្រោមកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) និង ក្រសួងមហាផ្ទៃតាមរយៈកម្មវិធីអនឡាញ ZOOM។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តសម្រាប់វិស័យកិច្ចការពារកុមារ អ្នកធ្វើការពាក់ព័ន្ធ ជាពិសេសសម្រាប់កុមារ និងយុវជនគ្រប់រូប នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនឹងទទួលបានការការពារសុវត្ថិភាពកាន់តែប្រសើរ នៅពេលកំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើប នាយុគ្គសម័យឌីជីថល [២២]។

[២២] សេចក្តីប្រកាសព័ត៌មានរបស់ Unicef។ ចូលមើលថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១។ ទាញយកពី៖ https://www.unicef.org/cambodia/



## គ. ការស្វែងយល់លម្អិតពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ការយល់ដឹងអំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារតាមប្រព័ន្ធអនឡាញ មិនទាន់មានភាពទូលំទូលាយ និងច្បាស់លាស់នៅឡើយទេ។ ការស្រាវជ្រាវដែលបានរៀបចំឡើងដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) បានបង្ហាញថាមនុស្សពេញវ័យភាគច្រើន គិតថារូបភាពអាសអាភាសជាហានិភ័យដែលអាចកើតឡើងចំពោះកុមារតាមប្រព័ន្ធអនឡាញ។ ក្រៅពីនោះពួកគេ មិនបានដឹងអំពីហានិភ័យផ្សេងទៀតដែលកុមារអាចជួបប្រទះតាមប្រព័ន្ធអនឡាញនោះទេ [២៣]។ កត្តាទាំងនេះ បានចង្អុលបង្ហាញពីតម្រូវការក្នុងការអប់រំ អំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារតាមប្រព័ន្ធអនឡាញ ជាពិសេសគឺការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនានា ក្នុងការបង្រៀនបន្តពីការការពារកុមារពីហានិភ័យទាំងនោះ។

### តើអ្វីខ្លះ ជាហានិភ័យដែលអាចកើតឡើងនៅពេលកុមារប្រើប្រាស់អ៊ីនធឺណិត?

ជាការពិតណាស់ ជាទូទៅកុមារគួរត្រូវបានណែនាំឱ្យបានច្បាស់ពីឥរិយាបទតាមអនឡាញដែលមានសុវត្ថិភាពតាំងពីពេលដែលពួកគេចាប់ផ្តើមប្រើប្រាស់ដំបូង។ ការណែនាំកុមារឱ្យបានដឹងពីហានិភ័យដែលអាចកើតឡើង នៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត អាចជួយឱ្យពួកគេចេះបែងចែករវាងឥរិយាបថសមរម្យ និងមិនសមរម្យជាមួយអ្នកដទៃនៅលើអ៊ីនធឺណិត។

ហានិភ័យដែលអាចនាំឱ្យកុមារជួបប្រទះ នូវទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវបានបែងចែកជា៣ប្រភេទរួមមាន [២៤]៖




### ហានិភ័យពាក់ព័ន្ធនឹងមាតិកា (Content Risks)

កុមារអាចមើលឃើញនូវមាតិកាដែលពួកគេមិនចង់ឃើញ ឬមាតិកាដែលមានលក្ខណៈមិនសមរម្យ។ វាអាចជាប្រភេទវីដេអូ រូបភាព អត្ថបទ សារសម្លេងតាមអនឡាញ ដែលមានលក្ខណៈផ្លូវភេទអាសអាភាស ឬមានលក្ខណៈហិង្សាជាដើម។

---

[២៣] APLE (2018) "They had pictures of me" – National study on the nature and extent of online child sexual exploitation in Cambodia

[២៤] Extracted from UNICEF (2017) "Children in a Digital World" https://www.unicef.org/publications/files/SOWC__2017__ENG__WEB.pdf p.72



### ហានិភ័យទំនាក់ទំនង ( Contact Risks )

មនុស្សមួយចំនួន ប្រើប្រាស់អ៊ីនធឺណិត ជាមធ្យោបាយក្នុងការទាក់ទងកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ កុមារអាចចូលរួមដោយមិនបានដឹងខ្លួនក្នុងការប្រាស្រ័យទាក់ទងប្រកបដោយគ្រោះថ្នាក់ជាមួយអ្នកដទៃតាមអនឡាញ ហើយពួកគេអាចត្រូវបានគេបោកបញ្ឆោតឱ្យមានទំនាក់ទំនងបែបផ្លូវភេទ។ ទំនាក់ទំនងបែបផ្លូវភេទ ពេលខ្លះកើតឡើងតែតាមអនឡាញតែប៉ុណ្ណោះ ដោយមិនមានការជួបផ្ទាល់ជាមួយកុមារឡើយ។ តាមអនឡាញ ជនល្មើសអាចបង្ខំ ឬរៀបចំឱ្យកុមារធ្វើសកម្មភាពផ្លូវភេទនៅមុខកាមេរ៉ា ឬជនល្មើសអាចផលិតរូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។



### ហានិភ័យដែលកើតពីការប្រព្រឹត្តដោយផ្ទាល់ ( Conduct Risks )

ពេលខ្លះកុមារខ្លួនឯងអាចមានឥរិយាបទចូលរួមចំណែក បង្កើតនូវមាតិកាបែបហានិភ័យ ឬចូលរួមក្នុងទំនាក់ទំនងបែបហានិភ័យតាមអនឡាញ។ សកម្មភាពទាំងនោះអាចជាការផលិត បង្ហោះ ឬចែកចាយរូបភាពអាក្រាត ឬរូបភាពបែបផ្លូវភេទខ្លួនឯង និងអ្នកដទៃ ដោយមិនបានយល់ដឹងពីផលវិបាកដែលនឹងកើតមានឡើង។

ក្រៅពីហានិភ័យដែលបានបង្ហាញខាងលើ អ្នកនឹងបានស្វែងយល់បន្ថែមទៀតអំពីទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដែលនឹងបង្ហាញនៅចំណុចលម្អិតបន្តបន្ទាប់ខាងក្រោម។

## វេទិកាអនឡាញមួយចំនួនដែលកុមារនិយមប្រើប្រាស់

ការប្រើប្រាស់វេទិកាឬកម្មវិធីមួយចំនួនតាមប្រព័ន្ធអនឡាញ អាចបណ្តាលឱ្យកុមារប្រឈមទៅនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទ។ វេទិកាឬកម្មវិធីមួយចំនួនតាមប្រព័ន្ធអនឡាញដែលកុមារកំពុងប្រើប្រាស់ ក៏អាចជាមធ្យោបាយអនុញ្ញាតឱ្យជនល្មើសផ្លូវភេទលើកុមារស្វែងរកព័ត៌មានរបស់កុមារបានដែរ។ ជាងនេះទៅទៀត ជនល្មើសផ្លូវភេទលើកុមារ អាចទាញយកប្រយោជន៍ពីការប្រើប្រាស់វេទិកាតាមអនឡាញរបស់កុមារ ជាមធ្យោបាយក្នុងការចាប់ផ្តើមទាក់ទងជាមួយកុមារ ស្វែងយល់បន្ថែមពីកុមារ និងប្រើប្រាស់វេទិកាទាំងនោះក្នុងដំណើរការលួងលោមកុមារជាដើម។

នៅប្រទេសកម្ពុជា កុមារបច្ចុប្បន្ននេះ និយមប្រើប្រាស់វេទិកាឬកម្មវិធីអនឡាញមួយចំនួន ដែលអាចបណ្តាលឱ្យពួកគេងាយប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ឧទាហរណ៍នៃវេទិកា ឬកម្មវិធីតាមប្រព័ន្ធអនឡាញ ទាំងនោះរួមមាន [២៥]៖

[២៥] APLE (2018) "They had pictures of me" - National study on the nature and extent of online child sexual exploitation in Cambodia

## បណ្តាញទំនាក់ទំនងសង្គម (Social media and communication platforms)

**បណ្តាញទំនាក់ទំនងសង្គម** សំដៅទៅលើគេហទំព័រ ឬកម្មវិធីនានាដែលអនុញ្ញាតឱ្យយើងអាចចែករំលែកមាតិកាផ្សេងៗជាមួយអ្នកដទៃ រួមមានរូបភាព ឃ្លីបវីដេអូ ចំណាប់អារម្មណ៍ផ្សេងៗ ព័ត៌មាន និងមាតិកាផ្សេងៗជាច្រើនទៀត។ បណ្តាញទំនាក់ទំនងសង្គម ជាវេទិកាតាមអនឡាញដែលពេញនិយម សម្រាប់ប្រាស្រ័យទាក់ទងជាមួយមនុស្សនិងវេទិកាដទៃទៀតនៅលើអ៊ីនធឺណិត។ អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមភាគច្រើន អាចបង្ហាញនូវប្រវត្តិរូបផ្ទាល់ខ្លួន ដែលអាចចែករំលែកជាមួយមិត្តភក្តិ ឬមនុស្សដទៃទៀតដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា។ កម្មវិធីខ្លះ ក៏អាចអនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបុគ្គល ឬក្រុមផ្សេងៗទៀតតាមរយៈសារជាសំណេរ សំឡេង ឬវីដេអូផងដែរ។ អ្នកប្រើប្រាស់ អាចភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ទៅនឹងបណ្តាញទំនាក់ទំនងសង្គមដទៃទៀត ឬអាចប្រើដាច់ដោយឡែកជាលក្ខណៈឯកជនក៏បាន។

ប្រភេទវេទិកា ឬកម្មវិធីបណ្តាញទំនាក់ទំនងសង្គមជាឧទាហរណ៍ទាំងនោះរួមមាន ហ្វេសប៊ុក (Facebook) អ៊ីនស្តាក្រាម (Instagram) កម្មវិធីផ្ញើសារ (FB Messenger) កម្មវិធីឡាញ (Line) និងកម្មវិធី Skype ជាដើម។ ប្រភេទកម្មវិធីទាំងនេះ អាចឱ្យកុមារជួបប្រទះនូវហានិភ័យតាមអនឡាញ ប្រសិនបើពួកគេមិនបានយល់ដឹងពីការប្រើប្រាស់ដែលប្រកបដោយសុវត្ថិភាព។

### តើហានិភ័យទាំងនោះ មានអ្វីខ្លះ?

ប្រវត្តិរូបផ្ទាល់ខ្លួនដែលត្រូវបានបង្ហាញលើបណ្តាញទំនាក់ទំនងសង្គម អាចមាននូវព័ត៌មានផ្ទាល់ខ្លួនជាច្រើនរបស់អ្នកប្រើប្រាស់ ដែលអាចឱ្យមនុស្សមិនល្អទាញយកជាមធ្យោបាយដើម្បីទាក់ទងជាមួយកុមារ។ ម្យ៉ាងវិញទៀត តាមរយៈបណ្តាញទំនាក់ទំនងសង្គម កុមារក៏អាចមើលឃើញនូវមាតិកាដែលមានលក្ខណៈមិនសមរម្យផងដែរ។ ពេលខ្លះ តាមរយៈទំនាក់ទំនងជាលក្ខណៈឯកជនជាមួយអ្នកប្រើប្រាស់ផ្សេងទៀត ជនល្មើសក៏អាចមានឱកាសទាក់ទងជាមួយកុមារ ផ្ញើឬបញ្ជូនសារមិនសមរម្យ ឬមានលក្ខណៈបែបផ្លូវភេទ និងបង្កគ្រោះថ្នាក់ដល់កុមារ។

## វេទិកាហ្គេមអនឡាញ ( Online Gaming Communities )

ក្រៅពីបង្កប់នូវមាតិកាដែលមានលក្ខណៈហិង្សាខ្លាំង និងពេលខ្លះក៏បង្ហាញនូវមាតិកាដែលមានលក្ខណៈផ្លូវភេទ មិនសមរម្យសម្រាប់កុមារ វេទិកាហ្គេមអនឡាញ ក៏អាចឱ្យជនល្មើសទាក់ទងជាមួយកុមារ ប្រមូលនូវព័ត៌មានរបស់កុមារ និងធ្វើឱ្យកុមារជឿទុកចិត្ត មុនពេលបង្វែរការទាក់ទងជាមួយកុមារតាមរយៈបណ្តាញទំនាក់ទំនងសង្គមផ្សេងទៀត ឬស្នើសុំជួបកុមារដោយផ្ទាល់។

វេទិកាហ្គេមអនឡាញជាច្រើនក៏តម្រូវឱ្យអ្នកប្រើប្រាស់បង់ប្រាក់ផងដែរ ដែលអាចធ្វើឲ្យអ្នកប្រើប្រាស់ជំពាក់បំណុល ជាពិសេសកុមារដែលមិនមានប្រាក់សម្រាប់បង់។ កត្តានេះ ជម្រុញឱ្យកុមារស្វែងរកមធ្យោបាយផ្សេងទៀតដើម្បីខ្ចីប្រាក់ ហើយពួកគេអាចស្ថិតក្នុងស្ថានភាពងាយរងគ្រោះដោយជនល្មើសដែលមានបំណងកេងប្រវ័ញ្ចកុមារ។

វេទិកាហ្គេមអនឡាញដែលជាឧទាហរណ៍មានដូចជា៖ Mobile Legend, Bang Bang (MLBB), Rules of survivor, AK2 Player Unknown's Battleground (PUBG), GTA 5 ជាដើម។ ប្រភេទកម្មវិធីទាំងនេះ អាចឱ្យកុមារជួបប្រទះនូវហានិភ័យតាមអនឡាញ ប្រសិនបើពួកគេមិនបានយល់ដឹងពីការប្រើប្រាស់ដែលប្រកបដោយសុវត្ថិភាព។

## កម្មវិធីផ្សាយផ្ទាល់ ( Live Streaming Applications )

កម្មវិធីផ្សាយផ្ទាល់ ជាទូទៅអាចឱ្យអ្នកប្រើប្រាស់មើល និងថតវីដេអូពេលកំពុងចាក់ផ្សាយ។ កម្មវិធីមួយចំនួនថែមទាំងអនុញ្ញាតឱ្យមានការដោះដូរជាប្រាក់ ឬទម្រង់នៃការបង់ប្រាក់ផ្សេងទៀតសម្រាប់វីដេអូដែលត្រូវបានផលិតនិងចាក់ផ្សាយ។

### តើហានិភ័យទាំងនោះ មានអ្វីខ្លះ ?

កម្មវិធីផ្សាយផ្ទាល់ភាគច្រើនមានជម្រើសដែលអាចឱ្យអ្នកប្រើប្រាស់អ៊ីនធឺណិតផ្សេងទៀតបញ្ចេញមតិយោបល់ និងទាក់ទងជាមួយអ្នកបង្ហោះវីដេអូ។ លទ្ធភាពនៃការបង់ប្រាក់សម្រាប់វីដេអូ ក៏អនុញ្ញាតឱ្យជនល្មើស កេងប្រវ័ញ្ចលើកុមារតាមរយៈការបញ្ចុះបញ្ចូលឱ្យកុមារសម្តែងនៅមុខកាមេរ៉ាដើម្បីបានប្រាក់។ ម្យ៉ាងវិញទៀត ដោយសារវីដេអូផ្សាយផ្ទាល់បង្ហាញពីសកម្មភាពកំពុងប្រព្រឹត្តជាក់ស្តែង និងមិនមានការពិនិត្យជាមុន កុមារអាចមើលឃើញនូវសម្ភារៈមិនសមរម្យខណៈពេលពួកគេកំពុងមើលអ្នកដទៃផ្សាយវីដេអូផ្ទាល់។

កម្មវិធីផ្សាយផ្ទាល់ដែលជាឧទាហរណ៍រួមមាន៖ TikTok, Bigo Live, YouTube ជាដើម។ ប្រភេទកម្មវិធីទាំងនេះ អាចឱ្យកុមារជួបប្រទះនូវហានិភ័យតាមអនឡាញ ប្រសិនបើពួកគេមិនបានយល់ដឹងពីការប្រើប្រាស់ដែលប្រកបដោយសុវត្ថិភាព។

សូមចងចាំថាកម្មវិធី និងវេទិកាអនឡាញនាពេលបច្ចុប្បន្ន កំពុងផ្លាស់ប្តូរ និងរីកចម្រើនឥតឈប់ឈរ ដែលបង្កឱ្យមានផលលំបាកក្នុងការតាមដានពីអ្វីដែលកុមារធ្វើនៅពេលពួកគេអនឡាញ។ ការព្យាយាមបន្តចូលរួមតាមដានការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារតាមដែលអាចធ្វើទៅបាន និងបន្តស្វែងយល់ពីការផ្លាស់ប្តូរថ្មីៗនៃបច្ចេកវិទ្យា គឺជារឿងដែលគួរធ្វើដ៏ល្អបំផុត។

### តើអ្វីជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (Online Child Sexual Exploitation_OCSE)?

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទដែលអាចកើតឡើងចំពោះកុមារ តាមរយៈការប្រើប្រាស់អ៊ីនធឺណិត ដោយរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬបណ្តាលឱ្យកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាព ឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ [២៦]។

បើយោងតាមរបាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានរកឃើញថាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កំពុងមានការរីករាលដាលនៅប្រទេសកម្ពុជា។ ហេតុផលដែលធ្វើឱ្យបញ្ហានេះ មានការកើនឡើងគួរឱ្យព្រួយបារម្ភនោះគឺ កំណើននៃការប្រើប្រាស់អ៊ីនធឺណិតកុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃឆ្លាតវៃ ដែលកំពុងរីករាលដាលយ៉ាងឆាប់រហ័សក្នុងសហគមន៍ងាយរងគ្រោះនៅកម្ពុជា ជាពិសេសការភ្ជាប់អ៊ីនធឺណិត បណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យា ក៏បានពង្រីកខ្លួនយ៉ាងខ្លាំងក្នុងកំឡុងពេលប៉ុន្មានឆ្នាំនេះ បានសម្រួលឱ្យប្រជាជនកម្ពុជាជាងពាក់កណ្តាលនៃប្រជាជនសរុបមានទូរស័ព្ទដៃឆ្លាតវៃយ៉ាងតិចបំផុតម្នាក់១គ្រឿង [២៧]។ ស្របពេលដែលសេវា និងឧបករណ៍

[២៦] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ "គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ" ទាញយកពី៖ http://luxembourgguidelines.org/english-version/

[២៧] UNICEF 2016

ភ្ជាប់អ៊ីនធឺណិតកាន់តែទំនើប និងមានតម្លៃកាន់តែសមរម្យ ការប្រើប្រាស់មានការកើនឡើងគ្រប់ទីកន្លែង រួមទាំងនៅសហគមន៍ដែលមានចំណូលទាប ដែលបង្កជាហានិភ័យខ្ពស់គួរឱ្យកត់សម្គាល់ចំពោះកុមារ និងយុវជនវ័យក្មេង ព្រោះពួកគេជាអ្នកប្រើប្រាស់អ៊ីនធឺណិតយ៉ាងសកម្ម។ ម្យ៉ាងវិញទៀត ការយល់ដឹងតិចតួចនៅកម្ពុជាអំពីវត្តមាន និងទំហំនៃបញ្ហាកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ [២៨] ជាពិសេសការយល់ដឹងរបស់សហគមន៍នៅមានកម្រិតទាប [២៩] ក៏ជាកត្តារួមចំណែកធ្វើឱ្យបញ្ហានេះមានការកើនឡើងដែរ។ កង្វះខាតចំណេះដឹងអំពីនិន្នាការនៃបច្ចេកវិទ្យា កង្វះកិច្ចសហការជាមួយអ្នកជំនាញជាពិសេសគឺភ្នាក់ងារអនុវត្តច្បាប់ មានការលំបាកក្នុងការកំណត់អត្តសញ្ញាណជនសង្ស័យ និងសកម្មភាពប្រព្រឹត្តបទល្មើសបានបង្កភាពងាយស្រួលដល់ជនល្មើស ក្នុងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

## តើជនល្មើសកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជានរណា?

នៅមានការយល់ខុសជាច្រើន ទាក់ទងនឹងការកំណត់ថានរណាជាជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ ពេលខ្លះមានការយល់ឃើញថា ជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អាចជាជនបរទេសណាម្នាក់ ដែលប្រើប្រាស់បណ្តាញណាមួយក្នុងការទាក់ទង លួងលោមកុមារមកពីប្រទេសកំពុងអភិវឌ្ឍ។ តែផ្ទុយទៅវិញ ការគិតបែបនេះ គឺពិតជាខុសឆ្ងាយពីភាពជាក់ស្តែងខ្លាំងណាស់ [៣០]។ ជាការពិត ការកំណត់ថានរណាម្នាក់ ជាជនល្មើសផ្លូវភេទលើកុមារគឺពិតជារឿងមួយដែលពិបាក និងស្មុគស្មាញ ជាពិសេសចំពោះសាធារណជនក្នុងការកំណត់ និងបង្ការទុកជាមុន។

មិនខុសពីជនល្មើសផ្លូវភេទលើកុមារក្រៅប្រព័ន្ធអនឡាញនោះទេ ជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អាចជានរណាម្នាក់ មិនថាពួកគេជាមនុស្សចាស់ឬក្មេង ជាប្រុសឬស្រី ជាជនចម្លែកឬជាមនុស្សដែលកុមារស្គាល់ ជាជនបរទេសឬជាមនុស្សដែលរស់នៅក្នុងស្រុក។ ពួកគេ ក៏អាចជាសមាជិក/មិត្តភ័ក្តិរបស់កុមារ ហើយជាអ្នកដែលកុមារស្គាល់រួចហើយ។ ពួកគេអាចជាកុមារខ្លួនឯង ឬជាមនុស្សពេញវ័យក៏មាន។

---

[២៨] APLE 2016

[២៩] ក្រសួងកិច្ចការនារី ២០១៤

[៣០] ECPAT (2018) "Trends in online child sexual abuse material". https://www.ecpat.org/wp-content/uploads/2018/07/ECPAT-International-Report-Trends-in-Online-Child-Sexual-Abuse-Material-2018.pdf

ទោះជាយ៉ាងណាក៏ដោយ ជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងជនល្មើសផ្លូវភេទលើកុមារក្រៅប្រព័ន្ធអនឡាញក៏មានភាពខុសគ្នាមួយចំនួនដែលគួរឱ្យកត់សម្គាល់បានដែរ [៣១]

| ជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ | ជនល្មើសផ្លូវភេទលើកុមារក្រៅប្រព័ន្ធអនឡាញ |
|---|---|
| ជននោះ ពេលខ្លះទំនងជាមនុស្សដែលទទួលបានការអប់រំល្អ និងមានការងារប្រកបដោយវិជ្ជាជីវៈ | ជនល្មើសទាំងនោះ អាចមកពីគ្រប់មជ្ឈដ្ឋាន អាចមានការអប់រំទាប ឬខ្ពស់ ហើយមិនចាំបាច់មានការងារល្អនោះទេ |
| ជននោះ អាចមានអាយុជាមធ្យមចន្លោះពី ២៦ ទៅ ៣៩ឆ្នាំ | ជនល្មើសទាំងនោះ ភាគច្រើនមានអាយុលើសពី ៤០ឆ្នាំ |
| ជននោះ ទំនងជាមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីមុនមកទេ | ជននោះ ទំនងជាធ្លាប់ត្រូវបានផ្តន្ទាទោសពីមុន |
| ជនមួយចំនួន មានទំនោរទៅនឹងអារម្មណ៍ផ្លូវភេទ ប៉ុន្តែពួកគេមិនតែងតែមានតម្រូវការផ្នែកផ្លូវភេទដោយផ្ទាល់ជាមួយកុមារនោះទេ | ជនល្មើស មានទំនោររំលោភបំពានលើកុមារដោយផ្ទាល់ ជាពិសេសតម្រូវការទំនាក់ទំនងរាងកាយ |
| ដំណើរនៃការលួងលោមតាមប្រព័ន្ធអនឡាញអាចមានរយៈពេលខ្លី ជាពិសេសជននោះអាចគ្រប់គ្រងលើកុមារ ជាជាងការកសាងទំនាក់ទំនងជាមួយកុមារ | ដំណើរការនៃការលួងលោមរបស់ជនល្មើស ជាធម្មតាមានរយៈពេលយូរ ហើយអាចចំណាយពេលច្រើនឆ្នាំមុនពេលមានការរំលោភបំពានកើតឡើង |

សូមចងចាំថា ជនល្មើសផ្លូវភេទលើកុមារ មានលក្ខណៈខុសប្លែកពីគ្នាច្រើន ហើយជនទាំងនោះ ជួនកាលមិនមានលក្ខណៈដូចដែលបានកំណត់នៅផ្នែកខាងលើនោះទេ។ ទោះជាយ៉ាងនេះក៏ដោយ ការបែងចែកពីភាពខុសគ្នា រវាងជនល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញនេះ ក៏អាចជាជំនួយក្នុងការកំណត់បានលក្ខណៈជាទូទៅរបស់ជនទាំងនោះដែរ។

[៣១] Most of the information in this table has been derived from Cambridge University Press (2019) “International and Transnational Crime and Justice” edited by Mangai Natarajan, Second Edition.

## ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

នៅប្រទេសកម្ពុជា ការវិភាគស្ថានភាពមួយលើប្រធានបទ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្ហាញថា ក្នុងចំណោមកុមារ ២២០នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ម្នាក់ក្នុងចំណោម៦នាក់ ធ្លាប់ប្រឈមនឹងហានិភ័យដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលភាគច្រើនក្នុងទម្រង់នៃការលួងលោម ឬទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទពីមនុស្សពេញវ័យតាមអនឡាញ។ ការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតក្នុងចំណោមកុមារនៅកម្ពុជា បូករួមទាំងការមានកម្រិតទាបផ្នែកចំណេះដឹងរបស់ឪពុកម្ដាយ និងអ្នកថែទាំកុមារអំពីហានិភ័យផ្សេងៗ ជាហេតុនាំឱ្យមានការកើនឡើងនៃចំនួនកុមារដែលប្រឈមនឹងហានិភ័យពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញរួមមាន ការផលិតសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) ការលួងលោមតាមប្រព័ន្ធអនឡាញ (online Grooming) ការផ្ញើសារបែបរំលោភបំពានផ្លូវភេទ (Sexting) ការគំរាមខាងផ្លូវភេទ (Sextortion) និងការផ្សាយផ្ទាល់ពីការរំលោភបំពានផ្លូវភេទលើកុមារ (Live Online Child Sexual Abuse)។




### ទម្រង់ទី១៖ ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ

ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ (Online Grooming) សំដៅទៅលើសកម្មភាពជនខិលខូចដែលព្យាយាមទាក់ទងកុមារតាមប្រព័ន្ធអនឡាញ ដើម្បីកសាងទំនុកចិត្តក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពួកគេ។ ការលួងលោមទាំងនោះរួមមានការបង្ហាញនូវសម្ភារៈ អាសអាភាសដូចជា តាមរយៈការផ្ញើនូវមាតិកា សារ វីដេអូ ឬរូបភាពបែបផ្លូវភេទទៅកាន់កុមារ។ វិធីទាំងនេះអាចជួយឱ្យជនល្មើសផ្លូវភេទលើកុមារ អាចបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ ក្នុងគោលដៅបង្កើនឱកាសឱ្យកុមារបញ្ជូនសម្ភារៈផ្លូវភេទដោយខ្លួនឯងទៅឱ្យជនល្មើស [៣២]។

ខុសពីការលួងលោមក្រៅប្រព័ន្ធអនឡាញ តាមរយៈប្រព័ន្ធអនឡាញ ជនល្មើសកាន់តែមានភាពងាយស្រួលក្នុងការលួងលោម និងទទួលបានទំនុកចិត្តពីកុមារ។ ជនល្មើស ជាទូទៅទាក់ទងជាមួយកុមារ ដោយការប្រើប្រាស់កម្មវិធីជជែកកំសាន្ត (Chatrooms) ហ្គេមកំសាន្តផ្សេងៗ គេហទំព័រ ឬកម្មវិធីបណ្ដាញទំនាក់ទំនងសង្គមនានា។ ការលួងលោម អាចពាក់ព័ន្ធនឹងការបង្កើតទំនាក់ទំនងផ្នែក

[៣២] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្ដីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ" ទាញយកពី៖ http://luxembourgguidelines.org/.

អារម្មណ៍ជាមួយកុមារដើម្បីទទួលបានការទុកចិត្ត។ ពេលខ្លះជនល្មើសក៏អាចបំពេញតម្រូវការរបស់កុមារ តាមរយៈការផ្តល់ការយកចិត្តទុកដាក់ ការផ្តល់ជារង្វាន់ ឬអាចជាការបង្ខិតបង្ខំផ្លូវចិត្ត ឬជាការបន្សាំកុមារទៅនឹងសកម្មភាពផ្លូវភេទជាដើម ហើយពួកគេក៏អាចសន្យារក្សាការសម្ងាត់ ស្តីបន្ទោសកុមារដើម្បីឱ្យកុមារបន្តចូលរួមក្នុងសកម្មភាពផ្លូវភេទ និងរក្សាភាពស្ងៀមស្ងាត់ [៣៣]។




## ទម្រង់ទី២៖ រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ

រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (Child Sexual Abuse Material_CSAM) សំដៅលើសម្ភារៈដែលបង្ហាញពីកុមារក្នុងស្ថានភាពអាក្រាត ពិព័ណ៌នាដោយផ្តោតលើកេរភេទរបស់កុមារ ឬសម្ភារៈដែលព័ណ៌នាអំពីកុមារនៅក្នុងស្ថានភាពបែបអាសអាភាស។ សម្ភារៈទាំងនោះរួមមាន រូបភាព វីដេអូ អត្ថបទ និងសារសម្លេង ដែលមានលក្ខណៈបែបអាសអាភាសជាដើម [៣៤]។

### ហេតុអ្វីបានជាយើងគួរប្រើប្រាស់ពាក្យ 'រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ' ជំនួសឱ្យពាក្យ 'រូបភាព-សម្ភារៈអាសអាភាសកុមារ'?

មនុស្សទូទៅ តែងស្គាល់ពាក្យថា CSAM ជាពាក្យ 'រូបភាពអាសអាភាសកុមារ' ប៉ុន្តែពាក្យនេះមិនបានគ្រោបទាំងស្រុងពីទម្រង់នៃការកេងប្រវ័ញ្ចដែលពាក់ព័ន្ធនោះឡើយ។ ជួនកាល អាចមានការយល់ខុសថា កុមារមានការយល់ព្រមចំពោះសកម្មភាពណាមួយ ដែលអាចជាកត្តានាំឱ្យទំហំនៃបទល្មើសត្រូវបានកាត់បន្ថយ ដោយមិនបានយល់ច្បាស់ថាទង្វើទាំងនេះជាទម្រង់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**ចំណាំ៖** រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទលើកុមារ ឬរូបភាព សម្ភារៈអាសអាភាសដែលផលិតដោយកុំព្យូទ័រ  សំដៅលើសម្ភារៈនានាដែលមិនពិព័ណ៌នារូបភាពកុមារពិតនោះទេ ប៉ុន្តែពិព័ណ៌នារូបភាពកុមារដែលប្រព្រឹត្តសកម្មភាពផ្លូវភេទ ឬត្រូវគេរំលោភបំពានជាលក្ខណៈក្រាហ្វិកណាមួយដោយរាប់បញ្ចូល ទាំងតុក្កតា រូបភាពដែលផលិតដោយកុំព្យូទ័រ រូបភាពដែលគេកែសម្រួល និងការរួមបញ្ចូលគ្នា។ ទោះជារូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទលើកុមារដែលផលិតដោយកុំព្យូទ័រ មិនបង្កផលប៉ះពាល់ចំពោះកុមារជាក់ស្តែងក៏ដោយ ក៏វានៅតែមានគ្រោះថ្នាក់ដដែលពីព្រោះវាអាចត្រូវបានគេប្រើប្រាស់ដើម្បីលួងលោមកុមារក្នុងគោលបំណងកេងប្រវ័ញ្ច វាបន្តឱ្យមានទីផ្សាររូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ជាពិសេសវាអាចបណ្តាលឱ្យមានវប្បធម៌នៃការអត់ឱនចំពោះសកម្មភាពផ្លូវភេទជាមួយកុមារ [៣៥]។

[៣៣] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ ទាញយកពី៖ https://ecpat.org/search-our-library/

[៣៤] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ" ទាញយកពី៖ http://luxembourgguidelines.org/.

[៣៥] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ ទាញយកពី៖ https://ecpat.org/search-our-library/

### ការពិនិត្យលើករណីសិក្សាមួយរបស់អង្គការសកម្មភាពដើម្បីកុមារ៖

អង្គការសកម្មភាពដើម្បីកុមារ បានទទួលការរាយការណ៍ករណីមួយពាក់ព័ន្ធនឹងសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ដែលត្រូវបានគេប្រទះឃើញដោយចៃដន្យនៅលើគេហទំព័រអាសអាភាស។ អ្នកវិភាគបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអនឡាញរបស់អង្គការសកម្មភាពដើម្បីកុមារ បានវាយតម្លៃលើសម្ភារៈនោះ ហើយបានរកឃើញថាសម្ភារៈនោះបង្ហាញពីមនុស្សពេញវ័យពីប្រទេសលោកខាងលិច បានរំលោភបំពានផ្លូវភេទលើក្មេងស្រីអាស៊ីដែលមានអាយុតិចជាង ១៥ឆ្នាំ។ ដោយអនុវត្តតាមគោលការណ៍ណែនាំប្រតិបត្តិការរបស់បណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអនឡាញ ( Internet Hotline Cambodia ) អ្នកវិភាគបណ្តាញរាយកាណ៍ពិសេសតាមប្រព័ន្ធអនឡាញ បានចាត់វិធានការសមស្របក្នុងការលុបមាតិកានោះចេញ។ បន្ទាប់មកអ្នកវិភាគបណ្តាញរាយកាណ៍ពិសេសតាមប្រព័ន្ធអនឡាញ បានធ្វើការវិភាគ និងកំណត់ទីតាំង។ ជាលទ្ធផលគេហទំព័រនោះត្រូវបានរកឃើញថាបានបង្ហោះដោយម្ចាស់នៅក្រៅប្រទេស ដែលតម្រូវឱ្យមានការជូនដំណឹងទៅកាន់បណ្តាញរាយការណ៍នៃប្រទេសនោះ ដើម្បីចាត់វិធានការបន្ថែម។ មាតិកានៃគេហទំព័រនោះ ក៏ត្រូវបានបញ្ជូនទៅកាន់INHOPE តាមរយៈប្រព័ន្ធ ICCAM ដើម្បីពិនិត្យមើលថាតើមាតិកានោះត្រូវបានរាយការណ៍រួចហើយឬនៅ ហើយមានចំណាត់ការណាមួយត្រូវបានធ្វើហើយឬនៅ ឬក៏មាតិកានេះទើបតែត្រូវបានរាយការណ៍។ ជាលទ្ធផល ក្នុងរយៈពេល ២៤ ម៉ោង ខ្លឹមសារដែលត្រូវបានចាត់ថ្នាក់ជារូបភាព សម្ភារៈរំលោភបំពានផ្លូវភេទ ( CSAM ) ត្រូវបានដកចេញពីគេហទំព័រ។





## ទម្រង់ទី៣៖ ការផ្ញើសារបែបផ្លូវភេទ

ការផ្ញើសារបែបផ្លូវភេទ (Sexting) គឺជាសកម្មភាពនៃការផ្ញើ ឬទទួលរូបភាពបែបផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងទៅឱ្យអ្នកដទៃផ្សេងទៀត។ ពេលខ្លះ ការផ្ញើ ឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯង ត្រូវបានធ្វើឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើងបន្ទាប់ពីទទួលរងការគំរាមកំហែង ការដាក់សម្ពាធ ការរៀបចំឡើង និង/ឬការបង្ខិតបង្ខំពីមនុស្សម្នាក់ទៀត [៣៦]។

ជាទូទៅ កុមារមិនបានដឹងថា នៅពេលដែលអ្វីមួយត្រូវបានផ្ញើតាមអ៊ីនធឺណិត វាអាចពិបាកនឹងលុបចេញជាពិសេសនៅពេលដែលរូបភាពត្រូវបានផ្ញើចេញ រូបភាពទាំងនោះក៏អាចត្រូវបានគេចម្លង ឬចែករំលែកបានយ៉ាងងាយស្រួល ហើយកុមារខ្លួនឯង នឹងបាត់បង់ការគ្រប់គ្រងភ្លាមៗលើរូបភាពទាំងនោះ។ រូបភាពទាំងនោះ អាចនឹងស្ថិតក្រោមការគ្រប់គ្រងដោយជនល្មើសផ្លូវភេទលើកុមារ។ ជារឿយៗ ជនល្មើសផ្លូវភេទលើកុមារតែងមានបណ្តុំរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទ ហើយការកើនឡើងនៃរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទទាំងនោះ ប្រហែលជាអាចមានប្រភពចេញពីការផ្ញើសារបែបផ្លូវភេទ ហើយក្រោយមកត្រូវបានចែកចាយបន្តដោយភាគីទីបី និងបានផ្សព្វផ្សាយនៅលើបណ្តាញអ៊ីនធឺណិត [៣៧]។

រូបភាព/វីដេអូ អាចត្រូវបានថតដោយប្រើឧបករណ៍ផ្សេងៗគ្នា។ ជាញឹកញាប់ទូរស័ព្ទចល័តត្រូវបានគេប្រើប្រាស់ ដើម្បីផលិតសម្ភារៈទាំងនោះ ហើយត្រូវបានចែកចាយតាមរយៈការផ្ញើសារ ការជជែកកំសាន្តតាមអ៊ីនធឺណិត ឬតាមកម្មវិធីបណ្តាញទំនាក់ទំនងសង្គម។

ការផ្ញើសារបែបផ្លូវភេទ ជាបញ្ហាចំបងព្រោះថាជាញឹកញាប់កុមារមិនបានយល់ដឹងអំពីផលវិបាកដែលអាចកើតមានពីការប្រព្រឹត្តរបស់ពួកគេ ហើយពួកគេមិនបានដឹងពីវិធានការណាមួយដើម្បីលាក់បាំងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់ពួកគេឡើយ។ ការផ្ញើសារបែបផ្លូវភេទ ក៏អាចបង្កជាបញ្ហាកាន់តែធ្ងន់ នៅពេលដែលរូបភាព សម្ភារៈដែលបានផលិតទាំងនោះ ពាក់ព័ន្ធនឹងបទល្មើស ឬ

[៣៦] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ" ទាញយកពី៖ http://luxembourgguidelines.org/.

[៣៧] Ibid p.25

ពាក់ព័ន្ធនឹងការរំលោភបំពានជាដើម។ ការផ្ញើសារបែបផ្លូវភេទ អាចធ្វើឱ្យកុមារងាយរងគ្រោះ ឬក្លាយជាជនរងគ្រោះនៃការធ្វើបាបខាងផ្លូវភេទ និងការគំរាមបែបផ្លូវភេទ ហើយពេលខ្លះទៀត រូបភាពរបស់ពួកគេត្រូវបានគេថតចម្លង ឬប្រមូលទុកជាមួយបណ្តុំរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារផ្សេងទៀត [៣៨]។




## ទម្រង់ទី៤៖ ការគំរាមបែបផ្លូវភេទ

ការគំរាមបែបផ្លូវភេទ (Sextortion) គឺជាទង្វើដែលជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់សម្ភារៈរំលោភបំពានផ្លូវភេទដែលបានទទួលពីកុមារ តាមរយៈការផ្ញើ ឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯង ដើម្បីគំរាមកុមារឱ្យបញ្ជូនសម្ភារៈផ្លូវភេទបន្ថែមទៀតដល់ពួកគេ ដើម្បីជួបផ្ទាល់ក្នុងគោលបំណងផ្លូវភេទ ឬដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងទៀតដូចជា លុយកាក់ ឬការគ្រប់គ្រង លើកុមារជាដើម [៣៩]។

ការគំរាមបែបផ្លូវភេទ អាចពាក់ព័ន្ធនឹងការទាមទាររបស់ជនល្មើស ដើម្បីទទួលបាននូវសកម្មភាពផ្លូវភេទដែលកុមារមិនចង់ធ្វើ ដូចជាការបង្ហាញឱ្យឃើញផ្នែកឯកជននៃរាងកាយរបស់កុមារ ការថតរូបអាសអាភាសជាដើម។ ការគំរាមបែបផ្លូវភេទ ក៏អាចបង្ហាញតាមរយៈវិធីសាស្រ្តដែលប្រើប្រាស់ដើម្បីទទួលបានរបស់របរ សេវាកម្មនានា ឬប្រាក់កាសជាដើម។ ឧទាហរណ៍ជនល្មើសអាចចូលមើល ឬប្រើរូបភាពដែលកុមារថតដោយខ្លួនឯង ក្នុងការគំរាមទារប្រាក់ពីកុមារ [៤០]។

[៣៨] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ ទាញយកពី៖ https://ecpat.org/search-our-library/

[៣៩] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ"  ទាញយកពី៖ http://luxembourgguidelines.org/.

[៤០] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ ទាញយកពី៖ https://ecpat.org/search-our-library/

**ការពិនិត្យលើករណីសិក្សាមួយរបស់អង្គការសកម្មភាពដើម្បីកុមារ៖**

កុមារីអាយុ១៥ឆ្នាំម្នាក់ បានទទួលការស្នើសុំធ្វើជាមិត្តនៅលើ Facebook ពីជនម្នាក់ដែលមើលទៅហាក់ដូចជាមានអាយុស្របាលនាងដែរ តាមរយៈប្រូហ្វាល (Profile) របស់ជននោះ។ នាងបានសម្រេចចិត្តយល់ព្រមធ្វើជាមិត្តជាមួយបុរសនោះ ហើយពួកគេក៏បានចាប់ផ្តើមជជែកជាមួយគ្នាទៅវិញទៅមកតាមកម្មវិធី Facebook messenger។ ក្រៅពីការផ្ញើសារ នាងក៏បានផ្ញើរូបថតខ្លះៗរបស់នាងឱ្យបុរសនោះផងដែរ។ ដោយប្រើប្រាស់កម្មវិធី Photoshop បុរសនោះបានកែច្នៃរូបថតដែលនាងផ្ញើមក ទៅជារូបភាពអាក្រាត។ បន្ទាប់មក ជននោះ បានគំរាមផ្ញើរូបថតទាំងនោះទៅឱ្យមិត្តភក្តិក្នុងហ្វេសប៊ុកទាំងអស់របស់នាង ប្រសិនបើនាងមិនផ្ញើរូបថតអាក្រាតពិតរបស់ខ្លួនមកឱ្យគាត់។ ដោយភាពភ័យខ្លាច នាងក៏សម្រេចចិត្តផ្ញើរូបថតអាក្រាតពាក់កណ្តាលខ្លួនរបស់នាងឱ្យទៅបុរសនោះ ប៉ុន្តែជនល្មើសមិនបានបញ្ឈប់ត្រឹមនេះទេ ជននោះក៏បន្តទាមទាររូបអាក្រាតបន្ថែមទៀត ហើយសុំឱ្យនាងមកជួបផ្ទាល់។ កុមារី មានការតានតឹង និងភ័យខ្លាចខ្លាំងណាស់ រហូតព្យាយាមធ្វើអត្តឃាត។ ជាសំណាងល្អ នាងត្រូវបានជួយសង្គ្រោះទាន់ពេលវេលា។

ក្រោយមានការរាយការណ៍ដោយអនាមិកមកកាន់បណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិតរបស់អង្គការសកម្មភាពដើម្បីកុមារ (Internet Hotline Cambodia) ក្រុមការងាររបស់អង្គការសកម្មភាពដើម្បីកុមារ អាចស្វែងរក និងទាក់ទងទៅកាន់កុមារីដើម្បីផ្តល់ការប្រឹក្សា និងការគាំទ្រភ្លាមៗ ក៏ដូចជាជួយដល់គ្រួសារនាងក្នុងការដាក់ពាក្យបណ្តឹង។ ចំណែកកុមារីត្រូវបានបញ្ជូនទៅទទួលការថែទាំបន្ថែមពីអង្គការដៃគូផ្សេងទៀត។ ជាលទ្ធផល ស្ថានភាពផ្លូវចិត្តរបស់កុមារី មានភាពប្រសើរឡើងវិញគួរឱ្យកត់សម្គាល់ ហើយនាងលែងគិតពីការចង់ធ្វើអត្តឃាតទៀតហើយ។



## ទម្រង់ទី៥៖ ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ

ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ ( Live Online Child Sexual Abuse ) សំដៅលើការផ្សាយផ្ទាល់ពីសកម្មភាពរំលោភបំពានផ្លូវភេទពាក់ព័ន្ធកុមារ ឬការឱ្យកុមារសម្តែងបែបផ្លូវភេទនៅមុខកាម៉េរា( អាចក្នុងស្ថានភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ ) ពេលខ្លះជនល្មើសផ្លូវភេទលើកុមារអាចផ្តល់ជាប្រាក់ដល់កុមារផ្ទាល់ អ្នកសម្របសម្រួល ឬអន្តរការីដើម្បីដោះដូរជាមួយនឹងសកម្មភាពនោះ [៤១]។

ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់ដែលកំពុងលេចឡើងនូវការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ដែលពាក់ព័ន្ធនឹងការមើល និងការផ្សាយផ្ទាល់វីដេអូអំពីកុមារសម្តែងសកម្មភាពផ្លូវភេទនៅមុខវ៉ែបខែម ឬម៉ាស៊ីនថតរបស់ទូរស័ព្ទដែលសម្រាប់មនុស្សពេញវ័យ ដើម្បីផ្តោះប្តូរនឹងលាភការជាមួយកុមារ ឪពុកម្តាយ ឬឈ្មួញកណ្តាល [៤២]។ លើកលែងប្រទេសហ្វីលីពីនចេញ គឺមានការពិភាក្សាគ្នាតិចតួចអំពីភាពងាយរងគ្រោះរបស់កុមារនៅក្នុងតំបន់អាស៊ាន ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មផ្សាយផ្ទាល់សម្រាប់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ការឆ្លើយតបជាច្រើនចំពោះការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ក្នុងចំណោមរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ប៉ុន្តែបានមើលរំលងការរីកចម្រើនយ៉ាងឆាប់រហ័សនៃកម្មវិធីផ្សាយផ្ទាល់ ដូចជា Bigo Live, Cube TV, Magic Video, Blued, Live Chat, App Live ក្នុងចំណោមកម្មវិធីផ្សេងៗទៀត។ កម្មវិធីទាំងនេះ ភាគច្រើនជាកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ដែលអ្នកប្រើប្រាស់ អាចផ្សាយផ្ទាល់អំពីផ្នែកមួយចំនួននៃជីវិតប្រចាំថ្ងៃរបស់ខ្លួន។ ទោះបីជាយ៉ាងណា កម្មវិធីទាំងនេះភាគច្រើនត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង សម្រាប់ជាមធ្យោបាយទំនាក់ទំនងជាមួយជនរងគ្រោះ និងចែករំលែកសម្ភារៈជាលក្ខណៈកេងប្រវ័ញ្ច [៤៣]។ នៅពេលបានទំនាក់ទំនងគ្នាហើយ អ្នកប្រើប្រាស់មានជម្រើសក្នុងការឈានទៅដល់ការជជែកជាលក្ខណៈឯកជន ហើយការកេងប្រវ័ញ្ច និងការរំលោភបំពានក៏អាចកើតមានឡើង និងមានការថតរូប សម្លេងទុក ក្នុងពេលជាមួយគ្នានោះដែរ។

---

[៤១] ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ " គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ"  ទាញយកពី៖ http://luxembourgguidelines.org/.

[៤២] Terre des Hommes-Netherlands. (2018).

[៤៣] Europol. (2017).

## បច្ចេកវិទ្យាមួយចំនួនទាក់ទងនឹងអ៊ីនធឺណិត និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

តើបច្ចេកវិទ្យាអ្វីខ្លះ ដែលអាចជាមធ្យោបាយបណ្តាលឱ្យជនល្មើសផ្លូវភេទលើកុមារ អាចកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញបាន? ហើយតើវាជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះ ដល់ការស៊ើបអង្កេតបទល្មើសប្រភេទនេះ?

### ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (Internet Service Provider_ ISP)

ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) គឺជាក្រុមហ៊ុនដែលផ្តល់សិទ្ធិឱ្យអ្នកប្រើប្រាស់អ៊ីនធឺណិតចូលប្រើប្រាស់សេវាអ៊ីនធឺណិតបាន។ ឧបករណ៍ ICT របស់អ្នក ដូចជា ទូរស័ព្ទដៃវៃឆ្លាត កុំព្យូទ័រថេបប្លេត ជាដើម មិនអាចភ្ជាប់អ៊ីនធឺណិតដោយផ្ទាល់ដោយមិនចាំបាច់ភ្ជាប់ទៅកាន់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតជាមុនបានឡើយ។ ដំបូង ឧបករណ៍ទាំងនេះ ត្រូវភ្ជាប់ជាមួយបណ្តាញក្នុងកន្លែងមួយ ឬ Router (ដូចជា បណ្តាញ Wifi ជាដើម ប្រសិនបើឧបករណ៍នោះប្រើប្រាស់អ៊ីនធឺណិតចល័ត) ហើយបន្ទាប់មក បណ្តាញនោះនឹងភ្ជាប់ទៅកាន់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត។ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ដើរតួនាទីជាច្រកផ្លូវចេញចូលសម្រាប់ឧបករណ៍ដើម្បីចូលទៅកាន់អ៊ីនធឺណិត ហើយធានាថាព័ត៌មានទាំងអស់ នឹងត្រូវបានបញ្ជូនទៅកាន់ឧបករណ៍នៅលើបណ្តាញ និងទីតាំងត្រឹមត្រូវដោយប្រើអាសយដ្ឋានអាយភីរបស់ឧបករណ៍ ICT ទាំងនោះ [៤៤]។

### អាសយដ្ឋានអាយភី-IP Address (Internet Protocol Address)

អាសយដ្ឋានអាយភី–IP Address គឺជាបណ្តុំនៃលេខបួនដុំ ដែលបែងចែកគ្នាដោយចំណុច។ អាសយដ្ឋានអាយភី–IP Address គឺជាអាសយដ្ឋានកំណត់អត្តសញ្ញាណ ឬជាហត្ថលេខាដែលមានតែមួយគត់របស់ឧបករណ៍ ដែលធ្វើឱ្យឧបករណ៍នោះអាចត្រូវបានគេកំណត់អត្តសញ្ញាណបង្ហាញពីទីតាំងរបស់ឧបករណ៍ និងញែកឧបករណ៍នោះពីឧបករណ៍ផ្សេងៗទៀត ដែលត្រូវបានភ្ជាប់នឹងអ៊ីនធឺណិត។ រាល់ឧបករណ៍នីមួយៗ មានអាសយដ្ឋានអាយភីផ្ទាល់ខ្លួន មិនថាវាជាកុំព្យូទ័រ ទូរស័ព្ទ ទូរទស្សន៍ឬជាឧបករណ៍ផ្សេងៗទៀតក៏ដោយ ឱ្យតែបានតភ្ជាប់អ៊ីនធឺណិត។ អាសយដ្ឋានអាយភី–IP Address អនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងឧបករណ៍នានា និងធ្វើឱ្យអ្នកប្រើប្រាស់អ៊ីនធឺណិត អាចបញ្ជូន និងទទួលទិន្នន័យ ហើយធានាថាព័ត៌មាននៃការប្រាស្រ័យទាក់ទងគ្នា និងទិន្នន័យទៅដល់គោលដៅត្រឹមត្រូវ។ ជាងនេះទៅទៀត អាសយដ្ឋានអាយភី ក៏បង្ហាញពីព័ត៌មាន ដូចជាទីតាំងឧបករណ៍ និងថាតើអ្នកផ្តល់សេវាកម្មអ៊ីនធឺណិតណាមួយ ដែលភ្ជាប់សេវាអ៊ីនធឺណិតឱ្យឧបករណ៍នោះ។ វិធីសាស្រ្តនេះត្រូវបានប្រើប្រាស់ជាសកល ហើយមានដំណើរការដូចគ្នារាល់គ្រប់ឧបករណ៍ ឬទីកន្លែងទាំងអស់។

[៤៤] ការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាឆ្នាំ២០១៩ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

នៅពេលអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារ ភ្ជាប់អ៊ីនធឺណិត ពួកគេប្រើឧបករណ៍នានាដែលមានអាសយដ្ឋានអាយភី។ អាសយដ្ឋានអាយភីទាំងនេះ បន្សល់ទុកស្នាម ឬដាននៃសកម្មភាពអ៊ីនធឺណិត ដែលអាចផ្តល់ជូនសមត្ថកិច្ចនូវឱកាសដើម្បីបង្ក្រាបនិងអាចកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយណាដែលបានប្រើឧបករណ៍នេះក្នុងការប្រព្រឹត្តបទល្មើស ជាពិសេសករណីនៃការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញក្នុងទម្រង់ចែកចាយសម្ភារៈរំលោភបំពានផ្លូវភេទតាមអនឡាញ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកប្រព្រឹត្តបទល្មើសខ្លះ ក៏អាចប្រើវិធីសាស្ត្រមួយចំនួនដើម្បីលាក់បាំងអាសយដ្ឋានអាយភីរបស់ពួកគេដែរ ដែលជាហេតុធ្វើឱ្យការកំណត់អត្តសញ្ញាណ និងកំណត់ទីតាំងរបស់អ្នកប្រព្រឹត្តបទល្មើស មានការលំបាក ជាពិសេសអ្នកអនុវត្តច្បាប់ ជួបប្រទះបញ្ហាប្រឈមក្នុងការស៊ើបអង្កេតករណីនៃការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ [៩៥]។

## បណ្តាញ Peer-to-Peer (P2P)

បណ្តាញ Peer-to-Peer ( P2P ) ជាវិធីដែលអ្នកប្រើប្រាស់អាចចែករំលែកឯកសារដោយផ្ទាល់រវាងមនុស្សពីរនាក់ ឬច្រើននាក់ដោយមិនចាំបាច់រក្សាទុកឯកសារទាំងនោះនៅលើ Server កណ្តាល។

បណ្តាញនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ផ្ទេរឯកសារពីអាសយដ្ឋាន IP មួយទៅអាសយដ្ឋាន IP មួយទៀតដោយមិនបង្ហាញអត្តសញ្ញាណនៃបណ្តាញរបស់ពួកគេ ឬឧបករណ៍ដែលពួកគេកំពុងប្រើប្រាស់នោះឡើយ [៩៦]។ បណ្តាញ Peer-to-Peer ( P2P ) ត្រូវបានប្រើប្រាស់ជាទូទៅដោយជនល្មើសផ្លូវភេទលើកុមារក្នុងការចែកចាយ និងការកាន់កាប់សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ។ ទោះជាយ៉ាងនេះក៏ដោយ ភាពជឿនលឿននៃបច្ចេកវិទ្យា និងវិធីសាស្ត្រក្នុងការបំប្លែងទិន្នន័យជាកូដ ( Encryption Methods ) បានបង្ហាញពីការផ្លាស់ប្តូរវិធីសាស្ត្ររបស់ជនល្មើសពីការប្រើប្រាស់បណ្តាញ Peer-to-Peer ( P2P ) ទៅជាវេទិកាផ្សេងទៀតក្នុងគោលបំណងចែកចាយសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ( CSAM ) ដូចជាតាមរយៈវេទិកានៅលើគេហទំព័រងងឹត ( Dark Web ) [៩៧]។

[៩៥] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ។
ទាញយកពី៖ https://ecpat.org/search-our-library/

[៩៦] ការវិភាគស្ថានភាពដំបូងស្តីពិការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាឆ្នាំ២០១៩ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

[៩៧] EUROPOL (2016) “Internet Organized Crime Threat Assessment” https://static.rasset.ie/documents/news/europol-iocta-web-2016.pdf

## ការបំប្លែងទិន្នន័យជាកូដ (Encryption)

ការបំប្លែងទិន្នន័យជាកូដ (Encryption) ជាយុទ្ធសាស្ត្រដ៏សាមញ្ញ និងមានប្រយោជន៍បំផុតមួយ ដែលត្រូវបានប្រើប្រាស់ ដើម្បីធានាសុវត្ថិភាពនៃព័ត៌មានឯកជនរបស់យើង នៅពេលយើងមានទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិត។ ការបំប្លែងទិន្នន័យជាកូដដើម្បីការពារពីការប្រើ ដោយគ្មានសិទ្ធិអនុញ្ញាត គឺជាមធ្យោបាយនៃការក្លែង ឬលាក់បាំងសារ ឬអត្ថបទដោយអនុវត្តតាមជំហានបន្តបន្ទាប់នៃកម្មវិធីកុំព្យូទ័រ។ ដូចនេះបើសារអត្ថបទធ្លាក់ទៅក្នុងដៃជនដទៃដែលជាអ្នកមិនត្រូវទទួលនោះ បុគ្គលដែលមើល ឬអានសារនោះនឹងមិនអាចយល់អំពីអ្វីៗដែលសរសេរឡើយ ព្រោះវាត្រូវបានបំប្លែងទៅជាសារកូដ។ បុគ្គលដែលជាអ្នកទទួលបានសារ ត្រូវមានលេខ ឬអក្សរសម្ងាត់សម្រាប់ដោះកូដដែលអ្នកដទៃមិនដឹង ហើយលេខ ឬអក្សរសម្ងាត់នោះត្រូវផ្តល់ជូនទៅអ្នកទទួលដោយអ្នកផ្ញើសារដើម្បីអាចដោះកូដ ឬទទួលបានសារដើមមកវិញ។ ដំណើរការនេះ ហៅថា ការដោះកូដ (Decryption)[៤៨]។

### ខាងក្រោមនេះជាឧទាហរណ៍នៃដំណើរការបំប្លែងទិន្នន័យជាកូដ និងការដោះកូដ៖

*សូមកត់សម្គាល់ថា នេះជាឧទាហរណ៍មួយ ហើយនៅមានវិធីផ្សេងទៀតដើម្បីបម្លែងកូដ និងដោះកូដទិន្នន័យ




ការបំប្លែងទិន្នន័យជាកូដ (Encryption) ផ្តល់អត្ថប្រយោជន៍ក្នុងការការពារព័ត៌មានតាមអនឡាញ និងឯកជនភាពរបស់យើងក៏ពិតមែន ប៉ុន្តែមធ្យោបាយនេះ ក៏ត្រូវបានមនុស្សមិនល្អប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសផងដែរ។ ជនល្មើសផ្លូវភេទលើកុមារ ប្រើប្រាស់វិធីបំប្លែងទិន្នន័យជាកូដ ដើម្បីលាក់អត្តសញ្ញាណ និងការប្រព្រឹត្តរបស់ពួកគេពីអាជ្ញាធរ។ ការបំប្លែងកូដទិន្នន័យ រួមចំណែកធ្វើឱ្យមានភាពស្មុគស្មាញបន្ថែមចំពោះការស៊ើបអង្កេតរបស់មន្ត្រីអនុវត្តច្បាប់ ដោយសារការប្រមូលភស្តុតាងនៃការកេងប្រវ័ញ្ចតាមអនឡាញ មានភាពលំបាកខ្លាំង ជាពិសេសការផ្សាយផ្ទាល់ពីសកម្មភាពនៃការរំលោភបំពានផ្លូវភេទលើកុមារ។

[៤៨] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ។ ទាញយកពី៖ https://ecpat.org/search-our-library/

## The Onion Router-TOR

The Onion Router-TOR ជាវិធីមួយក្នុងចំណោមវិធីដែលជនល្មើសផ្លូវភេទលើកុមារ ប្រើដើម្បីលាក់បាំងអត្តសញ្ញាណរបស់ពួកគេ។ TOR បង្វែរចរាចរណ៍អ៊ីនធឺណិត ឱ្យឆ្លងកាត់បណ្តាញមួយផ្សេងទៀតដែលលាក់ទីកន្លែង ឬអត្តសញ្ញាណរបស់អ្នកប្រើប្រាស់។ ជំនួសដោយការធ្វើចរាចរណ៍ដោយផ្ទាល់ ដូចជាចូលទៅកាន់គេហទំព័រផ្សេងៗ ឬប្រើប្រាស់កម្មវិធីសាររហ័ស (Instant Messages) ដោយឆ្លងកាត់វិថីអ៊ីនធឺណិតដែលជាក់លាក់ហើយអាចត្រូវបានគេដឹងដោយងាយស្រួល TOR ធ្វើដំណើរឆ្លងកាត់វិថីអ៊ីនធឺណិតដែលតែងតែប្រែប្រួល ដែលមិនអាចត្រូវបានគេតាមដានរកឃើញឡើយ។

ការតភ្ជាប់របស់ TOR ត្រូវបានចាក់សោរដោយកូដ ដែលមិនអាចឱ្យគេដឹងពីអាសយដ្ឋានអាយភីរបស់អ្នកបាននោះឡើយរាប់តាំងពីប្រភពដើម ទៅកាន់ទីតាំង ឬគេហទំព័រដែលចង់មើល គឺមិនមានប្រភពច្បាស់លាស់ទេថាតើទិន្នន័យនោះមកពីកន្លែងណា ឬទៅកន្លែងណា។

ជនល្មើសផ្លូវភេទលើកុមារ ប្រើប្រាស់ TOR ដើម្បីចែករំលែករូបភាព សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ហើយអនុញ្ញាតឱ្យពួកគេភ្ជាប់ទំនាក់ទំនងជាមួយជនរងគ្រោះដោយអនាមិក។ ជនល្មើសផ្លូវភេទលើកុមារ អាចលាក់អត្តសញ្ញាណរបស់ពួកគេ ដែលធ្វើឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងមន្ត្រីអនុវត្តច្បាប់មិនអាចរកពួកគេឃើញ[៤៩]។

## គេហទំព័រងងឹត (The Dark Web)

គេហទំព័រងងឹត គឺជាផ្នែកមួយនៃបណ្តាញទូទាំងពិភពលោក (World Wide Web) ដែលខ្លឹមសាររបស់វាមិនត្រូវបានរៀបចំជាបញ្ជីដោយកម្មវិធីបើកអ៊ីនធឺណិតជាទូទៅដូចជា Chrome ឬ Firefox ឡើយ។ គេហទំព័រងងឹត មានគេហទំព័រដែលអាចមើលឃើញជាសាធារណៈបាន តែលុះត្រាតែតាមរយៈការប្រើប្រាស់កម្មវិធីអ៊ីនធឺណិតពិសេសប៉ុណ្ណោះ (ដូចជា ToR ឬ Freenet) ដែលកម្មវិធីទាំងនេះពឹងផ្អែកលើបណ្តាញកុំព្យូទ័រ ដែលមានអន្តរទំនាក់ទំនងគ្នាដោយអនាមិកនៅជុំវិញពិភពលោក ដើម្បីបង្ហោះខ្លឹមសាររបស់វា។ បណ្តាញគេហទំព័រងងឹត មានចេតនាលាក់បាំងអាសយដ្ឋានIP របស់អ្នកប្រើប្រាស់ជាអនាមិក ដោយគ្មាននរណាម្នាក់នៅក្នុងបណ្តាញស្គាល់ ឬឃើញឡើយរាប់បញ្ចូលទាំងរដ្ឋាភិបាល និងស្ថាប័នអនុវត្តច្បាប់ផងដែរ។ ប៉ុន្មានឆ្នាំថ្មីៗនេះ គេហទំព័រងងឹត ត្រូវបានជ្រើសរើសយកទៅប្រើប្រាស់ដោយបុគ្គលដែលមានបំណងប្រើប្រាស់វា សម្រាប់ធ្វើសកម្មភាពខុសច្បាប់ មានដូចជាអំពើជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងសេវាកម្មខុសច្បាប់ផ្សេងទៀត ជាពិសេសជននិយមរួមភេទជាមួយកុមារ ក៏ប្រើប្រាស់គេហទំព័រងងឹតសម្រាប់ទាក់ទងគ្នាដោយអនាមិក ព្រមទាំងចែករំលែករូបភាព សម្ភារៈរំលោភបំពានផ្លូវភេទកុមារ។

ទម្រង់នៃរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទកុមារដែលមានលក្ខណៈហិង្សាខ្លាំង ហើយជនរងគ្រោះមានអាយុវ័យក្មេង ត្រូវបានរកឃើញច្រើននៅតាមបណ្តាញងងឹត ដែលបង្កការលំបាកដល់អ្នកអនុវត្តច្បាប់ក្នុងការកំណត់បទល្មើសទាំងនោះ[៥០]។

---

[៤៩] តារាងព័ត៌មានស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផលិតដោយអង្គការ ECPAT អន្តរជាតិ។
ទាញយកពី៖ https://ecpat.org/search-our-library/

[៥០] ការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាឆ្នាំ២០១៩ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ



## ឃ. ការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត ដូចជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជាដើម បានក្លាយទៅជាបញ្ហាសកល។ អ៊ីនធឺណិតអាចឱ្យជនល្មើសផ្លូវភេទលើកុមារ កេងប្រវ័ញ្ចលើកុមារតាមទម្រង់ផ្សេងៗ ដែលបង្កើតនូវភាពស្មុគស្មាញដល់ភ្នាក់ងារ អនុវត្តច្បាប់ និងទាមទារឱ្យមានកិច្ចសហការជាអន្តរជាតិក្នុងដំណើរការស៊ើបអង្កេត។ កិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិក្នុងដំណើរការស៊ើបអង្កេត គឺជាជំហានដ៏មានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត រួមជាមួយភ្នាក់ងារអនុវត្តច្បាប់ មានការលំបាកក្នុងការកំណត់អត្តសញ្ញាណជនសង្ស័យ និងសកម្មភាពប្រព្រឹត្តបទល្មើស បានបង្កឱ្យការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ អនឡាញ នៅតែបន្តកើតមាន។

### តើអ្វីជាឧបសគ្គសំខាន់ៗក្នុងកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ?

តាមរយៈភស្តុតាងបានមកពីសហគមន៍ និងការពិភាក្សាស៊ីជម្រៅជាមួយមន្ត្រីអនុវត្តច្បាប់ជាតិ និងអន្តរជាតិ ហាក់ដូចជាមានឧបសគ្គដែលអាចកើតមានមួយចំនួនចំពោះ ការកំណត់អត្តសញ្ញាណ ការស៊ើបអង្កេត និងការផ្តន្ទាទោសបទល្មើសទាក់ទងនឹង កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅប្រទេសកម្ពុជា។

**ឧបសគ្គទាំងនោះរួមមាន [៥១]៖**

### ១. កង្វះចំណេះដឹងអំពីឧបករណ៍ ICT និងនិន្នាការនៃបច្ចេកវិទ្យា៖

ការយល់ដឹងរបស់មន្ត្រីអំពីបច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ និងនិន្នាការនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុង ចំណោមយុវវ័យនៅមានកម្រិត។ ការធ្វើការងារជាមួយការកេងប្រវ័ញ្ចកុមារនៅក្នុងបរិយាកាសអ៊ីនធឺណិត មានការលំបាកច្រើន ហើយជាញឹកញាប់ពោរពេញទៅដោយភាពខ្វះចន្លោះគួរឱ្យកត់សម្គាល់។ កុមារ ឬ មនុស្សវ័យក្មេង មានចំណេះដឹងច្រើនជាងមន្ត្រីដែលកំពុងធ្វើការងារសម្រាប់ឆ្លើយតបចំពោះបទល្មើស ទាក់ទងនឹងអ៊ីនធឺណិត។ ហេតុនេះ ដោយមិនមានចំណេះដឹងអំពីបរិយាកាសអ៊ីនធឺណិតរបស់យុវវ័យ ឬ អំពីវិធីសាស្ត្រទូទៅ ដែលជនខិលខូចប្រើប្រាស់ ដើម្បីផ្តោតគោលដៅលើយុវវ័យ ការឆ្លើយតបចំពោះការ គំរាមកំហែងតាមអ៊ីនធឺណិតដែលអាចកើតមាន និងការស៊ើបអង្កេតករណីទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្រិតមូលដ្ឋាន គឺស្ទើរតែមិនអាចធ្វើបានឡើយ។

[៥១] ការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាឆ្នាំ២០១៩ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

### ២. កង្វះធនធាន នៅសហគមន៍មូលដ្ឋាន៖

ដោយសារកង្វះការយល់ដឹងអំពីបច្ចេកវិទ្យានៅថ្នាក់មូលដ្ឋាន ស្ទើរតែគ្រប់បទល្មើសទាក់ទងទៅនឹងកុំព្យូទ័រទាំងអស់ ត្រូវបានបញ្ជូនទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៅរាជធានីភ្នំពេញ។ កិច្ចការនេះទាមទារឱ្យមានមន្ត្រី ធ្វើការបញ្ជាក់អំពីព័ត៌មានដែលពាក់ព័ន្ធនឹងករណីដែលបានកើតនៅមូលដ្ឋាននិងផ្តល់កំណត់ត្រានេះ ជូននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ការធ្វើបែបនេះនាំឱ្យមានការពន្យារពេលស៊ើបអង្កេត និងមានភាពខ្វះចន្លោះជាមួយព័ត៌មានស្តីពីករណីនោះ។

### ៣. កង្វះកិច្ចសហការជាមួយអ្នកជំនាញឯកទេស និងធនធានអន្តរជាតិ៖

នៅពេលរកឃើញនូវករណីពាក់ព័ន្ធនឹងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) មន្ត្រីបានរក្សាទុកសំណាករូបភាពតែមួយចំនួនតូចប៉ុណ្ណោះសម្រាប់ជាភស្តុតាង ដែលជាហេតុមិនអាចចែករំលែកបាននៅកម្រិតអន្តរជាតិដើម្បីកំណត់អត្តសញ្ញាណកុមារ និងថែមទាំងមិនបានអនុញ្ញាតឱ្យមានកិច្ចសហការ និងការកសាងសមត្ថភាពជាពហុភាគីផងដែរ។ តម្រូវការឱ្យមានអ្នកជំនាញឯកទេសសម្រាប់គាំទ្រដល់ការតាមដានត្រួតពិនិត្យ និងការស៊ើបអង្កេតបទល្មើសប្រភេទនេះ ក៏ត្រូវបានលើកឡើង ដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញ និងចែករំលែកព័ត៌មានបាន។

### ៤. ភាពពឹងផ្អែកជ្រុល លើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់តាមបែបប្រពៃណី៖

នគរបាលជាតិ ហាក់ដូចជាដាក់ការផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុង ទៅលើការស៊ើបអង្កេតតាមបែបប្រពៃណី។ ក្នុងករណីកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជនខិលខូចអាចមិនមានវត្តមាននៅក្នុងស្រុកនោះឡើយ ហេតុនេះទាមទារឱ្យទីភ្នាក់ងារឬស្ថាប័នអនុវត្តច្បាប់ ត្រូវពឹងផ្អែកលើវិធីសាស្ត្រស៊ើបអង្កេតតាមប្រព័ន្ធអ៊ីនធឺណិត និងមានកិច្ចសហការកាន់តែខ្លាំងជាមួយទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិ ក្នុងការផ្តល់ធនធានចាំបាច់សម្រាប់ការស៊ើបអង្កេត និងផ្តន្ទាទោសដល់ជនខិលខូចពីក្រៅប្រទេស។

### ៥. កង្វះអភិក្រមដែលគិតគូរអំពីជនរងគ្រោះ៖

អភិក្រមដែលគិតគូរអំពីជនរងគ្រោះ ព្យាយាមផ្តល់គុណតម្លៃចំពោះការកំណត់អត្តសញ្ញាណ និងការថែទាំជនរងគ្រោះ ស្មើគ្នានឹងគុណតម្លៃ ដែលផ្តល់ចំពោះការស៊ើបអង្កេត និងការផ្តន្ទាទោសជនខិលខូចដែរ។ ប៉ុន្តែបើពិនិត្យមើលលើការឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឬបទល្មើសទាក់ទងនឹងអ៊ីនធឺណិត យើងឃើញថាអ្នកអនុវត្តច្បាប់ហាក់ដូចជាយកចិត្តទុកដាក់ច្រើនលើការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោសជនខិលខូច ជាជាងកំណត់អត្តសញ្ញាណ និងយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។

# មេរៀនទី ២ ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ

## មាតិកាមេរៀនទី២


២.១ ប្រធានបទសំខាន់ៗ

២.២ នរណាជាក្រុមគោលដៅ

២.៣ រយៈពេលនៃមេរៀន

២.៤ សេចក្តីផ្តើម

២.៥ ប្លង់មេរៀន

២.៦ ខ្លឹមសារមេរៀនលម្អិត

ក. តើសកម្មភាពអ្វីខ្លះ ដែលអាចឱ្យកុមារប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ?

ខ. តើគួរធ្វើដូចម្តេច ដើម្បីរក្សាព័ត៌មានតាមអនឡាញឱ្យមានសុវត្ថិភាព ?

គ. តើអ្វីជាការកំណត់ឯកជនភាពរបស់អ្នកប្រើប្រាស់លើបណ្តាញទំនាក់ទំនងសង្គម ឬលើកម្មវិធីផ្សេងៗតាមប្រព័ន្ធអនឡាញ ?

# មេរៀនទី ២ ការរក្សាសុវត្ថិភាពតាមអនឡាញ

## ២.១ ប្រធានបទសំខាន់។

- តើមានអ្វីខ្លះ អាចកើតឡើងចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកតាមប្រព័ន្ធអនឡាញ?
- តើព័ត៌មានអ្វីខ្លះដែលអ្នកគួរចែករំលែក និងមិនគួរចែករំលែកតាមប្រព័ន្ធអនឡាញ?
- វិធីកំណត់ឯកជនភាព

## ២.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះ អំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ២.៣ រយៈពេលនៃមេរៀន

៣០នាទី ទៅ ៤៥នាទី

## ២.៤ សេចក្ដីផ្ដើម



គោលការណ៍សំខាន់មួយ ដែលអ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវចងចាំ គឺថាអ្វីៗដែលបានបង្ហោះលើអ៊ីនធឺណិត គឺស្ទើរតែមិនអាចដកចេញបានទាំងស្រុងនោះឡើយ។ កត្តានេះ អាចបង្កនូវហានិភ័យយ៉ាងខ្លាំងដល់កុមារ នៅពេលដែលពួកគេបានបង្ហោះព័ត៌មានផ្ទាល់ខ្លួននៅលើអ៊ីនធឺណិត ហើយព័ត៌មានទាំងនោះអាចត្រូវបានប្រើប្រាស់ដោយជនល្មើសផ្លូវភេទលើកុមារ។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាច៖

- ស្វែងយល់អំពីព័ត៌មានតាមអនឡាញណា ដែលអាចបង្កហានិភ័យដល់កុមារ
- ដឹងពីវិធីអប់រំកុមារក្នុងការកំណត់ឯកជនភាពកម្មវិធីដែលពួកគេប្រើប្រាស់ដើម្បីរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេឱ្យមានសុវត្ថិភាព

## ២.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី១ | ១៥នាទី | នៅក្នុងផ្នែកទី១នេះ អ្នកសម្របសម្រួល អាចចាប់ផ្តើមដោយពន្យល់បង្ហាញរាល់សកម្មភាពតាមអ៊ីនធឺណិតទាំងអស់ តែងបានបន្សល់ទុកនូវស្លាកស្នាមដែលអាចតាមដានបាន ជាពិសេសព័ត៌មានទាំងនោះត្រូវបានមើលឃើញដោយមនុស្សដទៃជាច្រើនទៀតដែលយើងមិនចង់ឱ្យឃើញ សូម្បីតែព័ត៌មានដែលបានចែករំលែកជាលក្ខណៈឯកជនក៏ដោយ។<br><br>អ្នកសម្របសម្រួលផ្តោតបន្ថែមដោយបង្ហាញពីសកម្មភាពអ្វីខ្លះ ដែលអាចឱ្យកុមារប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញតាមរយៈស្លាយមេរៀន។ |
| ផ្នែកទី២ | ១៥នាទី | អ្នកសម្របសម្រួល អាចចាប់ផ្តើមដោយការសួរសំនួរបំផុសថា តើគួរធ្វើដូចម្តេចដើម្បីរក្សាព័ត៌មានតាមអនឡាញឱ្យមានសុវត្ថិភាព? រួចបង្ហាញពីចម្លើយតាមរយៈស្លាយ ឬផ្ទាំងក្រដាស ដោយផ្ទៀងផ្ទាត់បន្ថែមជាមួយចម្លើយរបស់សិក្ខាកាម។<br><br>ក្រោយមក អ្នកសម្របសម្រួលប្រើប្រាស់ផ្ទាំងព័ត៌មានស្តីពីអាកប្បកិរិយាតាមប្រព័ន្ធអនឡាញដែលប្រកបដោយភាពឆ្លាតវៃ ឬហៅថា SMART rules ដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ ឬអ្នកសម្របសម្រួលអាចច្នៃប្រឌិតដោយខ្លួនឯង ក្នុងការពន្យល់បន្ថែម។ |
| ផ្នែកទី៣ | ១៥នាទី | **សកម្មភាពបំផុស៖** ផ្នែកនេះ អ្នកសម្របសម្រួលនឹងបង្ហាញសិក្ខាកាមពីវិធីកំណត់ឯកជនភាពលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក។ អ្នកសម្របសម្រួលនឹងឱ្យសិក្ខាកាមអនុវត្តផ្ទាល់លើទូរស័ព្ទដៃរបស់ពួកគេ និងបង្ហាញបន្ថែមតាមរយៈស្លាយមេរៀន ឬការរចនាលើក្រដាសផ្ទាំងធំ។ |

## ២.៦ ខ្លឹមសារមេរៀនលម្អិត

នៅពេលដែលយើងប្រើប្រាស់អ៊ីនធឺណិត យើងមិនបានដឹងទេថាសកម្មភាពរបស់យើងនៅលើអ៊ីនធឺណិត និងព័ត៌មានដែលយើងដាក់បញ្ចូលក្នុងអ៊ីនធឺណិត (Upload) អាចត្រូវបានអ្នកដទៃមើលឃើញនោះឡើយ។ ផ្ទុយទៅវិញរាល់សកម្មភាពតាមអ៊ីនធឺណិត ដូចជាគេហទំព័រដែលយើងចូលទៅកាន់ ព័ត៌មានដែលយើងបានបញ្ចូល និងការបង្ហោះផ្សេងៗដែលយើងតែងតែចែករំលែក ទាំងអស់នេះបានបន្សល់ទុកនូវស្លាកស្នាមដែលអាចតាមដានបាន ជាពិសេសព័ត៌មានទាំងនោះត្រូវបានមើលឃើញដោយមនុស្សដទៃជាច្រើនទៀតដែលយើងមិនចង់ឱ្យឃើញ។ សូម្បីតែព័ត៌មានដែលបានចែករំលែកជាលក្ខណៈឯកជន ក៏អាចត្រូវបានគេថតចម្លង ឬបង្ហាញដល់មនុស្សដទៃទៀត ដែលធ្វើឱ្យបាត់បង់នូវការគ្រប់គ្រងលើអ្នកដែលអាចមើលឃើញវាផងដែរ។ ដូច្នេះអ្វីដែលអ្នកមិនចង់ឲ្យអ្នកដទៃបានឃើញ មិនគួរមាននៅលើអ៊ីនធឺណិតនោះទេ ហើយជាពិសេសយើងត្រូវគិតគូរឱ្យបានច្បាស់លាស់ មុននឹងសម្រេចធ្វើអ្វីមួយតាមអនឡាញ។

### ក. តើសកម្មភាពអ្វីខ្លះ ដែលអាចឱ្យកុមារប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ?

#### ការចែករំលែកព័ត៌មានតាមអនឡាញ៖

រឿងសំខាន់មួយដែលទាំងកុមារ និងមនុស្សពេញវ័យតែងធ្វើនៅលើអ៊ីនធឺណិតគឺការចែករំលែក។ យើងតែងតែចែករំលែកព័ត៌មាន យើងចែករំលែកបទពិសោធន៍ យើងចែករំលែកចំណេះដឹង ហើយយើងក៏ចែករំលែករូបថត និងវីដេអូផងដែរ។ ការចែករំលែកគឺជាវិធីភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ ក៏ប៉ុន្តែវាក៏គួរតែត្រូវបានធ្វើឡើង ប្រកបដោយភាពឆ្លាតវៃ និងមានសុវត្ថិភាពផងដែរ។ ដូចនេះមនុស្សគ្រប់រូបដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ជាពិសេសកុមារគួរតែដឹងអំពីហានិភ័យដែលអាចកើតឡើងពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានតាមអនឡាញ។

#### ព័ត៌មានផ្ទាល់ខ្លួន និងរូបថតអាចត្រូវបានជនល្មើសតាមអនឡាញទាញយកផលប្រយោជន៍៖

មិនមែនមនុស្សទាំងអស់នៅលើអ៊ីនធឺណិតសុទ្ធតែមានចេតនាល្អនោះទេ។ មនុស្សមួយចំនួន អាចប្រើព័ត៌មានរបស់នរណាម្នាក់ ដែលពួកគេស្វែងរកបានតាមអ៊ីនធឺណិតសម្រាប់ចេតនាអាក្រក់។ មនុស្សមិនល្អក៏អាចព្យាយាមស្វែងរកព័ត៌មានផ្ទាល់ខ្លួនរបស់កុមារក្នុងគោលបំណងចាប់ផ្តើមទាក់ទងជាមួយកុមារ ផ្ញើឱ្យកុមារនូវរូបភាព វីដេអូ ដែលមានលក្ខណៈមិនសមរម្យ ឬអាចស្នើសុំឱ្យកុមារផ្ញើ ឬបញ្ជូននូវរូបភាព វីដេអូ ដែលមានលក្ខណៈមិនសមរម្យឱ្យពួកគេវិញក៏មាន។ ហេតុផលនេះហើយគ្រប់ពត៌មានផ្ទាល់ខ្លួនមិនគួរមាននៅលើអ៊ីនធឺណិតនោះទេ។ ព័ត៌មានផ្ទាល់ខ្លួនទាំងនោះរួមមាន៖



**លេខទូរស័ព្ទ**
**និងអាសយដ្ឋានរបស់អ្នក**




**ពាក្យសម្ងាត់ និង**
**ឈ្មោះប្រើប្រាស់របស់អ្នក**



**ទីតាំងរបស់អ្នក**



**ឈ្មោះសាលារៀន និងកន្លែង**
**កំសាន្តជាទៀងទាត់របស់អ្នក**



**រូបថតដែលមានលក្ខណៈស្និទ្ធស្នាល និង**
**មានលក្ខណៈបង្ហាញហួសហេតុអំពីខ្លួនអ្នក**

ព័ត៌មានទាំងនេះអាចត្រូវបានប្រើប្រាស់ដោយជនល្មើសតាមអនឡាញដើម្បីស្វែងរកកុមារ ចង់ដឹងបន្ថែមអំពីកុមារ និងទាក់ទងកុមារ។ ការចែករំលែកព័ត៌មានផ្ទាល់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណិតអាចបង្កើនហានិភ័យចំពោះកុមារ និងមនុស្សពេញវ័យ។ ទោះយ៉ាងនេះក៏ដោយ កុមារជាជនដែលងាយរងគ្រោះទៅនឹងហានិភ័យទាំងនោះជាងមនុស្សពេញវ័យ ព្រោះពួកគេឆាប់ជឿទុកចិត្តលើអ្នកដទៃ និងធ្វើតាមតម្រូវការរបស់មនុស្សដែលពួកគេជួប និងជជែកជាមួយតាមអនឡាញ។

រូបថត និងវីដេអូបែបស្និទ្ធស្នាល ឬរូបថត និងវីដេអូដែលមានលក្ខណៈផ្លូវភេទ ដែលបានបង្ហោះតាមប្រព័ន្ធអ៊ីនធឺណិត អាចបង្កហានិភ័យខ្លាំងចំពោះកុមារ នៅពេលវាត្រូវបានចែករំលែក។ បើទោះបីជារូបថតនោះត្រូវបានលុបចោលក៏ដោយ ក៏វាអាចត្រូវបានថតចម្លង ឬរក្សាទុកក្នុងឧបករណ៍របស់គេដែរ ហើយគេមិនអាចដក ឬលុបវាចេញពីអ៊ីនធឺណិតបានឡើយ។ ដូច្នេះរូបថត ឬវីដេអូណាមួយដែលអ្នកមិនមានបំណងចង់ឱ្យអ្នកណាម្នាក់បានឃើញ មិនគួរមាននៅលើអ៊ីនធឺណិតនោះទេ។

## ខ. តើគួរធ្វើដូចម្តេច ដើម្បីរក្សាព័ត៌មានតាមអនឡាញឱ្យមានសុវត្ថិភាព?

សូមចងចាំថា អ្នកអាចណែនាំកុមារឱ្យអនុវត្តនូវវិធីសាស្ត្រងាយៗមួយចំនួនដូចខាងក្រោម ដើម្បីឱ្យពួកគេអាចរក្សាព័ត៌មានផ្ទាល់ខ្លួនប្រកបដោយសុវត្ថិភាពតាមអនឡាញ ជាពិសេសអាចការពារពួកគេពីហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញផងដែរ។ វិធីសាស្ត្រងាយៗទាំងនោះ រួមមាន៖

១. កំណត់ពាក្យសម្ងាត់ឱ្យមានលក្ខណៈរឹងមាំចំពោះគ្រប់គណនីដែលអ្នកប្រើប្រាស់

២. សូមចងចាំថាអ្នកត្រូវចាកចេញពីគណនីរបស់អ្នក (Log Out) នៅពេលអ្នកឈប់ប្រើប្រាស់

៣. រាំងខ្ទប់ (Block) និងរាយការណ៍ពីមនុស្សនៅលើអ៊ីនធឺណិត ដែលធ្វើសកម្មភាពមិនសមរម្យ ឬគួរឱ្យសង្ស័យ

៤. កំណត់ឯកជនភាពកម្មវិធីដែលអ្នកប្រើប្រាស់ ដើម្បីប្រាកដថាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកត្រូវបានមើលឃើញដោយមនុស្សដែលស្គាល់ច្បាស់តែប៉ុណ្ណោះ

៥. គួរតែប្ដីទទួលធ្វើជាមិត្តតាមអនឡាញតែជាមួយមនុស្សដែលស្គាល់ច្បាស់ប៉ុណ្ណោះ

ក្រៅពីការអនុវត្តនូវវិធីសាស្ត្រខាងលើ អ្នកក៏អាចពន្យល់បង្ហាញដល់កុមារបន្ថែមពីអាកប្បកិរិយាតាមប្រព័ន្ធអនឡាញដែលប្រកបដោយភាពឆ្លាតវៃ ឬហៅថា SMART rules [៥២] បានផងដែរ។




ត្រូវរក្សាព័ត៌មានផ្ទាល់ខ្លួន ឱ្យមានសុវត្ថិភាព (SAFE) ហើយត្រូវគិតឱ្យបានច្បាស់លាស់ពីអ្វីដែលអ្នកនឹងចែករំលែកតាមប្រព័ន្ធអនឡាញ



មិនត្រូវជួបផ្ទាល់ (MEET) ជាមួយមនុស្សចម្លែកដែលអ្នកទើបតែស្គាល់តាមប្រព័ន្ធអនឡាញ



មិនត្រូវទទួល (ACCEPT) សំណើសុំធ្វើជាមិត្តភក្តិ និងទទួលសារពីមនុស្សដែលមិនស្គាល់នោះទេ



ត្រូវពិនិត្យប្រភពនៃអ្វីដែលបានអាន ឬបានទទួលតាមអ៊ីនធឺណិត ដើម្បីប្រាកដថាវាគួរឱ្យជឿទុកចិត្តបាន (RELIABLE)



ត្រូវប្រាប់ (TELL) នរណាម្នាក់ដែលអ្នកទុកចិត្ត ប្រសិនបើអ្នកមានអារម្មណ៍ថាបានទទួលរងការគម្រាមកំហែងតាមប្រព័ន្ធអនឡាញ

[៥២] ផ្ទាំងរូបភាពអប់រំស្តីពី "អាកប្បកិរិយាតាមប្រព័ន្ធអនឡាញដែលប្រកបដោយភាពឆ្លាតវៃ" របស់អង្គការសកម្មភាពដើម្បីកុមារ ឆ្នាំ២០២០

## គ. តើអ្វីជាការកំណត់ឯកជនភាពរបស់អ្នកប្រើប្រាស់លើបណ្តាញទំនាក់ទំនងសង្គម ឬលើកម្មវិធីផ្សេងៗតាមអនឡាញ ?

នៅពេលអ្នកបង្កើតគណនីបណ្តាញទំនាក់ទំនងសង្គមដើម្បីប្រើប្រាស់ គណនីភាគច្រើននឹងត្រូវបានកំណត់ជាលក្ខណៈសាធារណៈ (Public) ដោយស្វ័យប្រវត្តិ ដែលតម្រូវឱ្យអ្នកផ្លាស់ប្តូរវា ប្រសិនបើអ្នកមិនចង់ឱ្យមនុស្សគ្រប់គ្នាឃើញអ្វីដែលអ្នកនឹងបង្ហោះ ឬចែករំលែកតាមអនឡាញ ។

ដើម្បីកំណត់ឯកជនភាព នៅក្នុងបណ្តាញទំនាក់ទំនងសង្គម ឬកម្មវិធីភាគច្រើន អ្នកត្រូវស្វែងរកពាក្យ "Menu" ដែលជាធម្មតាវាអាចនៅជ្រុងខាងស្តាំដៃ រួចចុចប៊ូតុងកំណត់ "Setting" ហើយបន្ទាប់មកស្វែងរកពាក្យឯកជនភាព "Privacy" ហើយធ្វើការកំណត់នូវអ្វីដែលអ្នកគិតថាវាចាំបាច់ ។

ខាងក្រោមនេះ ជាឧទាហរណ៍ដែលបង្ហាញអំពីជំណាក់កាលនៃការកំណត់ឯកជនភាពក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) ៖

**ជំហានទី១ ៖** ចូលទៅរកពាក្យ "Setting" ហើយបន្ទាប់មកស្វែងរកពាក្យ "Privacy"




**ជំហានទី២ ៖** ធ្វើការកំណត់ឯកជនភាព នូវចំណុចមួយចំនួនដូចខាងក្រោម ៖

- តើអ្នកណា អាចមើលឃើញនូវការបង្ហោះរបស់អ្នក ?
  Who can see your posts ?
- មនុស្ស និងទំព័រដែលអ្នកតាមដាន
  People and pages you follow.
- តើអ្នកណា អាចផ្ញើសំណើរសុំធ្វើជាមិត្តភ័ក្តិមកអ្នកបាន ?
  Who can send you a friend's request ?
- តើមានព័ត៌មានអ្វីខ្លះនៅលើប្រូហ្វាលរបស់អ្នក ដែលត្រូវបានកំណត់ឱ្យឃើញជាសាធារណៈ ?
  What info on your profile is set to public ?
- ការកំណត់មុខងារសម្រាប់តែមិត្តភ័ក្តិ និងកំណត់មិនឱ្យបង្ហាញទីតាំងរបស់អ្នក នៅពេលអ្នកប្រើកម្មវិធីហ្វេសប៊ុកឡាយ
  Facebook Live-Only for friends and without showing your location.

ជាទូទៅ ការកំណត់ឯកជនភាពនៅលើបណ្តាញសង្គម អាចអនុវត្តបានច្រើនជំណាក់កាលផ្សេងទៀតក្រៅពីចំណុចទាំងប្រាំខាងលើ ដែលតម្រូវឱ្យអ្នកស្វែងយល់បន្ថែមទៀតតាមដែលអាចធ្វើទៅបាន ។

# ជំពូក៣៖

## ការឆ្លើយតបចំពោះអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ




នៅក្នុងជំពូក៣នេះ អ្នកនឹងបានរៀនសូត្រនូវមេរៀនសំខាន់ៗចំនួនពីរផ្សេងគ្នាដែលក្នុងនោះរួមមាន មេរៀនទី១៖ ការស្គាល់ពីសញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការផ្ដល់ជំនួយ និងការរាយការណ៍ និង មេរៀនទី២៖សារៈសំខាន់នៃការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារ

## គំនិតសំខាន់នៃមេរៀនទី១

១. ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ មានផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងចំពោះកុមារ ជាពិសេស អាចប៉ះពាល់ដល់សុខុមាលភាពផ្លូវកាយ ផ្លូវអារម្មណ៍ និង/ឬអាកប្បកិរិយារបស់ពួកគេ។ ការទទួលការព្យាបាលបន្ទាប់ពីករណីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទបានកើតឡើង អាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើកុមារ និងជួយពួកគេឱ្យរស់នៅក្នុងជីវិតដែលមានភាពល្អប្រសើរឡើងវិញ និងមានសុភមង្គល។

២. នៅពេលដែលកុមារលាតត្រដាងអំពីការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទដែលកើតឡើងចំពោះពួកគេ វាពិតជាសំខាន់ណាស់ដែលយើងត្រូវយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ និងដោះស្រាយស្ថានភាពប្រកបដោយវិជ្ជាជីវៈ។ ជាងនេះទៅទៀត ត្រូវប្រាកដថាកុមារមិនបានធ្វើអ្វីខុស និងការដែលពួកគេប្រាប់ពីរឿងរ៉ាវដែលបានកើតឡើង គឺជារឿងដែលត្រឹមត្រូវបំផុត។ អ្នកក៏ត្រូវប្រាកដថា កុមារទទួលបានជំនួយដែលពួកគេត្រូវការ។

៣. ការរាយការណ៍ ជាវិធីដែលល្អបំផុតក្នុងការជួយបញ្ឈប់នូវការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាពិសេសការរាយការណ៍អាចជួយដល់កុមារឱ្យទទួលបាននូវការគាំទ្រ និងជំនួយដែលសមស្របនានា។ ការរាយការណ៍កាន់តែច្រើននាំឱ្យជនល្មើស កាន់តែខ្លាចរអារក្នុងការប្រព្រឹត្តបទល្មើស ជាពិសេសអាចផ្តល់ទំនុកចិត្តកាន់តែខ្ពស់ដល់ជនរងគ្រោះក្នុងការលាតត្រដាងពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

## គំនិតសំខាន់នៃមេរៀនទី២

១. ការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារលើប្រធានបទស្តីពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឱ្យកុមារនូវចំណេះដឹងដែលអាចជួយការពារពួកគេ កាត់បន្ថយភាពងាយរងគ្រោះ និងអាចឱ្យពួកគេមានភាពក្លាហានក្នុងការប្រាប់ពីរឿងរ៉ាវដែលកើតឡើង។

២. ការជជែកអំពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញដោយបើកចំហជាមួយកុមារ ជាពិសេសប្រាប់ពួកគេអំពីការប្រាស្រ័យទាក់ទងតាមអនឡាញដែលមានសុវត្ថិភាព នឹងធ្វើឱ្យពួកគេមានទំនុកចិត្តក្នុងការចែករំលែកបទពិសោធន៍តាមអនឡាញរបស់ពួកគេជាមួយអ្នក។

# មេរៀនទី ១ ការស្គាល់ពីសញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការផ្តល់ជំនួយ និងការរាយការណ៍

## មាតិកាមេរៀនទី១


**១.១** ប្រធានបទសំខាន់ៗ

**១.២** នរណាជាក្រុមគោលដៅ

**១.៣** រយៈពេលនៃមេរៀន

**១.៤** សេចក្តីផ្តើម

**១.៥** ប្លង់មេរៀន

**១.៦** ខ្លឹមសារមេរៀនលម្អិត

**ក.** **សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ**

> សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

> សញ្ញាណនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

**ខ.** **តើអ្វីដែលអ្នកគួរធ្វើ ប្រសិនបើអ្នកសង្ស័យថាកុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ?**

> ការផ្តល់ការគាំទ្រ

> ការសម្របសម្រួលបញ្ជូនករណីទៅរកសេវាសមស្រប និងការថែទាំ

> ចំណុចសំខាន់ៗដែលអ្នកមានជំនាញវិជ្ជាជីវៈត្រូវដឹងបន្ថែមអំពីការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

**គ.** **ការរាយការណ៍អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការរាយការណ៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ**

> ការរាយការណ៍ពីករណីនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

> របៀបរាយការណ៍តាមរយៈបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត

> ហេតុអ្វីបានជាអ្នកត្រូវរាយការណ៍?

មេរៀនទី ១

# ការស្គាល់ពីសញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការផ្តល់ជំនួយ និងការរាយការណ៍

## ១.១ ប្រធានបទសំខាន់ៗ

- សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ការគាំទ្រ និងការផ្តល់ជំនួយដល់កុមារ
- ការរាយការណ៍អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាពិសេស ការរាយការណ៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

## ១.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះអំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ១.៣ រយៈពេលនៃមេរៀន

៣០នាទី ទៅ ៤៥នាទី

## ១.៤ សេចក្តីផ្តើម



ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ អាចជះឥទ្ធិពលធ្ងន់ធ្ងរដល់កុមារ មិនថាបានកើតឡើងក្នុងទម្រង់បែបណានោះទេ។ ទម្រង់ទាំងអស់ សុទ្ធតែអាចប៉ះពាល់ដល់កុមារតាមវិធីផ្សេងៗ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីអ្នកដែលមានភារកិច្ចពាក់ព័ន្ធ។ ដូច្នេះវាពិតជាសំខាន់ណាស់ដែលអ្នកមានជំនាញវិជ្ជាជីវៈធ្វើការផ្ទាល់ជាមួយកុមារ បានដឹងពីរបៀបដើម្បីកំណត់សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដឹងពីវិធីក្នុងការផ្តល់នូវជំនួយ និងការគាំទ្រដែលសមស្រប ជាពិសេសដឹងពីរបៀបរាយការណ៍។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាច៖

- ដឹងពីរបៀបកំណត់សញ្ញាណសំខាន់ៗដែលអាចបង្ហាញថាកុមារប្រហែលជាបានរងគ្រោះដោយសារការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ
- ដឹងពីវិធីផ្តល់ការគាំទ្រ សម្របសម្រួលបញ្ជូនករណី និងរបៀបរាយការណ៍

## ១.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី១ | ១០នាទី | អ្នកសម្របសម្រួលចាប់ផ្តើមដោយការពន្យល់បង្ហាញពីសញ្ញាណសំខាន់ៗដែលកុមារបង្ហាញបន្ទាប់ពីរងគ្រោះដោយករណីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ អ្នកសម្របសម្រួលអាចប្រើប្រាស់ស្លាយមេរៀន ឬក្រដាសផ្ទាំងធំដែលបានរៀបចំទុកជាស្រេច ដោយបែងចែកសញ្ញាណជាបីផ្នែកសំខាន់ៗ រួមមានសញ្ញាណផ្នែករាងកាយ ឥរិយាបថ និងអារម្មណ៍។ អ្នកសម្របសម្រួលត្រូវបញ្ជាក់បន្ថែមអំពីសញ្ញាណផ្នែកឥរិយាបថ និងអារម្មណ៍ចំពោះករណីនៃការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ហើយបញ្ជាក់អំពីសញ្ញាណផ្នែករាងកាយដែលអាចនឹងកើតមានឡើងផងដែរ ប្រសិនបើការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញនោះ អាចឈានដល់ការជួបផ្ទាល់រវាងកុមារ និងជនល្មើស។ |
| ផ្នែកទី២ | ១០នាទី | **សំនួរបំផុស៖** សួរទៅកាន់អ្នកចូលរួម ថាតើពួកគេបានដឹងទេ អ្វីដែលគួរធ្វើប្រសិនបើសង្ស័យថាកុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ? តើពួកគេដឹងពីវិធីក្នុងការនិយាយជាមួយកុមារដែរឬទេ? ជាពិសេសតើពួកគេដឹងទេថា សេវាសមស្របណាខ្លះ ដែលពួកគេអាចសម្របសម្រួលបញ្ជូនករណីទាំងនោះបាន?<br><br>កត់ត្រា និងពិភាក្សាពីចម្លើយរបស់សិក្ខាកាម រួចបង្ហាញបន្ថែមតាមរយៈមេរៀននូវចំណុចសំខាន់ៗដូចជា អ្វីដែលគួរធ្វើ និងមិនគួរធ្វើ នៅពេលកុមារប្រាប់អ្នកពីរឿងរ៉ាវដែលបានកើតឡើង ការផ្តល់ការគាំទ្រ ការសម្របសម្រួលបញ្ជូនករណីទៅរកសេវាសមស្រប ជាពិសេសចំណុចសំខាន់ៗដែលអ្នកមានជំនាញវិជ្ជាជីវៈត្រូវដឹងបន្ថែមអំពីការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។<br><br>* អ្នកសម្របសម្រួលអាចប្រើប្រាស់សៀវភៅជំនួយស្មារតីសេវាសម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ដើម្បីបង្ហាញបន្ថែមអំពីសេវាគាំទ្រផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលដែលប្រតិបត្តិការនៅគ្រប់រាជធានី ខេត្តទូទាំងប្រទេសកម្ពុជាដោយរួមបញ្ចូលនូវការគាំទ្រផ្នែកផ្លូវចិត្ត ជំនួយផ្នែកច្បាប់ ការស្តារឡើងវិញ ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម ការអប់រំ ក៏ដូចជាសេវាសំខាន់ៗដទៃទៀត។ |

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
| --- | --- | --- |
| ផ្នែកទី៣ | ១០នាទី | អ្នកសម្របសម្រួលបន្តពន្យល់ពីការស្វែងរកជំនួយតាមរយៈការរាយការណ៍អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការរាយការណ៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ ការអនុវត្តផ្ទាល់តាមរយៈការចូលទៅកាន់បណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តក្នុងចំណោមសិក្ខាកាមដែលចូលរួម។ |
| ផ្នែកទី៤ | ១៥នាទី | **សកម្មភាពបំផុសការចូលរួម៖**<br>**សកម្មភាព៖ ការលើកឡើងពីការប្រឈម និងដំណោះស្រាយ**<br>(អ្នកសម្របសម្រួលអាចប្រើប្រាស់សកម្មភាពនេះ ប្រសិនបើសិក្ខាកាមដែលចូលរួមភាគច្រើន ជាអ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការពាក់ព័ន្ធនឹងការគ្រប់គ្រងករណី ការផ្ដល់សេវាគាំទ្រ និងការងារផ្នែកសង្គម)<br><br>អ្នកសម្របសម្រួល ប្រាប់ដល់សិក្ខាកាមឱ្យលើកឡើងនូវបញ្ហាប្រឈមចំនួន៥តាមរយៈបទពិសោធន៍ដែលពួកគេធ្លាប់មាន នៅពេលដែលពួកគេបានជួយកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។ អ្នកសម្របសម្រួល សរសេរបញ្ហាប្រឈមទាំងអស់នោះនៅលើក្ដារខៀន រួចបែងចែកអ្នកចូលរួមជា៥ក្រុម ដែលក្រុមនីមួយៗនឹងពិភាក្សាពីបញ្ហាប្រឈមចំនួនមួយ។ សិក្ខាកាមត្រូវពិភាក្សាអំពីមូលហេតុដែលបង្កឱ្យមានបញ្ហាប្រឈមនោះ រួចលើកឡើងនូវដំណោះស្រាយចំនួន៣។ សិក្ខាកាមជាតំណាងក្រុម ត្រូវធ្វើបទបង្ហាញពីការពិភាក្សារបស់ពួកគេឱ្យក្រុមដទៃទៀតបានដឹង។ |

## ១.៦ ខ្លឹមសារមេរៀនលម្អិត

### ក. សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ចំពោះអ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការជាមួយកុមារ ការយល់ដឹងពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែអ្វីដែលរឹតតែមានសារៈសំខាន់ខ្លាំងជាងនេះទៀតនោះ គឺការយល់ដឹងពីរបៀបឆ្លើយតបក្នុងករណីដែលការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទបានកើតឡើង។ ការឆ្លើយតបបន្ទាន់ និងការផ្តល់ឱ្យកុមារនូវការថែទាំ និងការគាំទ្រដ៏ត្រឹមត្រូវ គឺជារឿងចាំបាច់បំផុត បន្ទាប់ពីកុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ មានផលប៉ះពាល់ខ្លាំងទៅលើការវិវឌ្ឍផ្នែកសង្គម ផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវចិត្តរយៈពេលវែងចំពោះកុមារ ប៉ុន្តែប្រសិនបើកុមារទទួលបានជំនួយ និងការឆ្លើយតបដ៏ត្រឹមត្រូវ ផលប៉ះពាល់ទាំងនោះ អាចត្រូវបានកាត់បន្ថយ ហើយពួកគេនឹងអាចរស់នៅប្រកបដោយសុខុមាលភាព និងភាពសប្បាយរីករាយ។

### សញ្ញាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ជំហានដំបូងក្នុងការជួយកុមារ គឺការកំណត់នូវសញ្ញាណដែលកុមារអាចរងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។ ការកំណត់សញ្ញាណរងគ្រោះរបស់កុមារ មិនមានភាពងាយស្រួលនោះទេ ព្រោះមានផលប៉ះពាល់ផ្សេងៗគ្នាដែលអាចកើតឡើងចំពោះកុមារ អាស្រ័យលើប្រភេទករណីនៃការរំលោភបំពានផ្លូវភេទ ទំនាក់ទំនងរបស់ពួកគេជាមួយជនល្មើស បុគ្គលិកលក្ខណៈរបស់កុមារ និងកត្តាជាច្រើនផ្សេងៗទៀត។ ទោះបីជាយ៉ាងនេះក៏ដោយ សញ្ញាណមួយចំនួនអាចកើតឡើងជាទូទៅ បន្ទាប់ពីការរំលោភបំពានផ្លូវភេទបានកើតឡើងចំពោះកុមារ ហើយការដឹងពីសញ្ញាណទូទៅទាំងនោះ អាចជួយអ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការជាមួយកុមារ មានលទ្ធភាពកំណត់បានថាកុមារត្រូវការជំនួយពីពួកគេ។

សញ្ញាណសំខាន់ៗដែលកុមារបង្ហាញបន្ទាប់ពីរងគ្រោះដោយករណីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ អាចបែងចែកជាសញ្ញាណផ្នែករាងកាយ ឥរិយាបថ និងអារម្មណ៍។ អ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការជាមួយកុមារ អ្នកជំនាញថែទាំសុខភាព និងអ្នកធ្វើការពាក់ព័ន្ធ អាចប្រើប្រាស់សញ្ញាណមូលដ្ឋានខាងក្រោមនេះ ដើម្បីធ្វើការកំណត់សញ្ញាណនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ សូមចងចាំថាសញ្ញាណទាំងនេះ មិនមានន័យថាកុមារត្រូវបានគេរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទប្រាកដមួយរយភាគរយនោះទេ តែសញ្ញាណទាំងនេះ អាចបង្ហាញថាកុមារកំពុងមានហានិភ័យ និងត្រូវការជំនួយ។

ខាងក្រោមនេះគឺជាតារាងស្តីពីសញ្ញាណទូទៅផ្នែករាងកាយ ឥរិយាបថ និងអារម្មណ៍របស់កុមារ ដែលអាចរងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ [៥៣] ៖

---

[៥៣] IRC និង UNICEF ( 2012 ) Caring for child survivors of sexual abuse

| សញ្ញាណផ្នែករាងកាយ | សញ្ញាណផ្នែកឥរិយាបថ | សញ្ញាណផ្នែកអារម្មណ៍ |
|---|---|---|
| • មានហូរឈាមតាមប្រដាប់ភេទ<br>• មានផ្ទៃពោះ<br>• មានវត្តមានទឹកកាម<br>• មានរមាស់នៅតំបន់ប្រដាប់ភេទ<br>• មានស្នាមជាំនៅតំបន់ប្រដាប់ភេទ<br>• អាចឆ្លងជំងឺកាមរោគ ឬជំងឺឆ្លងផ្សេងទៀត<br>• មានការលំបាកក្នុងការដើរ<br>• ឈឺចាប់ពេលបត់ជើងតូច/ ឬពេលបត់ជើងធំ<br>• ត្អូញត្អែរអំពីការឈឺពោះ<br>• បង្ករបួសស្នាមដល់ខ្លួនឯង (ដូចជា៖ ការប៉ុនប៉ងធ្វើអត្តឃាតជាដើម) | • ប្រើប្រាស់សារធាតុញៀន ឬគ្រឿងស្រវឹង<br>• បង្ហាញអាកប្បកិរិយាផ្លូវភេទមិនសក្តិសមនឹងអាយុ<br>• មានបញ្ហានៅសាលារៀន<br>• រត់ចេញពីផ្ទះ<br>• មានបញ្ហាក្នុងការទទួលទានអាហារ<br>• មានអាកប្បកិរិយាលាក់បាំង/ និយាយកុហក<br>• សុបិន្តអាក្រក់<br>• ផ្តាច់ទំនាក់ទំនងពីមិត្តភក្តិ | • ស្តីបន្ទោសខ្លួនឯង និងឱ្យតម្លៃខ្លួនឯងទាប<br>• ការថប់បារម្ភ<br>• ខឹង ឆេវឆាវ តានតឹង<br>• ជំងឺធ្លាក់ទឹកចិត្ត<br>• ធ្វើបាបខ្លួនឯង<br>• ជំងឺស្ត្រេសក្រោយការប៉ះទង្គិចផ្លូវចិត្ត (Post-Traumatic Stress Disorder-PTSD)<br>• ចងគំនុំគំគួន សងសឹក<br>• មានអារម្មណ៍ថាខ្លួនឯងគ្មានប្រយោជន៍ |

ប្រភពដកស្រង់៖ IRC និង UNICEF (2012) Caring for child survivors of sexual abuse.

សញ្ញាណដែលបានពិពណ៌នាខាងលើនេះ គឺជាសញ្ញាណបង្ហាញពីផលប៉ះពាល់ភ្លាមៗ និងផលប៉ះពាល់ក្នុងរយៈពេលខ្លីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ទោះជាយ៉ាងនេះក៏ដោយ ការស្រាវជ្រាវក៏បានបង្ហាញផងដែរថាកុមារក៏អាចទទួលរងផលប៉ះពាល់រយៈពេលវែងដែលអាចកើតឡើងនៅពេលពួកគេធំពេញវ័យ។ ផលប៉ះពាល់ទាំងនោះរួមមាន៖

- ការលំបាកក្នុងការបង្កើតទំនាក់ទំនងជិតស្និទ្ធ (ការបែកបាក់ ឬការមិនពេញចិត្តនឹងទំនាក់ទំនងជាដើម)
- ការលំបាកខាងផ្នែកផ្លូវភេទ ឬការមិនពេញចិត្តផ្នែកផ្លូវភេទ
- ការរងគ្រោះសារឡើងវិញ
- អាកប្បកិរិយាបំផ្លិចបំផ្លាញខ្លួនឯង (ការធ្វើបាបខ្លួនឯង និងការប៉ុនប៉ងធ្វើអត្តឃាត)
- ជំងឺថប់បារម្ភ ជំងឺធ្លាក់ទឹកចិត្ត និងការប្រើប្រាស់សារធាតុញៀន ឬគ្រឿងស្រវឹងជាដើម។

### សញ្ញាណនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

មិនខុសពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទនៅខាងក្រៅ កុមារក៏អាចបង្ហាញនូវសញ្ញាណផ្នែកឥរិយាបថ និងសញ្ញាណផ្នែកផ្លូវអារម្មណ៍មួយចំនួនបន្ទាប់ពីរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ សញ្ញាណទាំងនោះរួមមាន ការស្ដីបន្ទោសខ្លួនឯង និងឱ្យតម្លៃខ្លួនឯងទាប ការថប់បារម្ភ ជំងឺធ្លាក់ទឹកចិត្ត ការធ្វើបាបខ្លួនឯង ជំងឺស្រ្តេសក្រោយការប៉ះទង្គិចផ្លូវចិត្ត (Post–Traumatic Stress Disorder–PTSD) សុបិន្តអាក្រក់និងគេងមិនលក់ អស់កម្លាំងល្ហិតល្ហៃ ការប្រើប្រាស់អ៊ីនធឺណិតហួសកំរិត ការកើតមានបញ្ហានៅសាលា រត់ចេញពីផ្ទះ មានបញ្ហាក្នុងការទទួលទានអាហារ មានអារម្មណ៍មិនស្រួលនៅជិតកាមេរ៉ា មានអាកប្បកិរិយាលាក់បាំង/និយាយកុហក ការប្រើប្រាស់គ្រឿងញៀនឬគ្រឿងស្រវឹងជាដើម។ នៅពេលករណីនៃការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ឈានដល់ការមានទំនាក់ទំនងផ្ទាល់រវាងជនល្មើស និងកុមារ ការរំលោភបំពានផ្លូវភេទនឹងអាចកើតមានឡើង នោះសញ្ញាណផ្នែកផ្លូវកាយក៏នឹងអាចកើតមានឡើងផងដែរ។

### ខ. តើអ្វីដែលអ្នកគួរធ្វើ ប្រសិនបើអ្នកសង្ស័យថាកុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ?

ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺជាបទល្មើសធ្ងន់ធ្ងរដែលអាចជះឥទ្ធិពលខ្លាំងដល់កុមារ។ វាជារឿងដ៏សំខាន់ដើម្បីលើកទឹកចិត្តកុមារឱ្យនិយាយនូវអ្វីដលបានកើតឡើង ប្រសិនបើពួកគស្ថិតក្នុងស្ថានភាពនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ការលាតត្រដាងអំពីបញ្ហា អាចឱ្យកុមារមានសុវត្ថិភាព ឬនាំឱ្យកុមារ និងគ្រួសារទទួលបានជំនួយនិងការគាំទ្រនានាដែលសមស្រប។ ប្រសិនបើអ្នកសង្ស័យអំពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ សូមនិយាយជាមួយកុមារ និង សង្កេតមើលថាពួកគត្រូវការជំនួយពីអ្នកដៃរឬទ។ ប្រសិនបើកុមារប្រាប់អ្នកពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទណាមួយ អ្នកត្រូវដឹងពីចំណុចសំខាន់ៗមួយចំនួនដូចជា៖

- ស្ដាប់ដោយការយកចិត្តទុកដាក់ មិនវិនិច្ឆ័យ និងត្រូវមានភាពហ្មត់ចត់ចំពោះអ្វីដែលកុមារបាននិយាយប្រាប់
- ត្រូវប្រាកដថាការដែលកុមារនិយាយអំពីរឿងរ៉ាវដែលបានកើតឡើង និងការដែលកុមារមករកអ្នកឱ្យជួយគឺ ជារឿងដែលត្រឹមត្រូវបំផុត
- ប្រាប់កុមារថាវាមិនមែនជារឿងដែលត្រូវខ្មាស់អៀននោះទេ ក្នុងការប្រាប់ពីរឿងរ៉ាវដែលបានកើតឡើង ហើយរាល់កំហុសដែលកើតមានជាការទទួលខុសត្រូវរបស់ជនល្មើស
- ប្រាប់កុមារថាពួកគមិនបានធ្វើអ្វីខុសឆ្គង ហើយពួកគមិនត្រូវបានទទួលការស្ដីបន្ទោសជាដាច់ខាត
- បង្ហាញពីការអាណិតអាសូរ និងផ្ដល់ការគាំទ្រនានា

## ការផ្តល់ការគាំទ្រ

ក្នុងនាមអ្នកជាអ្នកមានជំនាញធ្វើការជាមួយកុមារផ្ទាល់ អ្នកអាចប្រហែលជាមនុស្សម្នាក់ ដែលកុមារអាចមានអារម្មណ៍ល្អ និងទុកចិត្តក្នុងការមកពឹងពាក់។ ដូចនេះការយល់ដឹងពីរបៀបក្នុងការផ្តល់ការគាំទ្រដល់កុមារគឺជារឿងដែលចាំបាច់បំផុត។

បញ្ហាភាគច្រើន អាចកើតឡើងនៅពេលកុមារលាតត្រដាងអំពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ជាឧទាហរណ៍ ការសួរសំនួរដោយផ្តោតទៅលើអ្វីដែលកុមារបានធ្វើ ហាក់កើតឡើងច្រើនជាជាងការសាកសួរអំពីឧបាយកលដែលជនល្មើសធ្វើលើកុមារហើយនាំឱ្យមានការរំលោភបំពានកើតឡើង។ វិធីនេះកាន់តែធ្វើឲ្យកុមារមានអារម្មណ៍ថា ពួកគេត្រូវបានស្តីបន្ទោស។ ការទទួលបានការគាំទ្រសមស្របពីមិត្តភក្តិ ក្រុមគ្រួសារ និងអ្នកមានជំនាញ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានចំពោះកុមារ។ ការលើកទឹកចិត្តឱ្យកុមារនិយាយចេញនូវរឿងរ៉ាវដែលបានកើតឡើង អាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់កុមារ និងជួយឲ្យពួកគេទទួលបានជំនួយដែលសមស្រប បើទោះបីជាពេលខ្លះពួកគេអាចប្រឈមនឹងភាពភ័យខ្លាចក៏ដោយ។

## ការសម្របសម្រួលបញ្ជូនករណីទៅរកសេវាសមស្រប និងការថែទាំ

អ្នកមានជំនាញវិជ្ជាជីវៈដែលធ្វើការជាមួយកុមារ គួរតែដឹងអំពីសេវាសមស្របផ្សេងៗ ដែលមាននៅក្នុងតំបន់របស់ពួកគេ ដើម្បីជួយកុមារបន្ទាប់ពីទទួលបានការរាយការណ៍ករណីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសពួកគេអាច ធានាថាកុមារត្រូវបានជួយសង្គ្រោះទាន់ពេលវេលា។

សេវាដែលសមស្របបំផុតចំពោះកុមារ អាចរួមបញ្ចូលនូវចំណុចមួយចំនួនដូចជា៖

១. តើនរណា ដែលអ្នកត្រូវរាយការណ៍ករណី? តើកន្លែងណា ដែលអ្នកត្រូវរាយការណ៍?

២. អ្នកត្រូវដឹងពីអាជ្ញាធរក្នុងតំបន់ដែលធ្វើការដោះស្រាយលើបញ្ហារំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

៣. តើសេវាផ្លូវច្បាប់ប្រភេទណា ដែលអ្នកអាចរកបានក្នុងការជួយដល់កុមាររងគ្រោះ ហើយអ្វីខ្លះជាសិទ្ធិស្របច្បាប់របស់ពួកគេ?

៤. តើការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងការថែទាំសង្គមបែបណា ដែលអាចស្វែងរកបានសម្រាប់កុមាររងគ្រោះ?

## ចំណុចសំខាន់ៗដែលអ្នកមានជំនាញវិជ្ជាជីវៈត្រូវដឹងបន្ថែមអំពីការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ក្នុងនាមអ្នកជាអ្នកមានជំនាញវិជ្ជាជីវៈធ្វើការជាមួយកុមារផ្ទាល់ អ្នកត្រូវប្រាកដថាការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អាចមានលក្ខណៈជាក់លាក់ជាងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទក្រៅប្រព័ន្ធអនឡាញ និងទាមទារឱ្យមានការយល់ដឹងបន្ថែម។ ខាងក្រោមនេះជាចំណុចសំខាន់ៗដែលអ្នកមានជំនាញវិជ្ជាជីវៈ អាចស្វែងយល់បន្ថែមអំពីការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៖

### ១. កុមារមិនត្រូវបានគេស្តីបន្ទោសចំពោះករណីកេងប្រវ័ញ្ចផ្លូវភេទឡើយ បើទោះបីជាពួកគេបានចូលរួមក្នុងសកម្មភាពនោះក៏ដោយ៖

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតែងតែជាកំហុសរបស់ជនល្មើស វាមិនមែន ជាកំហុសរបស់កុមារនោះទេ បើទោះបីជាពេលខ្លះកុមារប្រាស្រ័យទាក់ទងជាមួយជនល្មើស ឬហាក់ដូចជាយល់ព្រមចូលរួមក្នុងសកម្មភាពផ្លូវភេទក៏ដោយ។ ទាំងនោះគឺដោយសារតែពួកគេមិនបានយល់ច្បាស់ជាមុនពីអ្វីដែលពួកគេបានធ្វើ ឬផលវិបាកដែលអាចកើតឡើងពីសកម្មភាពរបស់ពួកគេនោះទេ។

### ២. បើទោះបីជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពេលខ្លះមិនមានការជួបទាក់ទងផ្ទាល់ជាមួយជនល្មើសក៏ដោយ តែវានៅតែអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដូចការជួបផ្ទាល់ដែរ៖

ទម្រង់ជាច្រើននៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសតាមប្រព័ន្ធអនឡាញ អាចកើតឡើងបានដោយមិនចាំបាច់ទាល់តែមានការជួបផ្ទាល់ ឬការប៉ះពាល់រាងកាយផ្ទាល់រវាងជនល្មើស និងកុមារនោះឡើយ។ ឧទាហរណ៍ដូចជាការថតរូបកុមារបែបផ្លូវភេទ ការចែកចាយរូបភាពទាំងនោះតាមប្រព័ន្ធអនឡាញ ឬការបង្ហាញឱ្យកុមារឃើញនូវរូបភាពបែបផ្លូវភេទជាដើម។

### ៣. ការផ្តល់ជាប្រាក់កាស វត្ថុមានតម្លៃ ឬអំណោយជាថ្នូរនឹងការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទ គឺជាការកេងប្រវ័ញ្ច៖

ជនល្មើសផ្លូវភេទលើកុមារតែងតែកេងប្រវ័ញ្ចកុមារដោយផ្តល់ ឬសន្យាផ្តល់ឱ្យពួកគេនូវអ្វីដែលគេត្រូវការ ដើម្បីបញ្ចុះបញ្ចូលកុមារឱ្យធ្វើសកម្មភាពផ្លូវភេទ ហើយឆ្លៀតឱកាសដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនពីកុមារ។ ទង្វើនេះត្រូវបានចាត់ទុកជាអំពើខុសច្បាប់ដែលត្រូវផ្តន្ទាទោស។



### ៤. ទាំងកុមារា និងកុមារីអាចត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ៖

ទាំងកុមារា និងកុមារីសុទ្ធតែអាចជួបហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទដូចគ្នាដែរ។ ការមិនបានយល់ដឹងថាកុមារាក៏អាចជាជនរងគ្រោះដែរនោះ បានធ្វើឱ្យកុមារាទទួលរងនូវភាពងាយរងគ្រោះ ព្រោះថាពួកគេនឹងមិនទទួលបានជំនួយដែលពួកគេត្រូវការបានល្អប្រសើរទេ បន្ទាប់ពីទទួលរងនូវការកេងប្រវ័ញ្ច។



### ៥. ជនល្មើសផ្លូវភេទលើកុមារភាគច្រើន ជាមនុស្សដែលកុមារស្គាល់៖

ជារឿយៗកុមារតែងត្រូវបានគេបោកបញ្ឆោត ឬលួងលោមដោយមនុស្សដែលកុមារជឿទុកចិត្ត ហើយយល់ព្រមផ្ញើរូបភាពសម្ភារៈផ្លូវភេទដល់ជនល្មើសតាមប្រព័ន្ធអនឡាញ។



### ៦. ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវចាប់ផ្តើមដោយការប្រាស្រ័យទាក់ទងដោយបើកចំហ ហើយមិនគួរហាមកុមារពីការប្រើប្រាស់ប្រព័ន្ធអនឡាញនោះទេ៖

ការហាមកុមារប្រើប្រាស់អ៊ីនធឺណិតគឺមិនមានប្រសិទ្ធិភាព ឬ សមហេតុផលនោះទេ។ កុមារនឹងទទួលបានការការពារល្អ ប្រសើរ ប្រសិនបើពួកគេបានដឹងពីវិធីក្នុងការសម្រេចចិត្តបានត្រឹមត្រូវ ក៏ដូចជាដឹងពីការប្រព្រឹត្តនូវទង្វើប្រកបដោយសុវត្ថិភាព និងឆ្លាតវៃនៅពេល ប្រើប្រាស់ប្រព័ន្ធអនឡាញ។



### ៧. កុមារគ្រប់វ័យ សុទ្ធតែអាចជួបហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ៖

ការពិភាក្សា ឬការណែនាំកុមារពីសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ គួរតែចាប់ផ្តើមតាំងពីពេលដែលពួកគេមានអាយុតិច និងជាពិសេសតាំងពីពេលដែលពួកគេចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធអនឡាញ។

## គ. ការរាយការណ៍អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការរាយការណ៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ករណីនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ អាចត្រូវបានរាយការណ៍ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតលោកអ្នកបំផុត ឬទូរស័ព្ទទៅកាន់លេខទូរស័ព្ទជំនួយបន្ទាន់របស់នគរបាលជាតិតាមរយៈលេខ១២៨៨។ អ្នកក៏អាចរាយការណ៍មកកាន់លេខទូរស័ព្ទរាយការណ៍បន្ទាន់របស់អង្គការសកម្មភាពដើម្បីកុមារ (APLE) តាមរយៈលេខ ០៩២ ៣១១ ៥១១ ឬតាមរយៈបណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត www.internethotlinecambodia.org។ នៅក្នុង**ឧបសម្ព័ន្ធទី៤** អ្នកអាចស្វែងរកបន្ថែមនូវបញ្ជីលេខទូរស័ព្ទទំនាក់ទំនង សម្រាប់ការរាយការណ៍ និងបញ្ជូនករណីបន្ត។ ជាងនេះទៅទៀត អ្នកក៏អាចស្វែងយល់បន្ថែមអំពីសេវាគាំទ្រផ្ដល់ដោយអង្គការក្រៅរដ្ឋាភិបាលដែលប្រតិបត្តិការនៅគ្រប់ រាជធានី ខេត្តទូទាំងប្រទេសកម្ពុជាដោយរួមបញ្ចូលនូវការគាំទ្រផ្នែកផ្លូវចិត្ត ជំនួយផ្នែកច្បាប់ ការស្ដារឡើងវិញ ការស្ដារនីតិសម្បទា ការធ្វើសមាហរណកម្ម ការអប់រំ ក៏ដូចជាសេវាសំខាន់ៗដទៃទៀត តាមរយៈសៀវភៅជំនួយស្មារតីសេវាសម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ ក្នុងខែវិច្ឆិកា ឆ្នាំ២០២០។

### ការរាយការណ៍ពីករណីនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ប្រសិនបើអ្នកបានឃើញដោយចៃដន្យនូវវត្ថុមានរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឬកុមារបានលាតត្រដាងពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញទៅអ្នកនោះអ្នកអាចចូលរួមរាយការណ៍មកកាន់បណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត **www.internethotlinecambodia.org** ។ ការរាយការណ៍ គឺមានលក្ខណៈអនាមិក និងរក្សាការសម្ងាត់។ បណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិតរបស់អង្គការសកម្មភាពដើម្បីកុមារត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយមូលនិធិ INHOPE និងផ្ដល់នូវមធ្យោបាយងាយស្រួលនិងមានប្រសិទ្ធិភាពក្នុងការរាយការណ៍អំពីករណីនានាដែលទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា។ នៅពេលដែលអង្គការសកម្មភាពដើម្បីកុមារទទួលបានការរាយការណ៍ អ្នកវិភាគបណ្ដាញរាយការណ៍ពិសេស នឹងធ្វើការវិភាគ វាយតម្លៃអំពីភាពស្របច្បាប់នៃព័ត៌មាន ហើយបន្ទាប់មកភ្នាក់ងារអនុវត្តច្បាប់ និង/ឬអ្នកផ្ដល់សេវាកម្មអ៊ីនធឺណិតត្រូវបានផ្ដល់ដំណឹងដើម្បីឱ្យជួយដករូបភាព និងសម្ភារៈខុសច្បាប់ទាំងនោះចេញពីគេហទំព័រ។



## របៀបរាយការណ៍តាមរយៈបណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត

- **ជំហានទី១៖** ចូលទៅកាន់គេហទំព័រ **www.internethotlinecambodia.org**




- **ជំហានទី២៖** ចុចប៊ូតុង **Report Abuse** ឬ រាយការណ៍ការរំលោភបំពាន




- **ជំហានទី៣៖** ជ្រើសរើសយកប្រភេទករណីនៃការរំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទណាមួយដែលអ្នកចង់រាយការណ៍ រួចបំពេញ ទម្រង់ឱ្យបានត្រឹមត្រូវ




- **ជំហានទី៤៖** ចុចប៊ូតុងបញ្ជូន




**សម្គាល់៖** អ្នកនឹងទទួលបានសារបញ្ជាក់ពីការបញ្ជូនការរាយការណ៍របស់អ្នកដោយជោគជ័យ។

## ហេតុអ្វីបានជាអ្នកត្រូវរាយការណ៍?

អ្នកអាចជួយបញ្ឈប់នូវការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារបាន ប្រសិនបើអ្នកបានដឹងពីករណីទាំងនោះតាមរយៈការចូលរួមរាយការណ៍។ តើហេតុអ្វីបានជាចាំបាច់ត្រូវរាយការណ៍អំពីករណីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ?

មូលហេតុសំខាន់បំផុត ដែលយើងត្រូវចូលរួមរាយការណ៍នោះគឺ អាចជួយដល់កុមារឱ្យទទួលបាននូវការគាំទ្រ និងជំនួយដែលសមស្របនានា

ការរាយការណ៍ជួយនាំយកជនល្មើសមកទទួលទោសតាមផ្លូវច្បាប់

ការរាយការណ៍កាន់តែច្រើននាំឱ្យជនល្មើស កាន់តែខ្លាចរអារក្នុងការប្រព្រឹត្តបទល្មើស

ការរាយការណ៍កាន់តែច្រើន អាចផ្តល់ទំនុកចិត្តកាន់តែខ្ពស់ដល់ជនរងគ្រោះក្នុងការលាតត្រដាងពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ

ការរាយការណ៍អាចជួយលុបចោលនូវរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារចេញពីប្រព័ន្ធអ៊ីនធឺណិត និងជួយបញ្ឈប់រាល់ការកេងប្រវ័ញ្ចផ្សេងៗ

ការរាយការណ៍អាចធ្វើឡើងដោយអនាមិក

មេរៀនទី ២

# សារៈសំខាន់នៃការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារ

## មាតិកាមេរៀនទី២


២.១ ប្រធានបទសំខាន់ៗ

២.២ នរណាជាក្រុមគោលដៅ

២.៣ រយៈពេលនៃមេរៀន

២.៤ សេចក្តីផ្តើម

២.៥ ប្លង់មេរៀន

២.៦ ខ្លឹមសារមេរៀនលម្អិត

ក. ការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការពិភាក្សាលើប្រធានបទជាមួយកុមារតូច (prepubescent)៖

> ការពិភាក្សាពីប្រធានបទទី១៖ គោលការណ៍ "ទេ-ទៅ-ប្រាប់"

> ការពិភាក្សាពីប្រធានបទទី២៖ ការប៉ះពាល់ដែលល្អ និងមិនល្អ

> ការពិភាក្សាពីប្រធានបទទី៣៖ ការស្គាល់ផ្នែកនៃរាងកាយ (ផ្នែកឯកជន)

ខ. ការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការពិភាក្សាលើប្រធានបទជាមួយកុមារធំ (After Puberty)

> ការពិភាក្សាពីប្រធានបទទី៤៖ ការព្រមព្រៀង និងទំនាក់ទំនងប្រកបដោយសុខុមាលភាព

> ការពិភាក្សាពីប្រធានបទទី៥៖ ហានិភ័យនៃរូបភាព វីដេអូអាសអាភាស

គ. ការជជែកអំពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ និងសារសុវត្ថិភាព

# មេរៀនទី ២ សារៈសំខាន់នៃការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារ

## ២.១ ប្រធានបទសំខាន់ៗ

- ការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការពិភាក្សាលើប្រធានបទជាមួយកុមារ
- ការជជែកអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងសារសុវត្ថិភាព

## ២.២ នរណាជាក្រុមគោលដៅ

វគ្គបណ្តុះបណ្តាលនេះ បង្កើតឡើងសម្រាប់អ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារជាពិសេសសម្រាប់អ្នកដែលមានចំណេះដឹងតិចតួច ឬមិនមានចំណេះដឹងសោះអំពីការបង្ការ និងទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ ជាអ្នកដែលបានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានលើប្រធានបទនេះរួចហើយ តែត្រូវការរំលឹកមេរៀនសារឡើងវិញ។

## ២.៣ រយៈពេលនៃមេរៀន

២៥នាទី ទៅ ៣០នាទី

## ២.៤ សេចក្ដីផ្ដើម



កុមារត្រូវតែមានអារម្មណ៍សុវត្ថិភាព និងដឹងថាពួកគេអាចនិយាយជាមួយមនុស្សពេញវ័យដែលគួរឱ្យទុកចិត្តអំពីបញ្ហាដែលទាក់ទងនឹងពួកគេ។ ពួកគេក៏ត្រូវដឹងដែរថា ពួកគេមានមនុស្សពេញវ័យណាម្នាក់ដែលអាចណែនាំពួកគេឱ្យយល់អំពីអាកប្បកិរិយាត្រឹមត្រូវ និងមិនត្រឹមត្រូវ ហើយមនុស្សពេញវ័យទាំងនោះនឹងការពារពួកគេនៅពេលចាំបាច់ណាមួយ។

ក្នុងនាមជាអ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារ អ្នកគួរតែដឹងពីវិធីសាស្ត្រដើម្បីលើកទឹកចិត្តកុមារឱ្យនិយាយដោយបើកចំហពីបញ្ហារបស់ពួកគេ និងធានាថាពួកគេមានចំណេះដឹងត្រឹមត្រូវដើម្បីជួយខ្លួនឯងឱ្យមានសុវត្ថិភាព។

តាមរយៈមេរៀននេះ សិក្ខាកាមនឹងអាចយល់ដឹងពីវិធីសាស្ត្រក្នុងការសន្ទនាអំពីបញ្ហាផ្លូវភេទជាមួយកុមារ របៀបលើកទឹកចិត្តកុមារឱ្យនិយាយចេញនូវរឿងរ៉ាវដែលបានកើតឡើង។

តាមរយៈមេរៀននេះ សិក្ខាកាមនឹង៖

- ដឹងពីសារៈសំខាន់នៃការពិភាក្សាដោយបើកចំហជាមួយកុមារ
- ដឹងអំពីប្រធានបទសំខាន់ៗដែលគួរពិភាក្សាជាមួយកុមារដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ
- ដឹងពីវិធីសាស្ត្រសំខាន់ៗក្នុងការទំនាក់ទំនងជាមួយកុមារ និងការពារពួកគេពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

## ២.៥ ប្លង់មេរៀន

| ផ្នែក | រយៈពេល | ព័ត៌មានលម្អិត |
|---|---|---|
| ផ្នែកទី១ | ៥នាទី | អ្នកសម្របសម្រួលចាប់ផ្តើមដោយការបង្ហាញពីសារសំខាន់នៃការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារ ជាពិសេសការជជែកជាមួយកុមារពីប្រធានបទបែបផ្លូវភេទ។ |
| ផ្នែកទី២ | ១៥នាទី | **សំនួរបំផុស៖** សួរទៅកាន់អ្នកចូលរួម ថាតើពួកគេបានដឹងទេ ប្រធានបទអ្វីខ្លះដែលគួរនិយាយជាមួយកុមារ ដើម្បីឱ្យពួកគេបានយល់ច្បាស់ពីការការពារខ្លួន ជាពិសេសអាចកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេបាន? <br><br> អ្នកសម្របសម្រួលសរុបនូវចម្លើយរបស់សិក្ខាកាម និងបង្ហាញបន្ថែមអំពីប្រធានបទដែលអាចពិភាក្សាដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ |
| ផ្នែកទី៣ | ១០នាទី | អ្នកសម្របសម្រួលបន្តពន្យល់ពីវិធីសាស្ត្រសំខាន់ៗក្នុងការទាក់ទងជាមួយកុមារ និងការពារពួកគេពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ |

## ១.៦ ខ្លឹមសារមេរៀនលម្អិត

មានប្រធានបទច្រើនណាស់ ដែលអ្នកគួរលើកឡើងក្នុងការពន្យល់ ពិភាក្សាជាមួយកុមារដោយបើកចំហរ ដើម្បីបង្កើតនូវមូលដ្ឋានដ៏ល្អប្រសើរចំពោះកុមារក្នុងការស្វែងយល់បន្ថែម និងអាចលើកឡើងពីកង្វល់នៅពេលចាំបាច់។ ប្រធានបទទាំងនោះ អាចជាប្រធានបទដែលទាក់ទងនឹងផ្នែកនៃរាងកាយ ទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដទៃ ឬប្រធានបទដែលទាក់ទងនឹងផ្នែកផ្លូវភេទជាដើម។

ការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយកុមារលើប្រធានបទទាំងនេះ ពិតជាមានសារសំខាន់ណាស់ ព្រោះវាអាច៖

១. ផ្តល់ឱ្យកុមារនូវចំណេះដឹងដែលអាចជួយការពារពួកគេពីការរំលោភបំពាន។ ជាពិសេស វាអាចកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារ តាមរយៈការជួយពួកគេឱ្យស្គាល់ពីស្ថានភាពដែលអាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យ យល់ពីអាកប្បកិរិយាបែបណាដែលត្រូវបានចាត់ទុកថាមិនសមរម្យ និងផ្តល់ឱ្យពួកគេនូវទំនុកចិត្តបន្ថែមទៀតក្នុងការប្រឈមមុខ និងហ៊ាននិយាយថាទេចំពោះមនុស្សដែលលួងលោមពួកគេក្នុងចេតនាមិនល្អ

២. បំបាត់អារម្មណ៍ខ្មាស់អៀន អារម្មណ៍ដែលគិតថាខ្លួនឯងបានធ្វើខុស និងអារម្មណ៍ភ័យខ្លាចក្នុងករណីដែលការរំលោភបំពានបានកើតឡើង ហើយលើកទឹកចិត្តពួកគេឱ្យហ៊ានប្រាប់ពីរឿងរ៉ាវទាំងនោះ។ ជាងនេះទៅទៀត វាអាចជួយពួកគេឱ្យយល់ថាពួកគេមិនត្រូវបានស្តីបន្ទោសឡើយ ប្រសិនបើពួកគេត្រូវបានរំលោភបំពានផ្លូវភេទ។

### ក. ការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការពិភាក្សាលើប្រធានបទជាមួយកុមារតូច ( prepubescent )

### ការពិភាក្សាពីប្រធានបទទី១៖ គោលការណ៍ " ទេ-ទៅ-ប្រាប់ "

ទោះបីជាកុមារស្ថិតក្នុងវ័យតូចក៏ដោយ កុមារត្រូវតែទទួលបាននូវឧបករណ៍ដើម្បីដោះស្រាយចំពោះស្ថានភាពដែលពួកគេមានអារម្មណ៍ថាត្រូវបានគេគំរាមកំហែង ហើយដឹងពីវិធីល្អបំផុតក្នុងការឆ្លើយតប។ គោលការណ៍ទាំងបី " ទេ ទៅ ប្រាប់ " ជួយឱ្យកុមារ អាចការពារខ្លួនរបស់ពួកគេដោយខ្លួនឯងប្រកបដោយភាពវៃឆ្លាត។ គោលការណ៍ " ទេ-ទៅ-ប្រាប់ " គួរត្រូវបានបង្រៀនដល់កុមារដោយការពន្យល់ដូចខាងក្រោម [៥៤]៖

**គោលការណ៍ " ទេ ! "៖** ផ្នែកខ្លះនៃរាងកាយរបស់ខ្ញុំ គឺមិនអាចប៉ះពាល់បានទេ។ ប្រសិនបើមានអ្នកណាម្នាក់ប៉ះខ្ញុំ ក្នុងលក្ខណៈមួយធ្វើឱ្យខ្ញុំព្រួយបារម្ភ ភ័យខ្លាច ឬឈឺចាប់ នោះខ្ញុំមានសិទ្ធិនិយាយថា " ទេ "។

**គោលការណ៍ " ទៅ ! "៖** ប្រសិនបើខ្ញុំស្ថិតនៅក្នុងស្ថានភាពមួយដែលធ្វើឱ្យខ្ញុំព្រួយបារម្ភ ឬភ័យខ្លាចនោះ ខ្ញុំត្រូវគេចចេញពីស្ថានភាពនោះ។

**គោលការណ៍ " ប្រាប់ ! "៖** ប្រសិនបើខ្ញុំមានអារម្មណ៍ភ័យខ្លាច មិនស្រួលក្នុងចិត្ត ឬមិនសប្បាយចិត្តចំពោះស្ថានភាពណាមួយ នោះខ្ញុំត្រូវទៅប្រាប់មនុស្សពេញវ័យដែលគួរឱ្យទុកចិត្តអំពីកង្វល់របស់ខ្ញុំ។ មនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត គឺស្ថិតនៅជុំវិញខ្លួនខ្ញុំ ដែលអាចជួយ និងគាំទ្រខ្ញុំបាន។

### ការពិភាក្សាពីប្រធានបទទី២៖ ការប៉ះពាល់ដែលល្អ និងមិនល្អ

ការពន្យល់ដល់កុមារតូចអំពីផ្នែកណាមួយនៃរាងកាយដែលមិនគួរត្រូវបានប៉ះដោយអ្នកដទៃ ហើយត្រូវបានចាត់ទុកថាមិនសមរម្យ គឺជារឿងដែលល្អបំផុត។ កុមារអាចបេះបែងចែកពីអ្វីដែលជាទង្វើសមរម្យ និងមិនសមរម្យ ប្រសិនបើនរណាម្នាក់ប៉ះពាល់ផ្នែកណាមួយនៃរាងកាយរបស់កុមារ។ ការពន្យល់ដោយការប្រើប្រាស់ភាសា ដែលមានលក្ខណៈសក្តិសមនឹងអាយុរបស់កុមារ គួរត្រូវបានគិតពិចារណា មុនពេលយកប្រធានបទប្រភេទនេះទៅជជែកជាមួយពួកគេ។ ទោះជាយ៉ាងនេះក៏ដោយ ការប៉ះពាល់ផ្នែកណាមួយនៃរាងកាយរបស់នរណាម្នាក់ បើទោះបីជាវាមិនស្ថិតនៅតំបន់ឯកជនក៏ដោយ ក៏អាចចាត់ទុកជាការមិនសមរម្យដែរ ប្រសិនបើជននោះ មិនមែនជាមនុស្ស ឬសាច់ញាតិ

[៥៤] កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង " ការរក្សាកុមារឱ្យរួចផុតពីការរំលោភបំពាន " ដោយអង្គការទស្សនៈពិភពលោក ឆ្នាំ២០១៤

ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយកុមារ។ ឧទាហរណ៍នៅពេលដែលម្តាយឪបកូននោះមិនត្រូវបានចាត់ទុកជាទង្វើមិនសមរម្យនោះទេ តែប្រសិនបើជនដទៃណាម្នាក់ មកឪបកុមារនោះ វាអាចជាទង្វើមិនសមរម្យ។ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយកុមារឱ្យដឹងពីអ្វីជាការប៉ះពាល់ដែលល្អ និងមិនល្អ ហើយនរណាដែលប៉ះពាល់កុមារក្នុងន័យល្អ និងមិនល្អ ជាពិសេសត្រូវពន្យល់ប្រាប់ពួកគេពីអ្វីដែលត្រូវធ្វើ ប្រសិនបើពួកគេមានអារម្មណ៍មិនស្រួល។

ចំណុចសំខាន់មួយទៀតដែលអ្នកត្រូវសង្កត់ធ្ងន់នៅពេលនិយាយអំពីការប៉ះពាល់ដែលល្អ និងការប៉ះពាល់ដែលមិនល្អជាមួយកុមារ គឺពួកគេត្រូវចងចាំថា មិនត្រឹមតែគ្មាននរណាម្នាក់ ដែលអាចប៉ះពាល់ផ្នែកឯកជនរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏មិនត្រូវប៉ះពាល់ផ្នែកឯកជនរបស់នរណាម្នាក់ផ្សេងទៀតដែរ។

### ការពិភាក្សាពីប្រធានបទទី៣៖ ការស្គាល់ផ្នែកនៃរាងកាយ (ផ្នែកឯកជន)

ដើម្បីឱ្យកុមារអាចនិយាយអំពីបញ្ហាផ្លូវភេទដែលពួកគេបានជួបប្រទះ ពួកគេត្រូវដឹងពីឈ្មោះនៃផ្នែកឯកជនរបស់ពួកគេ។ ការស្គាល់ពីផ្នែកឯកជន និងចេះហៅផ្នែកទាំងនោះ មានសារៈសំខាន់ណាស់ជាពិសេសសម្រាប់កុមារតូចៗ។ ក្នុងនាមអ្នកជាអ្នកដែលធ្វើការពាក់ព័ន្ធផ្ទាល់ជាមួយកុមារ អ្នកមិនគួរមានភាពខ្មាស់អៀនក្នុងការពិភាក្សា អំពីផ្នែកផ្សេងៗនៃរាងកាយជាមួយកុមារនោះទេ ព្រោះប្រសិនបើអ្នកមានភាពខ្មាសអៀនក្នុងការពិភាក្សា កុមារក៏អាចមានអារម្មណ៍ខ្មាសអៀន និងមិនហ៊ាននិយាយដែរ។

## ខ. ការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការពិភាក្សាលើប្រធានបទជាមួយកុមារធំ (After Puberty)

### ការពិភាក្សាពីប្រធានបទទី៤៖ ការព្រមព្រៀង និងទំនាក់ទំនងប្រកបដោយសុខុមាលភាព

កុមារត្រូវការការណែនាំអំពីអ្វីដែលចាត់ទុកថាជាទំនាក់ទំនងប្រកបដោយសុខុមាលភាព និងអត្ថន័យនៃការព្រមព្រៀង។ ពួកគេគួរតែដឹងថាទំនាក់ទំនងផ្លូវភេទរវាងមនុស្សពេញវ័យដែលមានការព្រមព្រៀងផ្នែកផ្លូវភេទរវាងគ្នាទៅវិញទៅមក គឺជារឿងធម្មតា ប៉ុន្តែទំនាក់ទំនងផ្លូវភេទដោយគ្មានការព្រមព្រៀង ឬទំនាក់ទំនងបែបផ្លូវភេទ ជាមួយកុមារដែលមិនទាន់ដល់នីតិភាពនៃការរួមភេទ ជាអំពើខុសច្បាប់ ព្រោះថាការព្រមព្រៀងខាងផ្នែកផ្លូវភេទ កើតឡើងនៅពេលដែលដៃគូបានផ្តល់ការយល់ព្រមពេញលេញក្នុងការចូលរួមសកម្មភាពផ្លូវភេទ ហើយតាមបញ្ញត្តិច្បាប់នៅកម្ពុជា នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ។ ផ្ទុយទៅវិញ ប្រសិនបើជនណាមួយធ្វើការរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ នោះនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ជាងនេះទៅទៀត ជនណារួមភេទ ឬធ្វើអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទជាមួយអនីតិជន (ជនដែលមានអាយុក្រោម ១៨ឆ្នាំ) ដោយផ្តល់ ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬទៅឱ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬជនដទៃទៀតត្រូវផ្តន្ទាទោសទៅតាមផ្លូវច្បាប់ បើទោះបីជាមានការព្រមព្រៀងខាងផ្នែកផ្លូវភេទក៏ដោយ។

### ការពិភាក្សាពីប្រធានបទទី៥៖ ហានិភ័យនៃរូបភាព ឬវីដេអូអាសអាភាស

បច្ចុប្បន្ននេះ មានយុវជនវ័យក្មេង និងកុមារតូចៗជាច្រើនដែលចូលមើលរូបភាព វីដេអូអាសអាភាស ដោយចេតនា ឬត្រូវបានអ្នកដទៃនាំឱ្យឃើញ។ វាជារឿងសំខាន់ក្នុងការអប់រំណែនាំកុមារពីផលប៉ះពាល់អវិជ្ជមាននៃរូបភាព វីដេអូអាសអាភាស ព្រោះរូបភាព និងវីដេអូទាំងនោះ បានពណ៌នាអំពីទំនាក់ទំនងផ្លូវភេទដែលមិនសមហេតុផល  និងជំរុញឱ្យមានអាកប្បកិរិយាបំពានផ្លូវភេទ ជាពិសេសអាចជាឱកាសឱ្យកុមារជួបប្រទះនូវការកេងប្រវ័ញ្ចផ្លូវភេទក៏ថាបាន។

### គ. ការជជែកអំពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ និងសារសុវត្ថិភាព

ការនិយាយអំពីបញ្ហាផ្លូវភេទ ជាទូទៅហាក់មានភាពលាក់បាំង និងខ្មាស់អៀននៅឡើយ ហើយកុមារប្រហែលជាមិនក្លាហានក្នុងការចាប់ផ្ដើមការសន្ទនាលើប្រធានបទនេះនៅឡើយទេ។ ការជជែកដោយ បើកចំហជាមួយកុមារលើប្រធានបទស្ដីអំពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ក៏មានសារសំខាន់មិនខុសពីការជជែកលើប្រធានបទស្ដីអំពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្រៅប្រព័ន្ធអនឡាញដែរ។ ការនិយាយជាមួយកុមារអំពីការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអនឡាញដែលមានសុវត្ថិភាព នឹងធ្វើឱ្យពួកគេមានទំនុកចិត្តក្នុងការចែករំលែកបទពិសោធន៍តាមអនឡាញជាមួយអ្នក។ ប្រសិនបើពួកគេប្រាប់ពីការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញដែលបានកើតឡើង សូមស្ដាប់ពួកគេដោយយកចិត្តទុកដាក់ និងស្វែងយល់ពីតម្រូវការរបស់ពួកគេ។

អ្នកអាចអនុវត្តបាននូវវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ដើម្បីប្រាកដថាអ្នកអាចតាមដានពីការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ ជាពិសេសផ្ដល់ការគាំទ្រដល់ពួកគេ និងអាចឱ្យពួកគេទុកចិត្តក្នុងការស្នើសុំជំនួយប្រសិនបើពួកគេត្រូវការ។

### ១. ស្វែងយល់ពីការវិវឌ្ឍនៃបច្ចេកវិទ្យា

ប្រព័ន្ធអ៊ីនធឺណិតកំពុងតែផ្លាស់ប្ដូរ និងជឿនលឿនឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ហើយវាក៏មិនមានភាពងាយស្រួលដែរក្នុងការតាមដាននូវកម្មវិធីថ្មីៗ ក៏ដូចជាផលប៉ះពាល់ដែលអាចកើតឡើងចំពោះសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។ ទោះជាយ៉ាងនេះក្ដី ការព្យាយាមតាមឱ្យទាន់រាល់ការផ្លាស់ប្ដូរនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់កុមារ អាចជួយការពារពួកគេឱ្យមានសុវត្ថិភាពពីហានិភ័យថ្មីៗដែលអាចនឹងកើតមានឡើង។

## ២. ផ្តល់ការគាំទ្រ

កុមារត្រូវដឹងថាពួកគេអាចនិយាយប្រាប់ដោយបើកចំហពីបញ្ហារបស់ពួកគេបាន។ ទោះបីជាអ្នកឃើញថាកុមារបានចូលរួមក្នុងសកម្មភាពតាមប្រព័ន្ធអនឡាញ ដែលអាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យក៏ដោយ អ្នកមិនគួរស្តីបន្ទោសពួកគេទេ តែត្រូវបង្ហាញថាអ្នកនៅទីនោះ ដើម្បីជួយពួកគេ។ នៅពេលណាដែលកុមារមានអារម្មណ៍ជឿទុកចិត្ត ពួកគេនឹងមករកអ្នក ដើម្បីទទួលបានការគាំទ្រ។

## ៣. រក្សាឧបករណ៍ និងកម្មវិធីឱ្យមានសុវត្ថិភាព

ត្រូវប្រាកដថាឧបករណ៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានរបស់អ្នក ត្រូវបានកំណត់នូវវិធានសុវត្ថិភាពដែលវិធានទាំងនោះរួមមានការប្រើប្រាស់ពាក្យសម្ងាត់ដែលមិនងាយគេលួចប្រើប្រាស់បាន ការគ្រប់គ្រងការចូលប្រើគេហទំព័រ និងកម្មវិធីផ្សេងៗទៀតតាមប្រព័ន្ធអនឡាញ ដើម្បីធានាថាកុមារនឹងមិនឃើញនូវរូបភាព-សម្ភារៈដែលមិនសមរម្យ។

## ៤. កំណត់ពេលវេលាប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ (សូមប្រាប់ដល់កុមារពីហេតុផលដែលអាចទទួលយកបាន)

ប្រសិនបើអ្នកកត់សម្គាល់ថាកូនរបស់អ្នកបានចំណាយពេលច្រើនលើសលប់លើប្រព័ន្ធអ៊ីនធឺណិត ឬញៀននឹងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ឬហ្គេមកំសាន្តតាមអនឡាញ រឿងល្អបំផុតដែលអ្នកត្រូវធ្វើគឺនិយាយជាមួយពួកគេ ដើម្បីឱ្យពួកគេកាត់បន្ថយការប្រើប្រាស់អ៊ីនធឺណិត។ ដូចនេះ ពួកគេនឹងចេះកំណត់ពេលវេលាក្នុងការប្រើប្រាស់អ៊ីនធឺណិតបានល្អប្រសើរ។

## ៥. លើកទឹកចិត្តឱ្យមានការអនុវត្តប្រកបដោយសុវត្ថិភាព

បង្រៀនកុមារឱ្យមានភាពឆ្លាតវៃនៅពេលអនឡាញ។ ភាពឆ្លាតវៃទាំងនោះរួមមានការមិនចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួន ការមិនជួបផ្ទាល់ជាមួយមនុស្សចម្លែកដែលកុមារស្គាល់តែតាមប្រព័ន្ធអនឡាញ ការមិនទទួលយកឯកសារ ឬរូបភាពពីមនុស្សដែលមិនស្គាល់ ការពិនិត្យមើលព័ត៌មានដើម្បីប្រាកដថាអាចជឿទុកចិត្តបាន ក៏ដូចជាការប្រាប់ដល់មនុស្សពេញវ័យ ប្រសិនបើមានអ្វីមិនល្អអាចកើតឡើង។

# ឧបសម្ព័ន្ធ



# ឧបសម្ព័ន្ធ១៖ គម្រូទម្រង់វាយតម្លៃ

**ទម្រង់វាយតម្លៃសម្រាប់វគ្គបណ្តុះបណ្តាល**

សូមវាយតម្លៃផ្នែកនីមួយៗនៃវគ្គបណ្តុះបណ្តាលដោយយោងតាមសំណួរខាងក្រោម។

កម្រិតនៃការវាយតម្លៃពីទាប ទៅ ខ្ពស់ (លេខ1=ទាប រីឯលេខ5=ខ្ពស់)

| | ១. តើលោកអ្នកគិតថាខ្លឹមសារនៃផ្នែកនីមួយៗរបស់វគ្គបណ្តុះបណ្តាលនីមួយៗគួរឱ្យចាប់អារម្មណ៍កម្រិតណា? | ២. តើលោកអ្នកវាយតម្លៃយ៉ាងដូចម្តេច ចំពោះអ្នកធ្វើបទបង្ហាញតាមផ្នែកនីមួយៗ(ចំណេះដឹង វិធីសាស្ត្របង្រៀន ការរៀបចំ...) | ៣. តើចំណេះដឹងដែលលោកអ្នកទទួលបានពីផ្នែកនីមួយៗនៃវគ្គអាចប្រើប្រាស់ ឬអនុវត្តបានក្នុងការងាររបស់លោកអ្នកដែរឬទេ? | ៤. តើវគ្គនេះបានបំពេញតាមការរំពឹងទុករបស់លោកអ្នកដែរឬទេ? | ៥. តើលោកអ្នក គិតថាសម្ភារៈអប់រំ និងឯកសារដែលផ្តល់ជូនមានលក្ខណៈងាយស្រួលយល់គ្រប់គ្រាន់ និងអាចប្រើប្រាស់/ផ្សព្វផ្សាយបន្តបានដែរឬទេ? | ៦. តើលោកអ្នកចង់បំពេញបន្ថែមនូវចំណុចខ្លះខាតណាផ្សេងទៀតតាមផ្នែកនីមួយៗនៃវគ្គដែរឬទេ? (សូមសរសេរនូវចម្លើយរបស់អ្នកក្នុងប្រអប់ខាងក្រោម) | ៧. តើលោកអ្នកគិតថាមានចំណុចណាខ្លះដែលគួរកែប្រែក្នុងផ្នែកនីមួយៗ នៃវគ្គ? (សូមសរសេរនូវចម្លើយរបស់អ្នកក្នុងប្រអប់ខាងក្រោម) |
|---|---|---|---|---|---|---|---|
| ផ្នែកទី១ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | | |
| ផ្នែកទី២ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | | |
| ផ្នែកទី៣ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | | |

| ទម្រង់វាយតម្លៃសម្រាប់វគ្គបណ្ដុះបណ្ដាល<br>សូមវាយតម្លៃផ្នែកនីមួយៗនៃវគ្គបណ្ដុះបណ្ដាលដោយយោងតាមសំណួរខាងក្រោម។<br>កម្រិតនៃការវាយតម្លៃពីទាប ទៅ ខ្ពស់ (លេខ1=ទាប រីឯលេខ5=ខ្ពស់) | | | | | |
|---|---|---|---|---|---|
| **ផ្នែកទូទៅនៃវគ្គបណ្ដុះបណ្ដាល៖** | | | | | |
| ៨. តើលោកអ្នក វាយតម្លៃយ៉ាងដូចម្ដេចចំពោះវគ្គបណ្ដុះបណ្ដាលទាំងមូល? | 1 | 2 | 3 | 4 | 5 |
| ៩. តើលោកអ្នក បានបង្កើននូវចំណេះដឹងកម្រិតណាលើប្រធានបទស្ដីពី.................................................. បន្ទាប់ពីចូលរួមវគ្គបណ្ដុះបណ្ដាលនេះ? | 1 | 2 | 3 | 4 | 5 |
| ១០. តើវគ្គបណ្ដុះបណ្ដាលនេះ អាចបង្កើននូវចំណេះដឹងរបស់លោកអ្នកស្ដីពីវិធីរាយការណ៍ករណីសង្ស័យបានកម្រិតណា? | 1 | 2 | 3 | 4 | 5 |
| តើលោកអ្នក មានមតិយោបល់ ឬការស្នើសុំបន្ថែមទៀតដែរឬទេ? | | | | | |
| | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

APLE

**អង្គការសកម្មភាពដើម្បីកុមារ**

# វិញ្ញាបនបត្របញ្ជាក់ការសិក្សា

## CERTIFICATE OF COMPLETION

សូមបញ្ជាក់ថា / Certify that ........................................

បានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពី ........................................

ដោយជោគជ័យ នាថ្ងៃទី ........................................

has successfully completed a training course on ........................................

delivered on ........................................

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី

**នាយកប្រតិបត្តិ**

Executive Director

........................................

**គ្រូបណ្តុះបណ្តាល**

Trainer

........................................

# ឧបសម្ព័ន្ធ៣៖ ករណីសិក្សា-ការកំណត់អំពីការលួងលោម (សម្រាប់សកម្មភាពក្រុមក្នុងមេរៀនទី២ នៃជំពូក១)

## ករណីសិក្សាទី១៖

បុរសជនជាតិអាមេរិកម្នាក់ ដែលបានរៀបការជាមួយស្ត្រីខ្មែរនៅខេត្តសៀមរាប ត្រូវបានរកឃើញថាមានទំនាក់ទំនងជាមួយកុមារាជាច្រើននាក់ដែលមានអាយុពី ១២ ទៅ ១៥ឆ្នាំនៅក្នុងសហគមន៍។ បុរសនោះបានទទួលចិញ្ចឹមកុមារាទាំងនោះជាកូនចិញ្ចឹម ហើយឧបត្ថម្ភថ្លៃសាលា ផ្តល់ជាចំណីអាហារ និងកន្លែងស្នាក់នៅដល់ពួកគេ។ ជននោះក៏បានអនុញ្ញាតឱ្យកុមារាទាំងនោះប្រើប្រាស់កុំព្យូទ័រ នាំពួកគេទៅហែលទឹក និងទៅផ្សារទំនើប ឬទៅញ៉ាំអាហារជាមួយគ្នា។ ជាងនេះទៅទៀត បុរសនោះក៏បានទិញអំណោយមួយចំនួនសម្រាប់កុមារាទាំងនោះដែរ ដូចជាសម្លៀកបំពាក់ និងស្ពី ហើយថែមទាំងបានផ្តល់ប្រាក់ដល់ពួកគេទៀតផង។ បុរសជនជាតិអាមេរិកនោះ ក៏កំពុងដំណើរការសាងសង់ផ្ទះថ្មីមួយ ដែលអាចឱ្យកុមារទាំងនោះមានបន្ទប់ស្នាក់នៅផ្ទាល់ខ្លួន។

ករណីនេះក៏ត្រូវបានដឹងដល់អង្គការសកម្មភាពដើម្បីកុមារ ហើយក៏ត្រូវបានស៊ើបអង្កេតដោយបុគ្គលិកការពារកុមារប្រចាំការនៅតំបន់នោះ។ តាមរយៈការស៊ើបអង្កេតគេបានរកឃើញថា កុមារាត្រូវបានជននោះរំលោភបំពានផ្លូវភេទជាប្រចាំ។ ជននោះតែងដេកជាមួយកុមារា បៀតបៀនផ្លូវភេទ ហើយបង្ខំកុមារាទាំងនោះឱ្យប៉ះពាល់ខ្លួនបែបផ្លូវភេទ។ ជាលទ្ធផល ជននោះត្រូវបានឃាត់ខ្លួន និងផ្តន្ទាទោសតាមច្បាប់។

### សំណួរ៖

១. តើជនល្មើសប្រើវិធីអ្វី ដើម្បីទទួលបានការទុកចិត្តពីកុមារ? សូមលើកឧទាហរណ៍ពីក្នុងករណីសិក្សាដើម្បីបញ្ជាក់ពីចម្លើយរបស់អ្នក។

*ក្នុងករណីសិក្សានេះ ការរាយការណ៍ត្រូវបានធ្វើឡើងដោយបុគ្គលិករបស់អង្គការសកម្មភាពដើម្បីកុមារ តែមិនមែនជាអ្នកជិតស្និទ្ធឬមនុស្សពាក់ព័ន្ធនឹងកុមារជាអ្នករាយការណ៍នោះទេ។*

២. តើអ្នកគិតថាមានហេតុផលអ្វីខ្លះដែលរារាំងមនុស្សក្នុងសហគមន៍មិនឱ្យរាយការណ៍ពីអាកប្បកិរិយាគួរឱ្យសង្ស័យរបស់ជននោះ?

៣. តើមានមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យប្រពន្ធរបស់ជននោះមិនរាយការណ៍?

៤. តើមានហេតុផលអ្វីខ្លះ ដែលរារាំងកុមារមិនឱ្យលាតត្រដាងពីការរំលោភបំពាន?

៥. តើមានសកម្មភាពអ្វីខ្លះ ដែលអាចធ្វើទៅបាននៅថ្ងៃអនាគត ដើម្បីការពារកុំឲ្យមានករណីបែបនេះកើតឡើង?

## ករណីសិក្សាទី២៖

មានការរាយការណ៍មួយ ដែលទទួលបានតាមរយៈបណ្តាញរាយការណ៍របស់អង្គការ APLE។ ការរាយការណ៍នេះ បានបញ្ជាក់ថាមានបុរសជនជាតិអាមេរិកម្នាក់ ត្រូវបានគេប្រទះឃើញជាញឹកញាប់ តែងទទួលទានអាហារពេលល្ងាចជាមួយបុរសជនជាតិខ្មែរម្នាក់ទៀត និងកុមារបីនាក់ដែលមានអាយុ ពី ៧ឆ្នាំ ទៅដល់ ១៥ឆ្នាំ។ ការសង្ស័យលើបុរសជនជាតិអាមេរិកនោះ ត្រូវបានលើកឡើងបន្ទាប់ពីបុគ្គលិក ភោជនីយដ្ឋានបានឃើញជននោះនៅជាមួយនឹងក្មេងប្រុសម្នាក់ក្នុងបន្ទប់ទឹក។ ទំនាក់ទំនងមិនសមរម្យ រវាងជនបរទេសនិងក្មេងប្រុស ដូចជាជននោះបានស្ទាបអង្អែល អោប និងលេងក្នុងអាងជាមួយក្មេងប្រុស ទាំង៣នាក់ ក៏បានបង្កឱ្យមានការសង្ស័យ ។

ការស៊ើបអង្កេតបានចាប់ផ្តើមនៅពេលដែលជននោះត្រូវបានប្រទះឃើញថាបាននាំកុមារទាំងនោះទៅ ហាងទំនិញ ទៅសួនទឹក សួនកម្សាន្ត និងកន្លែងជាច្រើនទៀត។ ក្នុងពេលនោះ គេក៏បានឃើញបុរស នោះ លេងបែបស្និទ្ធស្នាលជាមួយកុមារា ស្ទាបអង្អែល ថើបពួកគេជាដើម។ មិនត្រឹមតែប៉ុណ្ណោះ គេក៏ បានរកឃើញថា ជននោះ បានជួយឧបត្ថម្ភលុយកាក់ដល់កុមារទាំងនោះ ជួយជួសជុលផ្ទះ និងជួយជា លុយកាក់ដល់ការសាងសង់ក្នុងសហគមន៍ផងដែរ។ តាមរយៈការសម្ភាសន៍ដែលបានធ្វើឡើងជាមួយ កុមារ បានឱ្យដឹងថាកុមារបានបង្ហាញអំពីការរំលោភបំពានផ្លូវភេទដែលបានកើតឡើងជាបន្តបន្ទាប់រវាង ជននោះ និងកុមារ។ ទោះបីជាករណីនេះត្រូវបានលាតត្រដាងក៏ដោយ ក៏ក្រុមគ្រួសារ និងសមាជិក សហគមន៍ហាក់មានភាពស្ទាក់ស្ទើរក្នុងការជឿថារឿងនេះជាការពិត។ ចុងក្រោយ ជនល្មើសត្រូវបាន ចោទប្រកាន់ និងបញ្ជូនទៅពន្ធនាគារ។

### សំណួរ៖

១. តើជនល្មើសប្រើវិធីអ្វី ដើម្បីទទួលបានការទុកចិត្តពីកុមារ? សូមលើកឧទាហរណ៍ពីក្នុងករណី សិក្សាដើម្បីបញ្ជាក់ពីចម្លើយរបស់អ្នក។

២. តើអ្វីជាសញ្ញាគួរឱ្យសង្ស័យដែលនាំឱ្យមានការរាយការណ៍?

៣. ហេតុអ្វីបានជាអ្នកគិតថាមនុស្សក្នុងសហគមន៍មានការស្ទាក់ស្ទើរក្នុងការជឿថាការរំលោភបំពាន បានកើតឡើង បើទោះបីជាករណីនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈក៏ដោយ? តើត្រូវធ្វើយ៉ាង ដូចម្តេច ដើម្បីទប់ស្កាត់មិនឱ្យមានរឿងបែបនេះកើតឡើងនៅពេលអនាគត?

៤. តើអ្នកគួរធ្វើយ៉ាងណា ប្រសិនបើអ្នកបានឃើញនូវអាកប្បកិរិយាគួរឱ្យសង្ស័យបែបនេះ?

# ឧបសម្ព័ន្ធ៤៖ បញ្ជីលេខទូរស័ព្ទទំនាក់ទំនងបន្ថែមសម្រាប់ការរាយការណ៍ និងបញ្ជូនករណីបន្ត

## ☎ លេខទូរស័ព្ទរាយការណ៍បន្ទាន់ និងលេខទូរស័ព្ទជំនួយបន្ទាន់

| ឈ្មោះអង្គការ/ស្ថាប័ន | លេខទំនាក់ទំនង |
|---|---|
| អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) | 092 311 511<br>បណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត Internet Hotline:<br>www.internethotliinecambodia.org |
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | 023 997 919 |
| បណ្ដាញទូរស័ព្ទសុវត្ថិភាពកុមារ-ChildSafe Hotline | រាជធានីភ្នំពេញ៖ 012 311 112<br>ខេត្តសៀមរាប៖ 017 358 758<br>ខេត្តព្រះសីហនុ៖ 012 478 100 |
| បណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា-Child Helpline Cambodia | 1280 |
| អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ( Legal Support for Children and Women-LSCW ) | 077 455 516 |
| អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ ( LICADHO ) | រាជធានីភ្នំពេញ៖ 066 555 312<br>បាត់ដំបង៖ 066 555 311<br>ខេត្តសៀមរាប៖ 066 555 305<br>ខេត្តព្រះសីហនុ៖ 066 555 303<br>ខេត្តកំពត/កែប៖ 066 555 304 |
| អង្គការសេរីភាពកម្ពុជាអូស្ត្រាលី ( Auscam Freedom Project ) | 011 444 080<br>089 270 278 |
| សម្ព័ន្ធចាប់ដៃ ( Chab Dai Coalition ) | 012 532 554 |
| អង្គការតំណក់ទឹក ( Damnok Toek ) | ប៉ោយប៉ែត៖ 095 960 303<br>អ្នកលឿង៖ 089 500 008 |

* * * សូមស្វែងរកព័ត៌មានបន្ថែមតាមរយៈ " សៀវភៅជំនួយស្មារតីសេវាសម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ផលិតនៅខែវិច្ឆិកា ឆ្នាំ២០២០ " ដោយអង្គការសកម្មភាពដើម្បីកុមារ ( APLE )

## ☎ លេខទូរស័ព្ទការិយាល័យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

| ខេត្ត/ក្រុង | លេខទំនាក់ទំនង | ខេត្ត/ក្រុង | លេខទំនាក់ទំនង |
|---|---|---|---|
| ភ្នំពេញ | 092 187 040 | មណ្ឌលគិរី | 012 917 127 |
| បន្ទាយមានជ័យ | 016 337 373 | ឧត្តរមានជ័យ | 011 402 598 |
| បាត់ដំបង | 012 994 122 | ប៉ៃលិន | 012 948 188 |
| កំពង់ចាម | 092 850 132 | ព្រះវិហារ | 012 510 958 |
| កំពង់ឆ្នាំង | 092 267 247 | ព្រៃវែង | 012 837 326 |
| កំពង់ស្ពឺ | 016 369 564 | ពោធិ៍សាត់ | 012 547 056 |
| កំពង់ធំ | 077 738 767 | រតនគិរី | 012 459 297 |
| កំពត | 088 797 6471 | សៀមរាប | 012 827 078 |
| កណ្ដាល | 015 687 543 | ខេត្តព្រះសីហនុ | 097 769 9767 |
| កែប | 090 332 588 | ស្ទឹងត្រែង | 011 690 607 |
| កោះកុង | 012 662 434 | ស្វាយរៀង | 016 485 687 |
| ក្រចេះ | 012 868 279 | តាកែវ | 077 741 234 |


092 311 511

## ប្រសិនបើអ្នកសង្ស័យពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

សូមរាយការណ៍តាមរយៈលេខទូរស័ព្ទ **092 311 511**

ឬតាមរយៈគេហទំព័រ **www.internethotlinecambodia.org**

លោកអ្នកក៏អាចស្កេន QR Code ដើម្បីចូលទៅកាន់គេហទំព័ររាយការណ៍ផងដែរ


រក្សាសិទ្ធិដោយ៖

APLE 20 YEAR



023 996 351

info@aplecambodia.org

www.aplecambodia.org

/aplecambodia.org

/aple_cambodia.org

/aplecambodia



ឧបត្ថម្ភការបោះពុម្ពដោយ៖

PLAN INTERNATIONAL

terre des hommes stops child exploitation

CHILDHOOD WORLD CHILDHOOD FOUNDATION FOUNDED BY H.M. QUEEN SILVIA OF SWEDEN